ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២៤ លេខ ៣ | ខែកញ្ញា ឆ្នាំ២០២០ | តម្លៃ ១.៥០០៛


30th ANNIVERSARY CDRI 1990 - 2020

# ទៅមុខមិនទាល់៖ ច្រកឆ្លងចូលគ្នារវាងប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រព័ន្ធអប់រំសិក្សាធិការ នៅកម្រិតឧត្តមសិក្សា

## តើការឆ្លងចូលគ្នានៃប្រព័ន្ធអប់រំ និងប្រព័ន្ធបណ្តុះបណ្តាលជាអ្វី?

ជាប្រវត្តិសាស្ត្រ និងជាប្រពៃណី ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ (VET) និងការអប់រំសិក្សាធិការ ត្រូវបានបែងចែកយ៉ាងដាច់ពីគ្នា ដោយសាររចនាសម្ព័ន្ធស្ថាប័ន របស់ប្រព័ន្ធបណ្តុះបណ្តាលនិងអប់រំទាំងពីរនេះ មានភាពខុសគ្នាទាំងស្រុង។ នៅអឺរ៉ុប ការបែងចែករវាងច្រកទាំងពីរ ចាប់ផ្តើមនៅយុគសម័យកណ្តាល ហើយបន្តអនុវត្ត រហូតដល់ដើមសតវត្សរ៍ទី២០។ រហូតដល់ពេលថ្មីៗនេះ VET ផ្អែកលើសមត្ថភាព ត្រូវបានផ្សារភ្ជាប់យ៉ាងខ្លាំង ជាមួយនឹងជំនាញវិជ្ជាជីវៈជាក់លាក់ ហើយមិនត្រូវបានផ្សារភ្ជាប់ច្បាស់លាស់នៅក្នុងការអប់រំសិក្សាធិការ (Field and Guez 2018)។ ក្នុងការធ្វើឲ្យ VET កាន់តែមានភាពពាក់ព័ន្ធ និងអាចឆ្លើយតបបានល្អទៅនឹងការផ្លាស់ប្តូរទីផ្សារការងារយ៉ាងលឿន និងមិនអាចទាយទុកជាមុនបាន និងតម្រូវការទាមទារឲ្យបុគ្គលិកមានជំនាញកម្រិតខ្ពស់ កំណែទម្រង់ថ្មីៗបានផ្តោតលើពិពិធកម្ម និងការឆ្លងចូលគ្នារបស់ VET។



នៅក្នុងបរិបទនៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល ការឆ្លងចូលគ្នាសំដៅលើគន្លងរៀនសូត្រដែលមានភាពបត់បែន ពោលគឺ ការដែលអាចឆ្លងគ្នាតាមខ្សែបញ្ឈរ និងខ្សែផ្តេក រវាងកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាល

នៅក្នុងបរិបទនៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល ការឆ្លងចូលគ្នាសំដៅលើ គន្លងរៀនសូត្រដែលមានភាពបត់បែន ពោលគឺការដែលអាចឆ្លងគ្នាតាមខ្សែបញ្ឈរ និងខ្សែផ្តេក រវាងកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាល និងគ្រឹះស្ថាននានា ដែលបង្កភាពងាយស្រួល ដល់និស្សិតក្នុងការផ្លាស់ប្តូរបរិស្ថានរៀនសូត្រក្នុងល្បឿនខុសៗគ្នា ដោយមិនប្រកាន់ការតម្រង់ទិសរបស់កម្មវិធីសិក្សាណាមួយឡើយ (Cedefop 2012)។ ការឆ្លងចូលគ្នាអាចជួយលុបបំបាត់ទស្សនៈថា VET ជាផ្លូវទាល់ទៅមុខមិនបាន ធ្វើឲ្យ VET កាន់តែមានលក្ខណៈទាក់ទាញសម្រាប់និស្សិតដែលចង់បន្តការសិក្សានៅឧត្តមសិក្សាភ្លាមៗ ឬក៏ប៉ុន្មានឆ្នាំក្រោយពីការទទួលបានសញ្ញាប័ត្រ។ ការឆ្លងចូលគ្នា ក៏ជួយជំរុញឱ្យមានបរិយាប័ន្ន និងផ្លាស់ប្តូរក្នុងសង្គម ដោយផ្តល់ឱកាសសម្រាប់និស្សិតជួបការលំបាក ឬក៏និស្សិតនិទ្ទេសទាប អាចចូលរៀននៅថ្នាក់ឧត្តមសិក្សា និងទទួលបានឱកាសល្អផ្សេងៗដែលឧត្តមសិក្សាផ្តល់ឲ្យ (Field and Guez 2018)។

ការឆ្លងចូលគ្នា ក៏អាចសំដៅដល់ការផ្លាស់ប្តូរពីប្រព័ន្ធអប់រំសិក្សាធិការ មកប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈដែរ ប៉ុន្តែអត្ថបទនេះ ពិនិត្យជាចម្បងតែច្រកឆ្លងរបស់និស្សិតពីប្រព័ន្ធអប់រំ

អត្ថបទនេះរៀបរៀងដោយ ហ៊ុន សីហគន្ធី, ជំនួយការស្រាវជ្រាវ, បណ្ឌិត សុង សុភក្តិ អ្នកស្រាវជ្រាវ និងជានាយកមជ្ឈមណ្ឌល, បណ្ឌិត ជា ផល អ្នកស្រាវជ្រាវ, នៃមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ។ សូមយោងអត្ថបទនេះថា៖ Hun Seyhakunthy, Dr Song Sopheak, and Dr Chea Phal. 2020. “No Dead-End Ahead: Permeability Pathways between Tertiary Vocational Education and Training and Academic Education.” Cambodia Development Review 24 (3): 1–6.

## មាតិកា


ទៅមុខមិនទាល់៖ ច្រកឆ្លងចូលគ្នារវាងប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រព័ន្ធអប់រំសិក្សាធិការ នៅកម្រិតឧត្តមសិក្សា ... ១

ការសិក្សាប្រៀបធៀបលើការអនុវត្តការទូតក្នុងការគ្រប់គ្រងទឹក ផ្តោតលើទន្លេអ៊ីនឌុស និងទន្លេមេគង្គ ........................... ៧

តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ..................... ១៣

— ស្ថានភាពក្នុងប្រទេស....................... ១៦

ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ...................................... ២៨

បណ្តុះបណ្តាលវិជ្ជាជីវៈ ទៅកាន់ប្រព័ន្ធសិក្សាធិការនៅកម្រិតឧត្តមសិក្សា។ ការសិក្សានេះក៏មានពិភាក្សាពី កម្លាំងចលករពីក្រោយការប្រឹងប្រែង ធ្វើឲ្យប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលកាន់តែមានភាពអាចបត់បែន ធ្វើការចង្អុលបង្ហាញពីគោលនយោបាយ និងយន្តការសំខាន់ៗកំពុងត្រូវបានអនុវត្តនៅក្នុងពិភពលោក និងមានផ្តល់ជាសេចក្តីសន្និដ្ឋាន ដោយមានផ្តល់ជាបទពិសោធន៍មួយចំនួន ដែលកម្ពុជាអាចរៀនសូត្រពីប្រទេសឯទៀត។

## ហេតុអ្វីគួរមានការឆ្លងចូលគ្នារវាង VET និងការអប់រំសិក្សាធិការ?

បណ្តាប្រទេសអឺរ៉ុបភាគច្រើន មើលឃើញពីសារៈសំខាន់នៃការរួមបញ្ចូលគ្នារវាងរចនាសម្ព័ន្ធស្ថាប័នទាំងពីរ ក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរទីផ្សារការងារ ដែលទាមទារឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើននូវលំនាំនៃការចូលរួម ដោយសង្កត់ធ្ងន់លើការរៀនសូត្រពេញមួយជីវិត និងពង្រីកលទ្ធភាពទទួលបានការអប់រំថ្នាក់ឧត្តមសិក្សា។ ដើម្បីសម្រេចតាមមហិច្ឆតារបស់អឺរ៉ុបក្នុងការក្លាយជាសេដ្ឋកិច្ចផ្អែកលើចំណេះដឹង ដែលមានសន្ទុះខ្លាំងជាងគេក្នុងពិភពលោក ក្រុមប្រឹក្សាអឺរ៉ុបបានផ្តល់អាទិភាពដល់គោលដៅយុទ្ធសាស្ត្រដូចតទៅ (Spöttl 2013)៖

- ធ្វើឲ្យការរៀនសូត្រពេញមួយជីវិត និងការឈានទ្បើងក្លាយជាការពិត
- កែលំអគុណភាពនិងប្រសិទ្ធភាព នៃការអប់រំនិងបណ្តុះបណ្តាល
- លើកកម្ពស់សមភាព ភាពស្អិតរមួតក្នុងសង្គម និងភាពជាពលរដ្ឋសកម្ម
- លើកកម្ពស់ការច្នៃប្រឌិត និងនវានុវត្តន៍ រួមទាំងសហគ្រិនភាពផង នៅគ្រប់កម្រិតនៃការអប់រំ និងបណ្តុះបណ្តាល។

ដោយផ្អែកតាមវិស័យអាទិភាពទាំងនេះ និងដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ប្រទេសអឺរ៉ុបជាច្រើនបានអនុម័តយកប្រព័ន្ធមួយដែលធានាឲ្យមានការតភ្ជាប់យ៉ាងរលូនរវាង VET ជាមួយនឹងប្រព័ន្ធអប់រំសិក្សាធិការ។ ជាក់ស្តែងដូចនៅក្នុងប្រទេសស្វីស VET ទទួលបានការកោតសរសើរខ្លាំងជាង ការអប់រំសិក្សាធិការទៅទៀត ដោយមាននិស្សិតពីរភាគបីបានចូលរៀនក្នុងកម្មវិធី VET ។ រដ្ឋាភិបាលស្វីស បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើប្រព័ន្ធ VET ក្នុងលក្ខណៈជាមធ្យោបាយសម្រាប់ធានាឲ្យមានកំណើនសេដ្ឋកិច្ច និងការរុងរឿងរបស់ប្រទេសជាតិ និងបានចាប់អនុវត្តច្រកសិក្សាជាច្រើនសម្រាប់និស្សិត VET (Backes-Gellner and Tuor 2010; Hoffman and Schwartz 2015)។ និស្សិត VET ដែលអាចប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិវិជ្ជាជីវៈសហព័ន្ធស្វីស រយៈពេលមួយឆ្នាំបាន (បង្កើតក្នុងឆ្នាំ១៩៩៧) គឺអាចបន្តការសិក្សានៅសាកលវិទ្យាល័យមួយ ក្នុងចំណោមសាកលវិទ្យាល័យទាំង ៩ នៃវិទ្យាសាស្ត្រអនុវត្ត។

លើសពីនេះទៀត ការកែលំអការឆ្លងចូលគ្នានៃការអប់រំអាចជួយកែតម្រូវទ្បើងវិញនូវ បញ្ហារើសអើងដែលជាបុព្វហេតុមូលដ្ឋាននៃ វិសមភាពក្នុងឱកាសទទួលបានការអប់រំនិងការងារ។ ការរើសអើងបែបនេះ តែងប៉ះពាល់ភាគច្រើនទៅលើនិស្សិត VET ដោយសារការយល់ឃើញថា និស្សិតដែលសម្រេចចិត្តរៀនបន្តយក VET ជាច្រកសិក្សាអប់រំរបស់ខ្លួន គឺមកពីប្រវត្តិសិក្សាមិនបានល្អគ្រប់គ្រាន់ សម្រាប់ឲ្យសាកលវិទ្យាល័យទទួលចូលរៀន។ ប្រព័ន្ធឧត្តមសិក្សាដែលមានរួមបញ្ចូល ការអប់រំសិក្សាធិការ និងការអប់រំវិជ្ជាជីវៈ អាចផ្តល់ឲ្យនិស្សិតនូវ ចំណេះដឹង និងជំនាញ ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ និងជួយដោះស្រាយការរើសអើងនៅក្នុងវិស័យការងារ (Spöttl 2013) ។

ការជឿនលឿនផ្នែកបច្ចេកវិទ្យា បានបង្កើតការងារថ្មីៗជាច្រើន ប៉ុន្តែវាក៏ធ្វើឲ្យការងារជាច្រើនប្រភេទ បាត់បង់តម្រូវការក្នុងទីផ្សារផងដែរ។ ទោះបីជាមានការប៉ាន់ប្រមាណខុសគ្នាយ៉ាងច្រើនក៏ដោយ ធនាគារពិភពលោក (២០១៩) ប៉ាន់ស្មានថា ៤៧ភាគរយនៃមុខរបរនៅអាមេរិក និង ៦១ភាគរយនៃប្រជាជននៅស៊ីប (Cyprus) អាចប្រឈមនឹងហានិភ័យនៃស្វ័យប្រវត្តិកម្ម។ គ្រឹះមូលធនមនុស្សរឹងមាំ និងការរៀនសូត្រពេញមួយជីវិត គឺជាគន្លឹះសម្រាប់ការរៀនជំនាញជាថ្មី និងបង្កើនកម្រិតជំនាញឲ្យពលករ ដើម្បីឆ្លើយតបនឹងបច្ចេកវិទ្យាដែលមកជំនួសការងារ នេះបើយោងតាម *របាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០១៩៖ ការផ្លាស់ប្តូរលក្ខណៈនៃការងារ* (*World Development Report 2019: The Changing Nature of Work* (World Bank 2019)។ ចំណុចនេះសង្កត់ធ្ងន់ពីតួនាទីសំខាន់បំផុតនៃប្រព័ន្ធ VET ក្នុងលក្ខណៈជាច្រកសិក្សាមួយទៀតសម្រាប់ការរៀនសូត្រពេញមួយជីវិត ជាជាងច្រកមួយដែលទាល់ផ្លូវទៅមុខ។

## តើការឆ្លងចូលគ្នារវាង VET និងការអប់រំសិក្សាធិការអាចជំរុញយ៉ាងណាបាន?

ផ្អែកលើបទពិសោធជាសកល ដែលភាគច្រើនមានដើមកំណើតនៅក្នុងប្រទេសអភិវឌ្ឍន៍ ការសិក្សានេះកំណត់នូវយុទ្ធសាស្ត្រមានប្រសិទ្ធភាពជាច្រើនសម្រាប់ធ្វើឲ្យ VET និងការអប់រំសិក្សាធិការកាន់តែមានភាពទូលំទូលាយ។ យុទ្ធសាស្ត្រទាំងនោះ រួមមានការបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (NQFs), ការប្រើប្រព័ន្ធ VET ជាឈ្នាន់សម្រាប់បើកឲ្យ និស្សិតដែលមានលទ្ធផលសិក្សាកម្រិតទាបអាចចូលរៀននៅឧត្តមសិក្សា ការចាប់បង្កើតកម្រិតសិក្សាខ្ពស់ៗ ឬផ្លូវអាជីពជឿនលឿនក្នុង VET ដែលមានសមមូលភាពទៅនឹងសញ្ញាប័ត្របរិញ្ញាបត្រ ឬសញ្ញាប័ត្រអនុបណ្ឌិត និងការជំរុញកិច្ចសហការជាប្រព័ន្ធរវាងសាកលវិទ្យាល័យ នឹងវិទ្យាស្ថាន VET នានា។

## ការបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិ

នៅបណ្តាប្រទេសអឺរ៉ុប យន្តការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល លើវិស័យឧត្តមសិក្សា Bologna (1999) និងវិធានការពន្លឿនដើម្បីបង្កើនគុណភាព និងភាពទាក់ទាញរបស់ VET Copenhagen (2002) បានកំណត់ទ្បើងវិញនូវរបៀបវារៈដ៏ចាំបាច់ សម្រាប់កំណែទម្រង់ការអប់រំ និងបណ្តុះបណ្តាល។ គំនិតផ្តួចផ្តើមសំខាន់ៗទាំងពីរនេះ ក្នុងគោលបំណងធ្វើទំនើបកម្ម

នូវប្រព័ន្ធអប់រំ និងបណ្ដុះបណ្ដាលរបស់អឺរ៉ុប បានឈានទៅដល់ការអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិអឺរ៉ុប (EQF)។ Lester (2015) បានរែកញែកថា EQF រួមមាន ប្រាំបីកម្រិតគុណវុឌ្ឍិ ដែលធ្វើការពិពណ៌នាបញ្ជាក់តាមរយៈ សមាសភាគ តម្រង់ទិសទៅវិជ្ជាជីវៈ និងការអនុវត្តផ្សេងៗ, លទ្ធផលរៀនសូត្រ (ចំណេះដឹង ជំនាញ និងសមត្ថភាព), និង វឌ្ឍនភាពរបស់អ្នករៀនសូត្រ (វាស់វែងតាមតម្លៃបន្ថែម)។ ក្របខ័ណ្ឌនេះបានចាប់អនុវត្តនៅឆ្នាំ២០០៨ ដោយមានការកំណត់យកឆ្នាំ២០១០ ជាឆ្នាំគោលដៅសម្រាប់ឲ្យប្រទេសនានា កសាងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (NQF) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើ EQF និងយកឆ្នាំ២០១២ ធ្វើជាឆ្នាំសម្រាប់ឲ្យប្រទេសនានា តភ្ជាប់គុណវុឌ្ឍិជាតិរបស់ខ្លួនជាមួយនឹងកម្រិតនានានៃ EQF។ តាំងពីពេលនោះមក EQF និងបន្ទាប់មកទៀត NQFs គឺជាកម្លាំងជំរុញមួយនៃកំណែទម្រង់គោលនយោបាយអប់រំ និងបណ្ដុះបណ្ដាលនៅក្នុង ៣៨ប្រទេស។

ការអនុម័តប្រើ NQFs ត្រូវបានកំណត់ថា មានអាទិភាពខ្ពស់បំផុត និងបានអនុវត្តឡើងយ៉ាងទៀងទាត់ក្នុងប្រាំឆ្នាំកន្លងមកនេះ ដោយសារប្រទេសនៅអឺរ៉ុបជាច្រើន យល់ពីសារៈសំខាន់របស់ក្របខ័ណ្ឌគុណវុឌ្ឍិ (Elken 2016)។ យោងតាមមជ្ឈមណ្ឌលអឺរ៉ុបសម្រាប់ការអភិវឌ្ឍការបណ្ដុះបណ្ដាលវិជ្ជាជីវៈ (Cedefop 2015) គឺមានការអនុម័តប្រើ NQFs ជាផ្លូវការក្នុង ២៩ប្រទេស រីឯ ៣៤ ប្រទេសអឺរ៉ុបផ្សេងទៀត នៅខែវិច្ឆិកា ២០១៤ បានរាយការណ៍ថា បានរចនារៀបចំយ៉ាងគ្រប់ជ្រុងជ្រោយនូវ NQF ដែលមានលក្ខណៈទូលំទូលាយ ដោយមានការដាក់បញ្ចូលគ្រប់កម្រិតនិងគ្រប់ប្រភេទនៃគុណវុឌ្ឍិ រវាងប្រព័ន្ធអប់រំ នឹងបណ្ដុះបណ្ដាលនានា។ នេះជាឥទ្ធិពលយ៉ាងធំមួយដែល EQF បានជះទៅលើ កំណែទម្រង់ និងការផ្លាស់ប្ដូរ ក្នុងការអប់រំ និងបណ្ដុះបណ្ដាលនៅអឺរ៉ុប។ NQFs នៅអាទ្បឺម៉ង់ រូម៉ានី និង ទួរគី គួបចូលគ្នា ត្រូវបានគេចាត់ទុកជាឧបករណ៍សំខាន់បំផុត សម្រាប់ការកែលំអការឆ្លងចូលគ្នានៅក្នុងប្រព័ន្ធអប់រំ និងបណ្ដុះបណ្ដាលនានា ក្នុងគោលបំណងដើម្បីលុបលំបាត់ភាពខណ្ឌដាច់គ្នា នៅក្នុងឧត្ដមសិក្សា (Cedefop 2015; UNESCO 2015)។ Lester (2015) រែកញែកថែមទៀតថា NQFs បានជួយសម្រួលដល់ការផ្ទេរឆ្លងជំនាញនៅឧត្ដមសិក្សា ហើយផ្ដល់នូវមូលដ្ឋានសម្រាប់ការទទួលស្គាល់ការសិក្សាដែលមានពីមុន និងបង្កើនតម្លាភាពនៃ គុណវុឌ្ឍិ និងកម្រិតផ្សេងៗគ្នា។

## VET **ជាឈ្នាន់ទៅកាន់ឧត្ដមសិក្សា**

តាមធម្មតា សាកលវិទ្យាល័យនានាតែងស្ថិតនៅក្នុងទីក្រុងធំៗ និងទាក់ទាញបានច្រើន នូវការយកចិត្តទុកដាក់ពីសំណាក់និស្សិតដែលសម្រេចបានលទ្ធផលខ្ពស់ៗ រីឯវិទ្យាស្ថាន VET តែងស្ថិតនៅតាមតំបន់ជាយក្រុងចម្ងាយៗ និងច្រើនទាក់ទាញបានតែនិស្សិតទន់ខ្សោយក្រោមមធ្យម ដោយសារ វគ្គសិក្សា VET តែងមានច្រើនមានថ្លៃសិក្សាសមរម្យ និងមានលក្ខខណ្ឌងាយស្រួលក្នុងការចូលរៀន។ លក្ខណៈខណ្ឌគ្នាបែបនេះ ជារបាំងរារាំងការអប់រំ និងបណ្ដុះបណ្ដាល ដែលអាចឆ្លងចូលគ្នា ហើយប្រទេសមួយចំនួនបានប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីដោះស្រាយស្ថានភាពនេះ និងតភ្ជាប់ប្រព័ន្ធអប់រំ និងបណ្ដុះបណ្ដាលនានារបស់ខ្លួន។ ករណីជាក់ស្ដែងមួយគឺ នៅសិង្ហបុរី ការសិក្សាអប់រំផ្នែកបច្ចេកទេស និងពហុបច្ចេកទេស មិនគ្រាន់តែត្រូវបានមើលឃើញថា ជាច្រកសិក្សាដ៏ចាំបាច់មួយសម្រាប់ផ្ដល់ជំនាញអនុវត្តជាក់ស្ដែង និងផលិតនិស្សិតបញ្ចប់ការសិក្សាដែលមានលក្ខណៈត្រៀមស្រេច ក្នុងការបម្រើឧស្សាហកម្ម ប៉ុន្តែក៏ជាផ្លូវមួយផ្សេងទៀតសម្រាប់ការឆ្លងពីសាលាមធ្យមសិក្សាវិជ្ជាជីវៈ ទៅសាកលវិទ្យាល័យ (Agrawal 2013)។ តាមការតភ្ជាប់ប្រព័ន្ធអប់រំរបស់ខ្លួន សិង្ហបុរីអាចដោះស្រាយបានបញ្ហាសិស្សបោះបង់ការសិក្សា ឬបរាជ័យក្នុងការសិក្សា។ សិស្សដែលបរាជ័យក្នុងការប្រឡងយកសញ្ញាប័ត្របញ្ចប់មធ្យមសិក្សា ជាជាងការឈប់ទៅរៀនទាំងស្រុង គឺអាចទទួលយកការអប់រំតម្រង់ទិសទៅរកការអនុវត្ត ដែលអាចនាំទៅដល់ទីផ្សារពលកម្មដោយផ្ទាល់ និង/ឬ ឧត្ដមសិក្សា។ តាមរបៀបឬវិធីនេះ សិង្ហបុរីបានកែលំអសមធម៌ក្នុងលទ្ធផលអប់រំ និងលើកកម្ពស់កម្រិតស្តង់ដាជាទូទៅ។

ប្រទេសកាណាដា ឥណ្ឌូនេស៊ី កូរ៉េខាងត្បូង និង ហ្សាម៉ាអ៊ីក បានអនុម័តប្រើប្រព័ន្ធមធ្យមសិក្សាវិជ្ជាជីវៈ តាមគំរូសហរដ្ឋអាមេរិក។ អ្នកចេញពីសាលាដោយគ្មានគុណវុឌ្ឍិ អាចរៀនវគ្គពីរឆ្នាំយកសញ្ញាប័ត្របរិញ្ញាបត្ររង ដើម្បីអាចចូលរៀននៅសាកលវិទ្យាល័យ ហើយនិស្សិតត្រូវរៀនពីរឆ្នាំថែមទៀត ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ។ សម្រាប់និស្សិតដែលមានគុណវុឌ្ឍិប្លែកពីធម្មតា ផ្លូវឈានទៅមុខ និងការរៀបចំដែលជួយសម្រួលដល់ការបត់បែន ឬវឌ្ឍនភាព គឺសំខាន់បំផុត។ ការអប់រំ ឬការបណ្ដុះបណ្ដាលរយៈពេលវែងពីមុន និងគុណវុឌ្ឍិដែលជាប់ទាក់ទង អនុញ្ញាតឲ្យនិស្សិតទាំងនោះអាចពង្រឹងនិងបង្កើនប្រសិទ្ធភាព និងសមត្ថភាពរបស់ខ្លួន មុននឹងចាប់ផ្ដើមរៀនយកសញ្ញាប័ត្ររបស់សាកលវិទ្យាល័យ។ ចំណុចសំខាន់មួយទៀតគឺ មិនមែននិស្សិតទាំងអស់ សុទ្ធតែបានត្រៀមខ្លួនស្រេចតាំងពីដើមទី ដើម្បីរៀនវគ្គពេញលេញបួនឆ្នាំយកសញ្ញាប័ត្រនោះទេ ដូច្នេះឱកាសរៀនយកសញ្ញាប័ត្រកម្រិតមធ្យម ឬបរិញ្ញាបត្ររង អាចជួយរក្សាទុកនិស្សិតឲ្យនៅបន្តការសិក្សា (Field and Guez 2018)។ ប៉ុន្តែគ្រឹះស្ថានឧត្ដមសិក្សាមួយចំនួនរារែកក្នុងការទទួលស្គាល់គុណវុឌ្ឍិមានពីមុន ហើយទាមទារឲ្យនិស្សិត ដែលចង់បន្តការសិក្សាយកសញ្ញាប័ត្រកម្រិតសាកលវិទ្យាល័យ ត្រូវចាប់រៀនតាំងពីដើមវគ្គ។

នៅប្រទេស ឡាត់វីយ៉ា និង អេស្តូនី និស្សិតដែលរៀនចប់វគ្គ VET រយៈពេលពីរឆ្នាំ មិនមែនសុទ្ធតែមានសិទ្ធិចូលរៀនដោយផ្ទាល់ និងជាស្វ័យប្រវត្តិ ក្នុងវគ្គយកសញ្ញាប័ត្រនោះទេ (OECD 2016) ដោយហេតុថា មិនមែនវគ្គ VET ទាំងអស់ សុទ្ធតែមានលក្ខណៈគ្រប់គ្រាន់ជា គុណវុឌ្ឍិសម្រាប់ចូលរៀននៅសាកលវិទ្យាល័យនោះឡើយ ពីព្រោះគុណវុឌ្ឍិសម្រាប់ចូលរៀន ត្រូវផ្អែកលើវគ្គដែលនិស្សិតបានរៀនចប់ បើមិនដូច្នោះទេ និស្សិតត្រូវរៀនវគ្គបន្ថែមខ្លះទៀត ដើម្បីត្រៀមខ្លួនចូលរៀននៅឧត្ដមសិក្សា។

ការយកការឆ្លងចូលគ្នាមកប្រើជាឈ្នាន់ វាពិបាកយល់បន្តិច ហើយការអនុវត្តគោលនយោបាយមិនមានស្ថិរភាព និងមិនទាន់ស៊ីគ្នា គឺកំពុងមានការពិភាក្សាយ៉ាងទូលំទូលាយក្នុងចំណោមអ្នកអនុវត្តជាក់ស្ដែង។ គោលនយោបាយដូចជា ការផ្ទេរក្រេឌីត (ពិន្ទុ

តាមមុខវិជ្ជា) របៀបរបបមានការបត់បែន និង ការទទួលស្គាល់ការរៀនសូត្រពីមុន ត្រូវបានអនុម័តរួចហើយ ប៉ុន្តែផ្លូវបន្តពី VET ទៅឧត្តមសិក្សា នៅតែលំបាកស្មុគស្មាញដោយសារមានរបាំងស្ថាប័នជាច្រើន។ ចំណុចសំខាន់មួយទៀតគឺ កម្មវិធីសិក្សា VET ផ្តោតលើជំនាញវិជ្ជាជីវៈជាក់លាក់ ដែលខុសពីកម្មវិធីសិក្សានៅឧត្តមសិក្សា ហើយបញ្ហានេះកាត់បន្ថយឱកាសឈានទៀងសម្រាប់អ្នកចូលរៀន VET (Field 2017)។

## VET នៅកម្រិតគុណវុឌ្ឍិខ្ពស់ៗ

តាំងពីដើមរៀងមក VET ត្រូវបានផ្តល់ក្នុងទម្រង់ជាវគ្គខ្លីៗ និងនៅកម្រិតមធ្យមសិក្សា។ ដោយសារ VET កាន់តែមានសារៈសំខាន់សម្រាប់ការកសាងសមត្ថភាពធនធានមនុស្ស ក្នុងការពិភាក្សាអភិវឌ្ឍនៅអឺរ៉ុប គេបានយកចិត្តទុកដាក់កាន់តែខ្លាំងលើការដាក់បញ្ចូល VET នៅក្រោយមធ្យមសិក្សា ដើម្បីតភ្ជាប់ទិដ្ឋភាពខុសៗគ្នានៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលផ្សេងៗ។ ប៉ុន្តែយើងពុំទាន់ឃើញនិយមន័យស្តង់ដាណាមួយ សម្រាប់ពន្យល់ពាក្យ VET កម្រិតខ្ពស់/ឧត្តមសិក្សា ដោយមានការបកស្រាយខុសគ្នានៅតាមប្រទេសអឺរ៉ុបខុសៗគ្នា។ Cedefop (2014, 292) បានកំណត់និយមន័យ VET ថាជា "ការអប់រំ និងការបណ្តុះបណ្តាលដែលមានគោលបំណងបំពាក់ចំណេះដឹង ចំណេះធ្វើ ជំនាញ និង/ឬសមត្ថភាព ដែលទាមទារក្នុងមុខរបរជាក់លាក់ ឬក៏ក្នុងន័យទូលាយ នៅក្នុងទីផ្សារពលកម្ម"។

បន្ថែមលើការដោះស្រាយជាមួយភាពផ្សេងៗគ្នាលើគំនិត និងរចនាសម្ព័ន្ធស្ថាប័ន និយមន័យខាងលើនេះ អាចប្រើជាឧបករណ៍ដ៏សំខាន់សម្រាប់ញែកស្រទាប់នៃ វិសាលភាព VET កម្រិតខ្ពស់ និងបទបញ្ញត្តិ ដែលយកមកគ្រប់គ្រងប្រព័ន្ធនេះបាន។ ផ្អែកលើចំណាត់ថ្នាក់ស្តង់ដាអន្តរជាតិនៃការអប់រំ (ISCED) ឧត្តមសិក្សា VET មានបួនកម្រិតអប់រំ ចាប់ទី៥ ដល់ ទី៨ ដែលសមមូលនឹងការអប់រំក្រោយមធ្យមសិក្សាវគ្គខ្លី បរិញ្ញាប័ត្រ ថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិត (UNESCO 2011)។ គោលដៅចម្បងនៃគុណវុឌ្ឍិ VET កម្រិតខ្ពស់ គឺជួយរៀបចំនិស្សិតបញ្ចប់ការសិក្សា VET ឲ្យត្រៀមខ្លួនបានស្រេចដើម្បីក្លាយជាកម្លាំងពលកម្ម ដោយផ្តោតលើឧស្សាហកម្មវិជ្ជាជីវៈជាក់លាក់ និងបើកផ្លូវសម្រាប់អ្នកដែលប្រាថ្នាចង់បន្តការសិក្សាថ្នាក់ឧត្តម។ ដើម្បីធានាឲ្យអ្នករៀន VET ទទួលបានការអប់រំល្អ កម្មវិធី VET កម្រិតខ្ពស់ជាទូទៅអាចសំគាល់បានតាមការគួបផ្សំបន្សុីគ្នានូវ ទិដ្ឋភាពផ្សេងៗខាងវិជ្ជាជីវៈ និងខាងសិក្សាអប់រំ ដោយឲ្យទម្ងន់ខ្លាំងជាងទៅខាងវិជ្ជាជីវៈ (Cedefop 2011)។

ការបន្ថែមកម្រិតគុណវឌ្ឍិខ្ពស់នៅក្នុងក្របខ័ណ្ឌ VET នៅអូស្ត្រាលី មានគោលដៅដោះស្រាយតម្រូវការនិងកង្វះខាតបុគ្គលមានសមត្ថភាពខ្ពស់ៗ ដើម្បីជំរុញកំណើន និងផលិតភាពនៃសេដ្ឋកិច្ចរបស់ប្រទេសជាតិ។ រដ្ឋាភិបាលអូស្ត្រាលី បានដាក់បញ្ចូលកម្រិតខ្ពស់ពីរក្នុងវិស័យ VET ពោលគឺ វិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាប័ត្រវិជ្ជាជីវៈ។ គុណវុឌ្ឍិទាំងពីរត្រូវបានរចនារៀបចំឡើងដើម្បីតភ្ជាប់គ្នារវាង VET នឹងឧត្តមសិក្សា និងមានកម្រិតខ្ពស់ជាងបរិញ្ញាប័ត្រ (ISCED level 6) ប៉ុន្តែទាបជាងសញ្ញាប័ត្រអនុបណ្ឌិត (ISCED level 7)។ ថ្វីបើខុសគ្នាពី NQFs របស់ប្រទេសឯទៀត ប៉ុន្តែគុណវុឌ្ឍិកម្រិតខ្ពស់ទាំងនេះ បានផ្តល់ផ្លូវកាន់តែអាចបត់បែនសម្រាប់អ្នករៀនសូត្រ ដើម្បីចូលទៅក្នុងពិភពការងារ និង/ឬ បន្តការសិក្សាថែមទៀត (Langworthy and Johns 2012)។

គួរបញ្ជាក់ដែរថា គេអាចសង្កេតឃើញបទពិសោធន៍វិជ្ជមានជាច្រើននៅក្នុងប្រទេសអឺរ៉ុបផ្សេងៗ ដោយសារមានការពង្រីកគុណវុឌ្ឍិ VET កម្រិតខ្ពស់។ ឧទាហរណ៍ ប្រទេសស៊ុយអែតបានពង្រីកកម្មវិធីវិជ្ជាជីវៈរបស់ខ្លួន ដល់ ISCED កម្រិត ៧ ដែលសមមូលនឹងសញ្ញាប័ត្រអនុបណ្ឌិត ហើយទាក់ទាញបានអ្នករៀន VET ៥០,០០០នាក់ ក្នុងឆ្នាំ២០១៧ (Skolverket 2019)។ នៅតាមប្រទេសអឺរ៉ុបឯទៀត ដូចជា អូទ្រីស បែលហ្ស៊ិក អាឡឺម៉ង់ ដាណឺម៉ាក អេស្ប៉ាញ ហ្វាំងឡង់ បារាំង អៀរឡង់ ហូឡង់ ព័រទុយហ្គាល់ ជាដើម ក៏មាននិន្នាការដូចគ្នា ដោយបានបន្ថែមកម្រិតខ្ពស់ៗក្នុងវិស័យ VET ដែរ (Ulicna, Luomi-Messerer and Auzinger 2016)។ ច្រករៀនសូត្របត់បែនបាន និងវិធីបង្រៀននៅក្នុង VET កម្រិតខ្ពស់ ជួយឲ្យអ្នករៀនសូត្រអាចបន្តប្រឹងប្រែងយកបរិញ្ញាប័ត្រផ្តោតលើការអនុវត្ត និងការអប់រំវិជ្ជាជីវៈកម្រិតឧត្តមនៅតាមសាកលវិទ្យាល័យវិទ្យាសាស្ត្រអនុវត្តន៍ ដែលនៅទីនោះវគ្គសិក្សា ដូចជាខាង វេជ្ជសាស្ត្រ ច្បាប់ ឬ វិស្វកម្ម/បច្ចេកវិទ្យាមានការសង្កត់ធ្ងន់ខ្លាំង លើទិដ្ឋភាពផ្តោតលើការអនុវត្ត។ នៅអាស៊ីអាគ្នេយ៍ ថៃបានកំណត់ប្រព័ន្ធ VET មានបីកម្រិត (ក្នុងនោះមានពីរជាកម្រិតឧត្តម ដែលសមមូលនឹង ISCED កម្រិត ៥ និង ៦) និងសេចក្តីណែនាំយ៉ាងតឹងរ៉ឹងផ្សេងៗ ដើម្បីជួយសម្រួលលំហូរនិស្សិត និងធានាឲ្យមានការរៀនសូត្រពេញមួយជីវិត (Department of Education Skills and Employment 2020)។ ដូច្នេះ ការអភិវឌ្ឍផ្លូវរៀនសូត្រអាចបត់បែននៅក្នុង VET កម្រិតឧត្តម គេគិតថាជាការចាំបាច់ ព្រោះវាអាចជួយលុបបំបាត់បានល្អនូវរបាំងផ្សេងៗ ដែលរារាំងយុវជនក្នុងការសម្រេចបានតាមសក្តានុពលរបស់ខ្លួន។ របាំងទាំងនេះ រួមមាន ការខណ្ឌដាច់គ្នានូវ ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល, ការយល់ខុសថា VET ជាផ្លូវទាល់, ការពុំមានលក្ខណៈឯកភាពគ្នាដែលរារាំង ការរីកចម្រើន និងជំហានធំៗ ដើម្បីកែលំអលទ្ធផលរបស់អ្នកបានរៀនចប់។

## របៀបរបបសហការ និងភាពជាដៃគូអន្តរស្ថាប័ន (ការផ្ទេរក្រេឌីត)

មានការទទួលស្គាល់ជាយូរមកហើយថា កិច្ចប្រឹងប្រែងជាប់លាប់ និងខ្លាំងក្លា របស់រដ្ឋាភិបាលជាច្រើន (ដូចជាក្នុង របៀបរបបសម្រាប់ផ្ទេរ និង ប្រព័ន្ធសន្សំក្រេឌីត ជាដើម) ដើម្បីជំរុញការតភ្ជាប់កាន់តែខ្លាំងរវាង VET នឹងអ្នកផ្តល់ការអប់រំសិក្សាធិការ គឺជាដំណោះស្រាយមួយ សម្រាប់ឲ្យមានការឆ្លងចូលគ្នា។ ការចូលគ្នារួមសកម្មពីសំណាក់អ្នកពាក់ព័ន្ធច្រើនប្រភេទ ដូចជា អ្នករៀនសូត្រ ស្ថាប័នអប់រំ និងបណ្តុះបណ្តាល បុគ្គលិកបង្រៀននិងអ្នកបណ្តុះបណ្តាល និងនិយោជិតនានា ដែលប្រឹងប្រែងរួមគ្នាគឺសំខាន់បំផុតសម្រាប់ជោគជ័យនៃការធ្វើអន្តរកាល (Pollard et al. 2017)។ ការទទួលស្គាល់ការរៀនសូត្រពីមុន រវាងច្រក

ឧត្តមសិក្សា នឹងច្រកបណ្តុះបណ្តាល គឺជាការព្យាយាមដើម្បីបំបាត់ភាពខុសប្លែកគ្នា និងសម្រួលបន្សុីលក្ខណៈដូចគ្នា ក្នុងខ្លឹមសារនៃវគ្គសិក្សា និងវិធីសាស្ត្របង្រៀន និងរៀនសូត្រ។ វិធីនេះជួយដល់និស្សិត ទោះបីមានប្រវត្តិសិក្សាបែបណាក្តី ឲ្យមានឱកាសបន្តការរៀនសូត្រកម្រិតខ្ពស់ ដោយពុំចាំបាច់រៀនឡើងវិញនូវចំណេះដឹងដែលខ្លួនបានទទួលរួចហើយ។

ក្នុងគោលដៅបង្កើន សមាមាត្រនិស្សិតមានសញ្ញាប័ត្រ VET ដែលទៅសិក្សានៅតាមស្ថាប័នឧត្តមសិក្សា រដ្ឋាភិបាលអូស្ត្រាលីបានផ្តួចផ្តើមបង្កើតកម្មវិធីកម្ចីសម្រាប់ថ្លៃ VET និងថ្លៃឧត្តមសិក្សា។ គំនិតផ្តួចផ្តើមនេះបានបង្កើតបរិយាកាសដ៏មានសន្ទុះមួយ ដោយលើកទឹកចិត្តសាកលវិទ្យាល័យ និងស្ថាប័ន VET នានា ឲ្យរួមសហការ ឬបង្កើតភាពជាដៃគូ ដើម្បីសម្រួលឲ្យមានអន្តរកាលយ៉ាងរលូនពី VET ទៅឧត្តមសិក្សា តាមរយៈការផ្ទេរក្រេឌីត និងរបៀបរបបអាចបត់បែន ពីព្រោះដំណើរការផ្ទេរ អាចជាបទពិសោធន៍យ៉ាងពិបាកមួយសម្រាប់និស្សិត (Smith and Brennan-Kemmis 2014)។ ឧទាហរណ៍មួយទៀត គឺនៅប្រទេសតាហ្សុីគីស្ថាន និស្សិតដែលរៀនចប់កម្មវិធីរយៈពេលពីរឆ្នាំនៅក្នុងសាលាបច្ចេកទេស អាចផ្ទេរដោយផ្ទាល់ចូលទៅឆ្នាំទី៣នៃកម្មវិធីរៀនយកបរិញ្ញាប័ត្រ ក្នុងសាកលវិទ្យាល័យដៃគូណាមួយ (Marope, Chakroun and Holmes 2015)។ វិធីនេះស្រដៀងគ្នានឹងប្រព័ន្ធផ្ទេរក្រេឌីតនានារបស់អូស្ត្រាលីដែរ ដែលអនុញ្ញាតឲ្យនិស្សិត VET បន្តការសិក្សានៅសាកលវិទ្យាល័យតាមរយៈប្រព័ន្ធផ្ទេរក្រេឌីត (Langworthy and Johns 2012) ។

ជាគោលការណ៍ របៀបរបបផ្សេងៗ អាចធ្វើឲ្យឈ្នាន់ចេញពីច្រកវិជ្ជាជីវៈ ទៅកាន់ច្រកអប់រំសិក្សាធិការ ហាក់ដូចជាគ្មានស្មុគស្មាញអ្វី និងរលូនល្អណាស់។ ប៉ុន្តែក្នុងការពិតជាក់ស្តែង បើតាមសំដីរបស់ Harris, Rainey and Sumner (2006) គឺវាដូចជា "ផ្លូវក្រាលផ្ទាំងថ្មរកេតរកូត" ពីព្រោះប្រព័ន្ធនេះស្មុគស្មាញ និងមិនសុីគ្នាទេ ជាពិសេស គោលនយោបាយ និងការអនុវត្តជាក់ស្តែង ប្រែប្រួលខុសគ្នារវាងស្ថាប័ននានា ហើយរបៀបរបបផ្ទេរនៅមានលក្ខណៈចំពោះកិច្ច (ad hoc) មិនមែនជាប្រព័ន្ធនោះទេ (Bandias, Fuller and Pfitzner 2011)។ ការសិក្សាមួយទៀតធ្វើឡើងដោយ Ambrose et al. (2013) បានផ្តល់គំនិតថា ការពុំមានលក្ខណៈឯកភាពគ្នា និងភាពមិនគ្រប់គ្រាន់នៃមុខវិជ្ជាផ្នែកសិក្សាអប់រំនៅក្នុងកម្មវិធី VET នានា និងភាពខុសប្លែកគ្នាក្នុងវិធីសាស្ត្របង្រៀននិងរៀនសូត្រ រវាងស្ថាប័ន VET នឹងសាកលវិទ្យាល័យ វាជាកត្តាចម្បងរារាំងរបៀបរបប និងភាពជាដៃគូសម្រាប់ការធ្វើអន្តរកាលបានល្អ។ បុគ្គលិកសាកលវិទ្យាល័យខ្លះមានអារម្មណ៍ថែមទៀតថា ប្រព័ន្ធក្រេឌីត "បានគំរាមកំហែងដល់ភាពពេញលេញនៃវគ្គសិក្សា និងស្តង់ដាទូទៅរបស់សាកលវិទ្យាល័យខ្លួន" (Bandias, Fuller and Pfitzner 2011, 587)។

## សេចក្តីសន្និដ្ឋាន

ឯកសារនេះបានរកឃើញយុទ្ធសាស្ត្រជាច្រើន ដែលអាចជួយបង្កើតច្រកសម្រាប់ការឆ្លងចូលគ្នា បានកាន់តែប្រសើររវាងប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រព័ន្ធអប់រំសិក្សាធិការ។ សម្រាប់ផ្លូវទៅកាន់ការឆ្លងចូលគ្នានេះ ការសិក្សាក៏មានគូសរំលេចនូវបញ្ហាប្រឈមជាច្រើន ដូចជា ភាពខុសគ្នារវាងប្រព័ន្ធទាំងពីរ និងភាពស្មុគស្មាញក្នុងការផ្ទេរពីការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅកាន់ការអប់រំសិក្សាធិការនៅឧត្តមសិក្សា ជាដើម។ កម្ពុជាក៏បានដាក់បញ្ចូលច្រកចម្លងមានប្រសិទ្ធភាពល្អមួយចំនួន លុបបំបាត់របាំងរារាំងនានា ដើម្បីឲ្យនិស្សិតកាន់តែមានសេរីភាពក្នុងការឆ្លងប្រព័ន្ធទាំងពីរ។ ផ្លូវទាំងនេះ មានជាអាទិ៍ ការបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ក្នុងឆ្នាំ២០១២ ដែលជួយកសាងច្រកចម្លងរវាងប្រព័ន្ធទាំងពីរ ដែលមានភាពបត់បែនផ្សេងៗ និងការដាក់អនុវត្តគុណវុឌ្ឍិ VET (នៅកម្ពុជា ហៅថា ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ [TVET]) កម្រិតខ្ពស់។

តាមទ្រឹស្តី ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ផ្តល់ឱកាសឲ្យនិស្សិតប្រើប្រាស់ TVET ជាឈ្នាន់មួយដើម្បីបន្តការរៀនសូត្រទៅថ្នាក់ឧត្តមសិក្សានៅតាមសាកលវិទ្យាល័យ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង និស្សិតកម្រដើរតាមផ្លូវមួយនេះណាស់។ និស្សិត TVET ភាគច្រើនតែងជ្រើសបន្តការសិក្សានៅតាមវិទ្យាស្ថាន TVET ដែលមានផ្តល់គុណវុឌ្ឍិកម្រិតខ្ពស់។ ក្នុងចំណុចនេះ កម្ពុជាអាចយកគំនិតផ្តួចផ្តើមផ្សេងៗ ដែលមានអនុវត្តនៅប្រទេសឯទៀត ដូចជា ការជំរុញកិច្ចសហការរវាងសាកលវិទ្យាល័យ និងគ្រឹះស្ថាន TVET ក្នុងការធ្វើពិពិធកម្មច្រកចម្លង សម្រាប់និស្សិត ដើម្បីធានាថានិស្សិតអាចផ្ទេរឆ្លងប្រព័ន្ធដោយគ្មានឧបសគ្គ។

## សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះ ជាចំណែកមួយនៃគម្រោងស្រាវជ្រាវរយៈពេល ៣,៥ឆ្នាំ របស់ CDRI ស្តីពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) នៅកម្ពុជា។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC) ដែលបានផ្តល់មូលនិធិដល់គម្រោងនេះ។

## ឯកសារយោង

Agrawal, Tushar. 2013. "Vocational Education and Training Programs (VET): An Asian Perspective." *Asia-Pacific Journal of Cooperative Education* 14 (1): 15–26.

Ambrose, Iris, Marie Bonne, Kate Chanock, Clare Cunnington, Sandra Jardine and Janet Muller. 2013. "'Like Catching Smoke': Easing the Transition from TAFE to University." *Journal of Academic Language and Learning* 7 (2): A120–A131.

Backes-Gellner, Uschi, and Simone N. Tuor. 2010. *Avoiding Labor Shortages by Employer Signaling: On the Importance of Good Work Climate and Labor Relations*. Working Paper No. 10. Zürich: Universität Zürich.

Bandias, Susan, Don Fuller and Darius Pfitzner. 2011. "Vocational and Higher Education in Australia:

A Need for Closer Collaboration." *Journal of Higher Education Policy and Management* 33 (6): 583–94.

Cedefop (European Centre for the Development of Vocational Training). 2011. *Vocational Education and Training at Higher Qualification Levels*. Research Paper No. 15. Luxembourg: Cedefop.

Cedefop. 2012. "Permeable Education and Training Systems: Reducing Barriers and Increasing Opportunity." Briefing Note. Thessaloniki: Cedefop.

Cedefop. 2014. *Terminology of European Education and Training Policy*. Second Edition. Luxembourg: European Union.

Cedefop. 2015. *Analysis and Overview of National Qualifications Framework Developments in European Countries: Annual Report 2014*. Working Paper No. 27. Luxembourg: European Union.

Department of Education Skills and Employment, Australian Government. 2020. "Thailand: Vocational Education and Training." https://internationaleducation.gov.au/International-network/thailand/Policy Updates-Thailand/Documents/Thailand%20Education%20Policy%20Update_VET_ FINAL.pdf.

Elken, Mari. 2016. "'EU-on-Demand': Developing National Qualifications Frameworks in a Multi-Level Context." *European Educational Research Journal* 15 (6): 628–43.

Field, Simon. 2017. "Virtual Conference Report on Pathways between TVET and Further Education." Bonn: UNESCO-UNEVOC.

Field, Simon, and Ava Guez. 2018. *Pathways of Progression: Linking Technical and Vocational Education and Training with Post-Secondary Education*. Paris: UNESCO.

Harris, Roger, Linda Rainey and Robert Sumner. 2006. "Crazy Paving or Stepping Stones? Learning Pathways within and between Vocational Education and Training and Higher Education." Adelaide: National Centre for Vocational Education Research.

Hoffman, Nancy, and Robert Schwartz. 2015. "Gold Standard: The Swiss Vocational Education and Training System." Washington, DC: National Center on Education and the Economy.

Langworthy, Anne, and Susan Johns. 2012. "Why Is It Important for Higher Education to Connect with the VET Sector?" *Research and Development in Higher Education* 35: 118–28.

Lester, Stan. 2015. "The European Qualifications Framework: A Technical Critique." *Research in Post-Compulsory Education* 20 (2): 159–72.

Marope, Priscilla Toka Mmantsetsa, Borhene Chakroun and K.P Holmes. 2015. *Unleashing the Potential Transforming Technical and Vocational Education and Training*. Paris: UNESCO.

OECD (Organisation for Economic Co-operation and Development). 2016. "Education in Latvia, Reviews of National Policies for Education." Paris: OECD Publishing.

Pollard, Emma, Kari Hadjivassiliou, Sam Swift and Martha Green. 2017. *Credit Transfer in Higher Education: A Review of the Literature*. Manchester: Department for Education.

Skolverket, ReferNet Sweden. 2019. *Vocational Education and Training in Europe- Sweden*. http://libserver.cedefop.europa.eu/vetelib/2019/Vocational_Education_Training_Europe_Sweden_2018_Cedefop_ReferNet.pdf.

Smith, Erica, and Ros Brennan-Kemmis. 2014. "Credit Transfer from VET to Higher Education: A Pathways Policy Meets a Roadblock." *Research in Post-Compulsory Education* 19 (2): 230–44.

Spöttl, Georg. 2013. "Permeability between VET and Higher Education -–A Way of Human Resource Development." *European Journal of Training and Development* 37 (5): 454–71.

Ulicna, Daniela, Karin Luomi-Messerer and Monika Auzinger. 2016. "Study on Higher Vocational Education and Training in the EU." Brussels: European Commission.

UNESCO (United Nations Educational, Scientific and Cultural Organization). 2011. *International Standard Classification of Education: ISCED 2011*. Montreal: UNESCO Institute for Statistics.

UNESCO. 2015. *Global Inventory of Regional and National Qualifications Frameworks, Volume 1: Thematic Chapters*. Hamburg: UNESCO Institute for Lifelong Learning.

World Bank. 2019. *World Development Report 2019: The Changing Nature of Work*. Washington, DC: World Bank.

# ការសិក្សាប្រៀបធៀបលើការអនុវត្តការទូត ក្នុងការគ្រប់គ្រងទឹក ផ្ដោតលើទន្លេអ៊ីនឌុស និងទន្លេមេគង្គ

## សេចក្ដីផ្ដើម

ទឹកជាចំណែកដ៏ចាំបាច់មួយនៃជីវិត ក្នុងការជួយទ្រទ្រង់ជីវភាពវិបុលភាព និងស្ថិរភាពសង្គម ក្នុងទូទាំងពិភពលោក។ សារៈសំខាន់ចាំបាច់នៃទឹក ក៏មានចែងច្បាស់ក្នុងគោលដៅទី៦ ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទាំង៨ ដែលផ្ដោតលើការទទួលបានទឹកប្រើប្រាស់ប្រកបដោយសមធម៌ និងការគ្រប់គ្រងទឹកប្រកបដោយចីរភាព (SDG 2015-2030)។ ដើម្បីសម្រេចបាននូវគោលដៅទី៦ នៃ SDG នេះ ត្រូវមានសហប្រតិបត្តិការ លើបញ្ហាទឹកដែលឆ្លងកាត់ព្រំដែន ដូចមានចែងក្នុងអនុគោលដៅទី៦.៥។ ប៉ុន្តែ ដោយសារមានបញ្ហាប្រឈមដូចជា កំណើនបញ្ហាកង្វះទឹក និងការគ្រប់គ្រងទឹកមិនបានត្រឹមត្រូវ ជម្លោះក្នុងបញ្ហាទឹកដែលឆ្លងកាត់ព្រំដែន អាចបង្កភាពរីករវក្នុងសង្គម និងបង្កើតជាទំនាស់។ របាយការណ៍ស្ដីពីការអភិវឌ្ឍទឹកនៅអាស៊ីឆ្នាំ២០១៣ (Asian Water Development Outlook 2013) បានរកឃើញថា សន្តិសុខនៃការគ្រប់គ្រងទឹកក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក កំពុងប្រឈមនឹងការគំរាមកំហែងនៃជម្លោះស្ដីពីតម្រូវការធនធានទឹក សំពាធប្រជាសាស្ត្រ ឧស្សាហូបនីយកម្ម នគរូបនីយកម្ម និងការប្រែប្រួលអាកាសធាតុ ហើយទំនាស់ទាំងនេះ ទំនងអាចបង្កើនភាពតានតឹងដល់បណ្ដាប្រទេសនៅតាមដងទន្លេ (ADB 2013)។

អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក Kofi Annan បានលើកឡើងថា "ការប្រកួតប្រជែងដ៏តឹងតែងរវាងបណ្ដាប្រទេសលើបញ្ហាធនធានទឹក បង្កើតនូវការព្រួយបារម្ភពីលទ្ធភាពអាចមានជម្លោះឃោរឃៅ" (United Nations 2020)។ ទំនាស់ទាក់ទងនឹងធនធានទឹក បានក្លាយជាបញ្ហាដ៏ស្មុគស្មាញ ដែលអាចប៉ះពាល់ដល់សន្តិសុខអន្តរជាតិ ហើយដែលត្រូវបានដាក់ចូលក្នុងបញ្ជីហានិភ័យសកលកំពូលៗទាំងប្រាំ (World Economic Forum 2020)។ ការស្រាវជ្រាវបានបង្ហាញថា ជាទូទៅទំនាស់លើធនធានទឹក កើតឡើងនៅតាមបណ្ដាប្រទេសមានព្រំដែនទឹកជាមួយគ្នា (Molen and Hildering 2005; Petersen-Perlman, Veilleux and Wolf 2017; Gholizadeh and Niknami 2020)។ វិវាទទាំងនោះបានផ្ទុះឡើងនៅតាមដងទន្លេដូចជា៖ ទន្លេនីល អ៊ីនឌុស និង មេគង្គ ក៏ដូចជានៅតាមដងទន្លេជាច្រើនទៀត។ អត្ថបទនេះធ្វើការសិក្សា និងប្រៀបធៀប មូលហេតុដែលបង្កឲ្យមានទំនាស់លើធនធានទឹក និងពិនិត្យពីយន្តការប្រើប្រាស់ សម្រាប់ដោះស្រាយទំនាស់នៅអាងទន្លេអ៊ីនឌុស និងមេគង្គ។

អត្ថបទនេះរៀបរៀងដោយ ផុន សុក្របញ្ញា, ជាទីប្រឹក្សា នៃវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង រស់ សយម្ភូ ជានិស្សិតបញ្ចប់ថ្នាក់អនុបណ្ឌិត ជំនាញច្បាប់អន្តរជាតិ នៃសាកលវិទ្យាល័យ Sussex និងជានិស្សិតថ្នាក់អនុបណ្ឌិត ជំនាញសន្តិសុខអន្តរជាតិ ទំនាស់ និងការអភិវឌ្ឍអន្តរជាតិ នៃសាកលវិទ្យាល័យ Leicester។ សូមយោងអត្ថបទនេះថា៖ Phon Sokpanya and Ros Sayumphu. 2020. “Comparative Study on the Implementation of Water Diplomacy: Focusing on the Indus and Mekong Rivers.” *Cambodia Development Review* 24 (3): 7–12.

## ទិដ្ឋភាពទូទៅនៃទន្លេអ៊ីនឌុស និងមេគង្គ

### *ទន្លេអ៊ីនឌុស*

ទន្លេអ៊ីនឌុស ដែលជួយទ្រទ្រង់ប្រជាជន ប្រមាណ ២១៥លាននាក់ ជាទន្លេវែងជាងគេលំដាប់ទី៨ ក្នុងពិភពលោក។ ទន្លេនេះមានប្រភពចេញពីភ្នំហិម៉ាល័យ ក្នុងតំបន់ខ្ពង់រាបទីបេខាងលិច ហើយមួយផ្នែកធំនៃទឹកទន្លេហូរកាត់តំបន់ Jammu និង Kashmir នៅភាគពាយព្យនៃអនុទ្វីបឥណ្ឌា។ ទន្លេអ៊ីនឌុស និងដៃទន្លេនានារបស់វា សំខាន់ជាខ្លាំងសម្រាប់ប្រទេសប៉ាគីស្ថាន និងឥណ្ឌា ព្រោះវាជាប្រភពទឹកដ៏ចម្បង សម្រាប់ផ្គត់ផ្គង់វិស័យកសិកម្មក្នុងប្រទេស។ ប៉ុន្តែដោយសារប្រជាជនប៉ាគីស្ថានប្រមាណជាង ៧០% ពឹងអាស្រ័យដោយផ្ទាល់ ឬដោយប្រយោលលើវិស័យកសិកម្ម ទន្លេអ៊ីនឌុស មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនប៉ាគីស្ថាន (Abbashi et al. 2019)។

ទំនាស់រវាងឥណ្ឌា នឹងប៉ាគីស្ថាន លើធនធានទឹកនៅអាងទន្លេអ៊ីនឌុស មិនមែនជាជម្លោះថ្មីនោះទេ ព្រោះវាបានចាប់ផ្ដើមតាំងពីឆ្នាំ១៩៤៧ ក្រោយពេលមានការបែងចែកអនុទ្វីបឥណ្ឌាជាប្រទេសឯករាជ្យពីរ គឺ ឥណ្ឌា និង ប៉ាគីស្ថាន ហើយបានតានតឹងកាន់តែខ្លាំងឡើងទៀត ចាប់តាំងពីពេលនោះមក។ ទំនាស់លើធនធានទឹកក្នុងអាងទន្លេអ៊ីនឌុស អាចបណ្ដាលមកពីកត្តាមួយចំនួន។ ទី១ គឺកត្តាជម្លោះទឹកដី ដែលកំពុងបន្តកើតមានក្នុងតំបន់ Kashmir

រូបភាព១៖ ផែនទីអាងទន្លេអ៊ីនឌុស




ប្រភព៖ Zawahri 2008

ហើយបានធ្វើឲ្យទំនាក់ទំនងឥណ្ឌា-ប៉ាគីស្ថាន មានភាពល្អក់កករ និងបានបង្អាក់ សហប្រតិបត្តិការរវាងប្រទេសទាំងពីរ (Haq and Sofi 2019; Qureshi 2017a)។ ទី២ កំណើនបទឧក្រិដ្ឋភេរវកម្មនៅឥណ្ឌា បានធ្វើឲ្យទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ កាន់តែដុនដាបឡើង ជាពិសេសក្រោយពេលមានការវាយប្រហារនៅក្រុង Mumbai ក្នុងឆ្នាំ២០០៨ ដែលឥណ្ឌាបានចោទថា រដ្ឋាភិបាលប៉ាគីស្ថានជាអ្នកនៅពីក្រោយអំពើភេរវកម្ម ហើយប៉ាគីស្ថាន បានបដិសេធទាំងស្រុងនូវការចោទប្រកាន់នេះ (Parashar 2020)។ ទី៣ មូលហេតុដែលទំនងជាមានសំពាធខ្លាំងនោះ គឺការអះអាងរបស់ប៉ាគីស្ថានថា ឥណ្ឌាដែលនៅខ្សែទឹកខាងលើ គិតតែពីផលប្រយោជន៍របស់ខ្លួន ដោយបានគ្រួតត្រាលំហូរទឹកទន្លេ និងធ្វើឲ្យរាំងស្ទះដល់ចង្វាក់ផលិតកម្មកសិកម្ម និងប៉ះពាល់ដល់ការរស់នៅ និងជីវភាពរបស់ប្រជាជនប៉ាគីស្ថាន។

### ទន្លេមេគង្គ

ទន្លេមេគង្គ ជាទន្លេវែងជាងគេលំដាប់ទី១២ ក្នុងពិភពលោក។ ទន្លេនេះហូរចេញពីខ្ពង់រាបទីបេ រហូតដល់ដីសណ្តទន្លេមេគង្គ ដោយឆ្លងកាត់ ៦ប្រទេសគឺ ចិន មីយ៉ាន់ម៉ា ឡាវ ថៃ កម្ពុជា និងវៀតណាម។ អាងទន្លេមេគង្គស្ថិតក្នុងចំណោមអាងធំជាងគេ និងមានជីវចម្រុះច្រើនជាងគេនៅអាស៊ីអាគ្នេយ៍ ដែលបានផ្តល់ជាប្រភពជួយចិញ្ចឹមជីវិតប្រជាជនប្រមាណជាង ៦០លាននាក់។ ក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ បណ្តាប្រទេសតាមដងទន្លេបានទាញយកអត្ថប្រយោជន៍ពីទន្លេមេគង្គ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហូបនីយកម្ម ហើយប្រទេសទាំងនោះក៏អាចធ្វើការអភិវឌ្ឍស្ទុះតាមបណ្តាប្រទេសជឿនលឿន កាត់បន្ថយភាពក្រីក្រ និងពង្រីកសមាហរណកម្មក្នុងតំបន់។

រូបភាព២៖ ផែនទីអាងទន្លេមេគង្គ




ប្រភព៖ ក្រសួងធនធានធម្មជាតិ និងបរិស្ថាន 2015
www.mekongeye.com/ wp-content/uploads/sites/2/2016/04/MDS-Final-Project-Report-Eng.pdf

ការប៉ះទង្គិចដែលបានផ្ទុះឡើងជុំវិញទន្លេមេគង្គ មានច្រើនសណ្ឋាន ហើយចំណុចលេចធ្លោជាងគេគឺ វត្តមានការចូលរួមពីបណ្តាប្រទេសដែលមិនស្ថិតនៅក្នុងអនុតំបន់ទន្លេមេគង្គ ក្នុងការដោះស្រាយការទូតលើការគ្រប់គ្រងទឹក។ ការប្រជែងគ្នាផ្នែកភូមិសាស្ត្រនយោបាយ និងការប្រទាញប្រទង់គ្នារវាងមហាអំណាច ជាពិសេស ការលូកដៃចូលរបស់សហរដ្ឋអាមេរិកក្នុងបញ្ហាទន្លេមេគង្គ ត្រូវបានចាត់ទុកថាជាមូលហេតុដ៏ចម្បងមួយនៃទំនាស់ (Chang 2013)។ ក្នុងដំណើរការនៃការប្រកួតប្រជែងនេះ ក៏មានគំនិតផ្តួចផ្តើម ធ្វើសហប្រតិបត្តិការជាច្រើនរបស់ប្រទេសចិន (សហប្រតិបត្តិការមេគង្គ-ឡានឆាង) សហរដ្ឋអាមេរិក (ភាពជាដៃគូសហរដ្ឋអាមេរិក-មេគង្គ ដែលត្រូវបានពង្រឹង និងប្តូរឈ្មោះពី គំនិតផ្តួចផ្តើមតំបន់ទន្លេមេគង្គក្រោម) ជប៉ុន (មេគង្គ-ជប៉ុន) និងកូរ៉េខាងត្បូង (មេគង្គ-កូរ៉េខាងត្បូង) និងគំនិតផ្តួចផ្តើមបង្កើតដោយស្ថាប័នក្នុងតំបន់ និងអន្តរជាតិជាច្រើនទៀត។

ថ្វីបើប្រទេសតាមដងទន្លេមេគង្គ ជាពិសេសបណ្តាប្រទេសនៅខ្សែទឹកខាងក្រោម បានទទួលអត្ថប្រយោជន៍គួរឲ្យកត់សម្គាល់ជាច្រើនពី គំនិតផ្តួចផ្តើមសហប្រតិបត្តិការនានា ជាពិសេសតាមរយៈសកម្មភាពនៃគម្រោងផ្សេងៗក្តី ប៉ុន្តែក្នុងនេះ តំបន់ទន្លេមេគង្គ បានក្លាយជាសមរភូមិយុទ្ធសាស្ត្រមួយនៃពួកមហាអំណាច (Hirsch 2016)។ បន្ថែមលើនេះទៀត ការរិះគន់ឥតឈប់ឈរលើការសាងសង់ទំនប់ទឹកជាឯកច្ឆន្ទរបស់ចិន ដោយគ្មានការពិភាក្សាច្បាស់លាស់ជាមួយ បណ្តាប្រទេសនៅខ្សែទឹកខាងក្រោម បានធ្វើឲ្យជម្លោះកាន់តែតានតឹងឡើង និងបានបង្ហាញច្បាស់ពីទំនាក់ទំនង និងសិទ្ធិអំណាចមិនស្មើភាព និងធ្វើឲ្យមានការមិនទុកចិត្តគ្នាទៅវិញទៅមក រវាងបណ្តាប្រទេសនៅក្នុងតំបន់ (Chang 2013)។

### ក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹក ដើម្បីដោះស្រាយវិវាទទឹក

ទោះបីជាជម្លោះលើធនធានទឹក បានតានតឹងឡើងទៀត ប៉ុន្តែវិវាទនេះគួរតែអាចដោះស្រាយបានប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បី

ជំរុញសមាហរណកម្ម និងសហប្រតិបត្តិការក្នុងតំបន់ និងសម្រេចបានវិបុលភាព និងការអភិវឌ្ឍទាំងអស់គ្នា។ ការទូតក្នុងការគ្រប់គ្រងទឹក ជាការទូតថ្មីមួយ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយទំនាស់ទឹកឆ្លងកាត់ព្រំដែន និងជាវិធីសាស្ត្រយុទ្ធសាស្ត្រមួយដែលមានការចូលរួម និងពិភាក្សាគ្នាពីសំណាក់អ្នកពាក់ព័ន្ធនិងអ្នកនយោបាយនានា ក្នុងគោលបំណងពង្រឹងសន្តិភាព ស្ថិរភាព និងការរីកចម្រើន (Hefny 2011; Molnar et al. 2017)។ យោងតាម Hefny (2011) និង Molnar et al. (2017) ការសិក្សានេះបានកំណត់និយមន័យ ការទូតក្នុងការគ្រប់គ្រងទឹកថាជា ការព្យាយាមដោះស្រាយនិងកាត់បន្ថយទំនាស់លើធនធានទឹក កសាងទំនុកចិត្ត លើកកម្ពស់សហប្រតិបត្តិការ និងពង្រឹង សមាហរណកម្មក្នុងតំបន់ សន្តិភាព និងសុវត្ថិភាព តាមរយៈការប្រើប្រាស់បញ្ចូលគ្នានូវវិធីសាស្ត្រច្រើនយ៉ាង ដូចជាមជ្ឈត្តកម្ម ចំណេះដឹងផ្នែកច្បាប់ និងចំណេះដឹងបានពីការសិក្សារកឃើញជាក់ស្តែង។ ផ្នែកពីរដូចតទៅនេះ មានពន្យល់ពីយន្តការ និងក្របខ័ណ្ឌផ្សេងៗ ដែលត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយទំនាស់នានានៅអាងទន្លេអ៊ីនឌុស និងមេគង្គ។

## *អាងទន្លេអ៊ីនឌុស*

វិវាទទឹកនៅអាងទន្លេអ៊ីនឌុស បានចាប់ផ្តើមវិវត្តធ្ងន់ធ្ងរក្រោយពេលប្រទេសឥណ្ឌាទទួលបានឯករាជ្យនៅឆ្នាំ១៩៤៧។ បន្ទាប់ពីមានការចរចាដឹកនាំដោយធនាគារពិភពលោក អស់រយៈពេលជិតមួយទសវត្សរ៍មក សន្ធិសញ្ញាទឹកអ៊ីនឌុស (IWT) ក៏ត្រូវបានអនុម័តក្នុងឆ្នាំ១៩៦០ ដើម្បីដោះស្រាយ និងកាត់បន្ថយជម្លោះរវាងភាគីទាំងពីរ (Alam 2002)។ IWT បានចែងថា ទន្លេអ៊ីនឌុសត្រូវបានខណ្ឌចែកគ្នាជាពីរដោយ ដៃទន្លេនៅភាគខាងកើតត្រូវប្រគល់ឲ្យឥណ្ឌា និងដៃទន្លេនៅភាគខាងលិច ឲ្យទៅប៉ាគីស្ថាន (Sarfraz 2013)។ ក្នុងនោះផងដែរ IWT តម្រូវឲ្យប្រទេសទាំងពីរ៖ (១) មិនបង្អាក់លំហូរទឹក ឬបង្កគ្រោះថ្នាក់ដល់ភាគីម្ខាងទៀត និង (២) ធ្វើសហប្រតិបត្តិការជាមួយគ្នា និងផ្តល់ឲ្យគ្នាទៅវិញទៅមកនូវទិន្នន័យធារាសាស្ត្រ (Sarfraz 2013)។

បទបញ្ញត្តិទាំងឡាយនៅក្នុង IWT បន្តអនុវត្តបានជាង ៥០ឆ្នាំមកហើយ ទោះបីក្នុងអំឡុងពេលឥណ្ឌា-ប៉ាគីស្ថានមានសង្គ្រាមរវាងគ្នាក្នុងឆ្នាំ១៩៦៥ ១៩៧១ និង ១៩៩៩ (Ranjan 2016) ក្តី។ ប្រហែលមានកត្តាពីរយ៉ាងដែលធ្វើឲ្យ IWT ត្រូវបានចាត់ទុកជាសន្ធិសញ្ញាមួយមានជោគជ័យជាងគេ ក្នុងការដោះស្រាយវិវាទទឹក។ ទី១ ជោគជ័យដ៏ធំធេងនេះ បានមកពីឆន្ទៈរបស់ឥណ្ឌា និងប៉ាគីស្ថាន ក្នុងការដោះស្រាយជម្លោះទឹកនេះ ដោយចាត់ទុកថាវាជាបញ្ហាបច្ចេកទេស ជាជាងគិតថាវាជាបញ្ហាភូមិសាស្ត្រនយោបាយ។ ជាការឆ្លើយតប ប្រទេសទាំងពីរបានព្រមព្រៀងគ្នាបង្កើត គណៈកម្មការអចិន្ត្រៃយ៍ទន្លេអ៊ីនឌុស (PIC) ដែលមានសមាសភាពវិស្វករបច្ចេកទេសជាន់ខ្ពស់ពីរនាក់ គឺម្នាក់ត្រូវបានតែងតាំងដោយឥណ្ឌា និងម្នាក់ទៀតដោយប៉ាគីស្ថាន។ គោលគំនិតនៃការបង្កើតក្រុមការងារនេះ គឺដើម្បីឲ្យប្រទេសទាំងពីរអាចអភិវឌ្ឍ និងគ្រប់គ្រងទន្លេអ៊ីនឌុសរួមគ្នា អនុលោមតាមបទបញ្ញត្តិរបស់ IWT។ ទី២ ក្នុងករណីដែល PIC មិនអាចចេញសេចក្តីសម្រេចណាមួយ ដែលភាគីទាំងសងខាងអាចទទួលយកបាន ឬមិនអាចដោះស្រាយទំនាស់ទឹករវាងប្រទេសទាំងពីរបាននោះ ភាគីទាំងពីរត្រូវរកភាគីទី៣ ដែលជាអ្នកជំនាញមកជួយសម្រុះសម្រួល ឬក៏ប្តឹងទៅតុលាការមជ្ឈត្តកម្មអចិន្ត្រៃយ៍ (PCA) ដើម្បីដោះស្រាយទំនាស់។

ប៉ុន្តែដោយឡែក ទោះបីជាមានការបង្កើត IWT និង PIC សម្រាប់គ្រប់គ្រងទន្លេអ៊ីនឌុសក្តី ឥណ្ឌានៅតែបន្តសាងសង់ទំនប់ទឹកតាមដងទន្លេជាច្រើន ដែលធ្វើឲ្យប៉ាគីស្ថានមានការខឹងសម្បា និងធ្វើឲ្យមានការប៉ះទង្គិចគ្នាជាច្រើនលើក (Qureshi 2017b)។ ទោះបីជា PIC បានដោះស្រាយបញ្ហាជាច្រើនរវាងប៉ាគីស្ថាន និងឥណ្ឌាក្តី ក៏នៅមានបញ្ហាពីរដែល PIC មិនអាចដោះស្រាយបានពោលគឺ ក្តីបារម្ភរបស់ប៉ាគីស្ថានលើទំនប់ទឹក Baglihar និង Kishenganga របស់ឥណ្ឌា (Sarfraz 2013)។ ដូច្នេះ តាមលក្ខខណ្ឌដែលមានចែងក្នុង IWT ទំនប់ទឹកទាំងពីរត្រូវមានការដាក់ឲ្យធ្វើការសិក្សាស្រាវជ្រាវដោយ អ្នកជំនាញឯករាជ្យម្នាក់ដែលចាត់តាំងឡើងដោយធនាគារពិភពលោក និងការដោះស្រាយតាមរយៈយន្តការតុលាការ PCA (Rao 2017)។ ទាក់ទិននឹងទំនាស់លើទំនប់ Baglihar នេះ ប៉ាគីស្ថានបានជំទាស់នឹងការសាងសង់ទំនប់ ដោយសារវាមានហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ តែខាងឥណ្ឌាបានលើកថា ទំនប់នេះមិនប៉ះពាល់ដល់លំហូរទឹកទេ។ ដោយសារតែភាពមិនចុះសម្រុងគ្នានេះ អ្នកជំនាញឯករាជ្យម្នាក់ត្រូវបានចាត់តាំងឲ្យមកវាយតម្លៃស្ថានភាពជាក់ស្តែង ហើយក៏បានចេញសេចក្តីសម្រេចថា គម្រោងនេះមិនបង្កផលប៉ះពាល់អាក្រក់ទេ ប៉ុន្តែត្រូវមានការកែតម្រូវបន្តិចបន្តួចក្នុងការសាងសង់ទំនប់នេះ។ ក្នុងករណីទី២ ក្តីបារម្ភរបស់ប៉ាគីស្ថានផ្តោតលើការរាំងស្ទះលំហូរទឹកទន្លេ និងការថយចុះកម្រិតទឹកក្នុងអាងទន្លេដែលបណ្តាលមកពីការសង់ទំនប់ទឹក Kishengang។ ប៉ាគីស្ថានបានប្តឹងទៅ PCA ហើយសាលក្រមចុងក្រោយរបស់តុលាការបានកំណត់ថា រដ្ឋនានាអាចសាងសង់ទំនប់បាន ប៉ុន្តែឥណ្ឌាត្រូវមានទំនួលខុសត្រូវ ក្នុងការធានាឲ្យមានលំហូរទឹកកម្រិតអប្បបរមាដើម្បីទប់ស្កាត់ការថយចុះកម្រិតទឹកក្នុងអាង (លើកលែងតែក្នុងស្ថានភាពចាំបាច់បន្ទាន់) និងក្នុងការការពារបរិស្ថានតាមដងទន្លេ (Sidhu 2013; Rao 2017)។

ក្នុងប្រាំទសវត្សរ៍កន្លងមកនេះ PIC ដំណើរការបានល្អរហូតមក ទោះបីជាមានទំនាស់ទឹកដី និងការប្រទូសរ៉ាយគ្នារវាងប្រទេសទាំងពីរក្តី (Sinha, Gupta and Behuria 2012)។ សមិទ្ធផលដ៏គួរឲ្យកត់សម្គាល់នេះ បានមកពីតម្លាភាព និងភាពមិនលំអៀងរបស់ PIC ក្នុងការអនុវត្តតួនាទីរបស់ខ្លួន (Zawahri 2008)។ ម្យ៉ាងទៀតបទបញ្ញាតិក្នុង IWT បានកំណត់ឲ្យ PIC ធ្វើទស្សនកិច្ចជាផ្លូវការ ត្រួតពិនិត្យដងទន្លេអ៊ីនឌុសរៀងរាល់ប្រាំឆ្នាំម្តង ក្រៅពីការប្រជុំប្រចាំឆ្នាំរបស់ PIC និងការប្រជុំជាពិសេសផ្សេងៗទៀតដែលកើតឡើងតាមការស្នើរបស់សមាជិកគណៈកម្មការ នៃភាគីនីមួយៗ (Zawahri 2008)។ មួយវិញទៀត ក្រៅតែពីធនាគារអន្តរជាតិសម្រាប់ការសាងសង់ឡើងវិញ និងអភិវឌ្ឍន៍ (IBRD ដែលគេតែងហៅថា ធនាគារពិភពលោក) IWT មិនអនុញ្ញាតឲ្យមានការចូលរួមពីស្ថាប័នសាធារណៈ ឬអន្តរជាតិណាឡើយ (Khan 1990)។ ការប្រតិបត្តិយ៉ាងតឹងរ៉ឹងតាមបទបញ្ញត្តិទាំងនេះ

បានធ្វើឲ្យទំនាស់ក្នុងអាងទន្លេអ៊ីនឌុស រវាងប្រទេសទាំងពីរ អាចដោះស្រាយបានដោយសន្តិភាព ដោយប្រើមធ្យោបាយការទូត ជាពិសេស ការចរចា ការពិគ្រោះយោបល់ និងការផ្សះផ្សារ ដោយ PIC និងការសម្រុះសម្រួលដោយធនាគារពិភពលោក និងការសម្រេចសេចក្តីដោយ PCA ។

### ***ទន្លេមេគង្គ***

ទន្លេមេគង្គ ក៏ជាប្រភពសំខាន់មួយនៃ ជម្លោះលើធនធានទឹកដែរ។ បើពិនិត្យពីប្រវត្តិនៃសហប្រតិបត្តិការរវាងប្រទេសតាមដងទន្លេមេគង្គក្រោម (កម្ពុជា ឡាវ ថៃ និង វៀតណាម) ទំនាស់បានផ្ទុះឡើងជាលើកដំបូង ក្រោយពេលបង្កើតគណៈកម្មការមេគង្គក្នុងឆ្នាំ១៩៥៧។ ដោយសារសង្គ្រាមមនោគមន៍វិជ្ជាក្នុងតំបន់ និងសង្គ្រាមស៊ីវិលនៅកម្ពុជា សហប្រតិបត្តិការដែលគណៈកម្មការមេគង្គបានបង្កើតឡើង គឺមិនបានដំណើរការដោយរលូនទេ (Sunchindah 2005)។ នៅឆ្នាំ១៩៩៥ ដោយសារមានការគាំទ្រពីអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិនានា គណៈកម្មការមេគង្គ ត្រូវបានកែប្រែឈ្មោះជា គណៈកម្មការទន្លេមេគង្គ (MRC) ដោយមានគណៈកម្មការមេគង្គតំណាងឲ្យបណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គជាសមាជិក ប៉ុន្តែប្រទេស ចិន និង មីយ៉ាន់ម៉ា មិនបានចូលជាសមាជិកទេ គឺបានធ្វើជាដៃគូសន្ទនា។ នាពេលបច្ចុប្បន្ន អាណត្តិរបស់ MRC រួមមាន ការត្រួតពិនិត្យអនុវត្តគោលនយោបាយផ្សេងៗ សម្របសម្រួលផែនការរបស់បណ្តាប្រទេសសមាជិក សំដៅឲ្យមានការអភិវឌ្ឍប្រកបដោយសមភាពនិងសមធម៌សម្រាប់សង្គម ការពារបរិស្ថាន និងរក្សាភាពគង់វង្សនៃប្រព័ន្ធអេកូឡូស៊ី រួមទាំងសិក្សាលើការអភិវឌ្ឍលើទន្លេមេគង្គ និងដៃទន្លេប្រកបដោយចីរភាព ហើយក្នុងនោះក៏មានរួមបញ្ចូលការសាងសង់ទំនប់ទឹកផងដែរ (Gerlak and Haefner 2017)។ នៅឆ្នាំ២០០៣ ភាគីទាំងអស់បានបង្កើតកិច្ចព្រមព្រៀងទន្លេមេគង្គ ដែលបានដាក់ចេញនូវ នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងគ្នា (PNPCA)[១] ក្នុងការគ្រប់គ្រងទន្លេ។

នាពេលកន្លងមក MRC ធ្លាប់បានសម្រុះសម្រួលវិវាទជាច្រើនរវាងរដ្ឋជាសមាជិក។ ក្នុងករណីពុំមានដំណោះស្រាយ គឺត្រូវបង្វែរយន្តការមកធ្វើការចរចាគ្នារវាងរដ្ឋពាក់ព័ន្ធ ដោយអនុលោមតាមកិច្ចព្រមព្រៀងទន្លេមេគង្គ។ ខុសប្លែកពីលក្ខខណ្ឌក្នុង IWT កិច្ចព្រមព្រៀងទន្លេមេគង្គ មិនមានគូសបញ្ជាក់ពីលក្ខខណ្ឌធ្វើមជ្ឈត្តកម្មឡើយ។

MRC ក៏ត្រូវបានប្រើប្រាស់ជាវេទិកាការទូតក្នុងការគ្រប់គ្រងទឹកដែលសំដៅដល់ ការជួយសម្រួលការចរចាលើបញ្ហាទឹកក្នុងតំបន់។ ករណីជាក់ស្តែងមួយគឺ ការសាងសង់ទំនប់ជាច្រើនរបស់ប្រទេសចិននៅលើលំហូរធំនៃទន្លេមេគង្គ ក្នុងអាងទន្លេខាងលើ។ ដើម្បីធានាឲ្យមានតម្លាភាពទិន្នន័យធារាសាស្ត្រ ផ្តល់ជាភស្តុតាងបញ្ជាក់ និងធ្វើឲ្យបណ្តាប្រទេសនៅខ្សែទឹកខាងក្រោម មានទំនុកចិត្ត MRC បានប្រមូលទិន្នន័យធារាសាស្ត្រពីតំបន់នានា នៅទន្លេខាងលើ សម្រាប់ប្រើក្នុងការវិភាគជាលក្ខណៈបច្ចេកទេសវិទ្យាសាស្ត្រ និងតាក់តែងច្បាប់គ្រប់គ្រងទឹក ដើម្បីចែករំលែកជាមួយរដ្ឋជាសមាជិក ដៃគូអភិវឌ្ឍន៍អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) នានា (Schmeier 2011)។

ក្នុងពេលថ្មីៗនេះដែរ ចិនបានចុះកិច្ចព្រមព្រៀង ចែករំលែកទិន្នន័យធារាសាស្ត្រពេញមួយឆ្នាំ ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ (MRC 2020)។ គួររំលឹកផងដែរថា មុនពេលចុះកិច្ចព្រមព្រៀងនេះ ចិនយល់ព្រមផ្តល់ឲ្យ MRC តែទិន្នន័យធារាសាស្ត្រ និងកម្រិតទឹកភ្លៀង ដែលមានរយៈពេលតែប្រាំខែក្នុងរដូវវស្សា (ពីខែមិថុនា ដល់ តុលា) ប៉ុណ្ណោះ។ បន្ថែមលើនេះ ដើម្បីបង្ហាញនូវសហប្រតិបត្តិការកាន់តែស្អិតរមួត និងការយកចិត្តទុកដាក់លើមហាអនុតំបន់មេគង្គ ចិនបានដាក់ចេញនូវសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅឆ្នាំ២០១៥ ដែលរួមមានការធ្វើសហការ និងផ្តល់ជាគម្រោងអភិវឌ្ឍន៍ដល់ប្រទេសទាំងអស់នៅតាមដងទន្លេ ក្នុងមហាអនុតំបន់មេគង្គ (Biba 2018)។

ទោះបីតាមការមើលពីខាងក្រៅ MRC មានសារៈសំខាន់ក្តី ប៉ុន្តែគណៈកម្មការនេះ ហាក់ដូចជាមានសិទ្ធិអំណាច និងមានជោគជ័យតិចតួចក្នុងការដោះស្រាយវិវាទ (Kittikhoun and Staubi 2018)។ មូលហេតុទំនងជាអាចមកពីភាពខុសគ្នានៃការទាញយកប្រយោជន៍ពី ការប្រើប្រាស់ទឹកទន្លេមេគង្គរបស់រដ្ឋជាសមាជិកនីមួយៗ និងការគិតគូរតែពីផលប្រយោជន៍ជាតិខ្លួនតែប៉ុណ្ណោះ (Gerlak and Haefner 2017; Sok 2020)។ ជាឧទាហរណ៍ ករណីទំនប់ Xayaburi និង Don Sahong ដែលឡាវបានស្នើឡើងក្នុងឆ្នាំ២០១០ និង ២០១៤ MRC មិនមានសមត្ថភាពបញ្ចុះបញ្ចូលឲ្យរដ្ឋសមាជិកអនុវត្តតាម PNPCA បានទេ ដូច្នេះហើយ ការសាងសង់ទំនប់ក៏ត្រូវបានពន្យាពេល (Gerlak and Haefner 2017)។ ម្យ៉ាងទៀត កង្វះឆន្ទៈ និងការប្តេជ្ញាចិត្តផ្នែកនយោបាយ របស់ប្រទេសជាសមាជិកមួយចំនួន បានធ្វើឲ្យ MRC មិនមានលទ្ធភាពបន្តអនុវត្តបាននូវការទូតក្នុងការគ្រប់គ្រងទឹក រួមទាំងក្របខ័ណ្ឌច្បាប់ផ្សេងៗទៀត។ ដោយសារមានទំនាស់ផលប្រយោជន៍ ក្នុងចំណោមអ្នកដឹកនាំយោបាយនេះហើយ ថៃ ជាឧទាហរណ៍ មិនបានបោះឆ្នោតយល់ព្រមលើកិច្ចព្រមព្រៀង វាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងកាត់ព្រំដែន ការចែករំលែកទឹក និងគុណភាពទឹក ដែល MRC បានស្នើឡើង (Campbell 2011) នោះទេ។ ដោយសារកិច្ចព្រមព្រៀងនេះត្រូវមានលទ្ធផលបោះឆ្នោតជាឯកច្ឆន្ទ កិច្ចព្រមព្រៀងនេះ គឺមិនអាចសម្រេចបានទេ។

### **សេចក្តីសន្និដ្ឋាន**

ទឹកជាតម្រូវការចាំបាច់សម្រាប់ការរស់រានមានជីវិត។ ប៉ុន្តែដោយសារ កំណើនតម្រូវការធនធានទឹក ការគ្រប់គ្រងទឹកមិនត្រឹមត្រូវ ភាពមិនទុកចិត្តគ្នា ការប្រែប្រួលអាកាសធាតុ និងជាពិសេស ការចូលរួមប្រកួតប្រជែងអំពីសំណាក់មហាអំណាចធំៗ ទឹកបានក្លាយជាប្រភពនៃទំនាស់ទៅវិញ។ ភាគច្រើននៃជម្លោះទឹកកើតឡើងនៅតាមប្រទេសដែលមានព្រំដែនទឹករួមគ្នារវាង ពីរ ឬ

---

១ PNPCA ជាគោលការណ៍ទូទៅរួមមួយ ដែលត្រូវបានរៀបចំដោយគណៈកម្មការក្នុងការធានាឲ្យមានលំហូរ និងគុណភាពទឹកសម្រាប់អាងទន្លេ ដោយផ្តោតលើគម្រោងនានា រួមមាន វារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រខ្នាតធំ និងគម្រោងជាច្រើនផ្សេងទៀត។

ច្រើនប្រទេស។ ដូចការសិក្សាបានបង្ហាញនៅខាងលើ ទំនាស់លើធនធានទឹកអាចទប់ស្កាត់ ឬកាត់បន្ថយបាន តាមរយៈការអនុវត្តការទូតក្នុងការគ្រប់គ្រងទឹក។

ការលើកកម្ពស់ក្របខ័ណ្ឌច្បាប់ផ្សេងៗក្នុងតំបន់ អាចជួយឲ្យមានដំណោះស្រាយប្រកបដោយសន្តិវិធី លើជម្លោះទឹករវាងរដ្ឋនានានៅតាមដងទន្លេ។ ការបង្កើតអង្គភាព ឬគណៈកម្មការត្រួតពិនិត្យ ដែលដើរតួនាទីជាអ្នកសម្របសម្រួល ឃ្លាំមើល និងដោះស្រាយទំនាស់ផ្សេងៗ ដោយផ្តល់ភស្តុតាងបែបវិទ្យាសាស្ត្រ កសាងទំនុកចិត្ត និងជំរុញសហប្រតិបត្តិការ គឺសុទ្ធតែជាលក្ខខណ្ឌចាំបាច់។ ដូចបានលើកឡើងរួចមកហើយ ការសម្រុះសម្រួល និងដោះស្រាយវិវាទទឹកនៅអាងទន្លេអ៊ីនឌុស និងមេគង្គ វាអាស្រ័យលើការប្រើប្រាស់ការទូតក្នុងការគ្រប់គ្រងទឹក តាមរយៈ PIC និង MRC នៃកិច្ចព្រមព្រៀងលើទន្លេទាំងពីរ។ ជារួម PIC មើលទៅទំនងមានជោគជ័យជាង ក្នុងការដោះស្រាយបញ្ហាទឹកដោយសន្តិវិធីនៅអាងទន្លេអ៊ីនឌុស ហើយ MRC ហាក់ដូចមានសិទ្ធិអំណាច និងជោគជ័យតិចតួច ក្នុងការដោះស្រាយទំនាស់ធនធានទឹក។ ដោយផ្អែកលើករណីសិក្សាទាំងពីរ ការសិក្សានេះបានលើកជាមតិដូចតទៅ៖

១. ជាការសំខាន់ដែលបណ្តារដ្ឋនៅតាមដងទន្លេ ត្រូវកសាងទំនុកចិត្តរវាងគ្នាទៅវិញទៅមក និងពង្រឹងការប្តេជ្ញាចិត្តផ្នែកនយោបាយ ដើម្បីសម្រេចបានការអភិវឌ្ឍទាំងអស់គ្នា (synergies) សម្របសម្រួលគោលនយោបាយ និងពង្រីកសហប្រតិបត្តិការឲ្យបានល្អបំផុត ក្នុងការប្រើប្រាស់ប្រភពទឹករួមគ្នា និងទទួលបានផលប្រយោជន៍ពីធនធានទឹកទាំងអស់គ្នា។ ក្នុងនោះដែរ ការប្រើប្រាស់ទឹកដោយសមរម្យនិងស្មើភាពគ្នាដូចមានចែងក្នុងច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងនៅក្នុងតំបន់ គឺមិនត្រូវរំលោភបំពានឡើយ។

២. ការទាញយកបទពិសោធន៍ពី ការដោះស្រាយទំនាស់ដោយជោគជ័យតាម IWT ដែលអនុវត្តបានយូរឆ្នាំមកហើយនេះ បញ្ហាប្រឈមផ្សេងៗនៃទន្លេមេគង្គ គឺអាចកាត់បន្ថយ និងគ្រប់គ្រងបានកាន់តែល្អ បើសិនមិនមានការចូលរួមច្រើនពីតួអង្គខាងក្រៅ និងការឈប់ដាក់របៀបវារៈយោធា នៅក្នុងតំបន់ទន្លេមេគង្គ។ "ការនឿយណាយនឹងគំនិតផ្តួចផ្តើមទន្លេមេគង្គដ៏ច្រើនសម្បើម (Mekong Initiative Fatigue)" ដោយសារមានគំនិតផ្តួចផ្តើមច្រើនពេក ដែលដឹកនាំដោយតួអង្គជារដ្ឋផ្សេងៗជាច្រើន ជាពិសេសគំនិតផ្តួចផ្តើមផ្តោតលើវេទិកាសន្ទនា ជាជាងលើគម្រោងអភិវឌ្ឍ បានធ្វើឲ្យបញ្ហាទន្លេមេគង្គកាន់តែស្មុគស្មាញ និងបញ្ឆេះការប្រជែងគ្នាផ្នែកនយោបាយ។ ផលប្រយោជន៍អាចទទួលបានច្រើនជាងសម្រាប់បណ្តាប្រទេសនៅតំបន់មេគង្គក្រោម បើសិនគំនិតផ្តួចផ្តើមទាំងនោះ ផ្តោតជាសំខាន់លើសហប្រតិបត្តិការទៅវិញទៅមក និងការអភិវឌ្ឍ។

៣. បណ្តាប្រទេសជាសមាជិក MRC គួរពង្រឹង និងពង្រីកសហប្រតិបត្តិការជាមួយប្រទេសជិតខាង នៅទន្លេមេគង្គខាងលើ រួមមាន ចិន និង មីយ៉ាន់ម៉ា ជាពិសេសលើបញ្ហាគ្រប់គ្រងភាពរាំងស្ងួត និងការប្រែប្រួលអាកាសធាតុ។ ចិន និង មីយ៉ាន់ម៉ា បានក្លាយជាដៃគូសន្ទនាតាំងពីឆ្នាំ១៩៩៦ មក ប៉ុន្តែរហូតមកដល់ពេលថ្មីៗនេះ ការយកចិត្តទុកដាក់នៅមានតិចតួច និងមានកម្រិត ក្នុងការចូលរួមជាមួយ MRC ដែលជាយន្តការសម្រាប់ជំរុញសហប្រតិបត្តិការ។ ដូចនេះ បើសិនប្រទេសទាំងប្រាំមួយ (គឺមានទាំង ចិន និង មីយ៉ាន់ម៉ា ផង) ក្លាយជាសមាជិកក្នុងវេទិកា MRC តែមួយនោះ ការធ្វើសហប្រតិបត្តិការ គឺរឹតតែមានប្រសិទ្ធភាពខ្ពស់។

៤. បណ្តាប្រទេសនៅតំបន់មេគង្គ គួរព្រមព្រៀងគ្នាចាត់ទុកវិវាទទឹកជាបញ្ហាបច្ចេកទេស ដូចក្នុងករណី IWT ជាជាងគិតថាវាជាបញ្ហាភូមិសាស្ត្រនយោបាយ។ ប្រទេសទាំងនេះ ក៏គួរជៀសវាងទំនោរនាំយកប្រទេសមហាអំណាច មកប្រជែងគ្នានៅក្នុងវិវាទទឹក ពីព្រោះធ្វើដូច្នេះអាចនាំឲ្យមានការដាក់របៀបវារៈ សន្តិសុខ និងយោធានៅក្នុងតំបន់មេគង្គ ដែលអាចបញ្ឆេះទំនាស់ធ្វើឲ្យបញ្ហាទឹកកាន់តែស្មុគស្មាញថែមទៀត។

## សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះ ជាផ្នែកមួយនៃគម្រោងស្រាវជ្រាវរយៈពេល ២ឆ្នាំថ្នាក់តំបន់របស់វិទ្យាស្ថាន CDRI ស្តីពី "ការទូតស្តីពីទឹកមេគង្គ៖ ឆ្ពោះទៅអាងរួមគ្នាដើម្បីវឌ្ឍនភាព" ផ្តល់មូលនិធិដោយមូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង (MLC) តាមរយៈក្រសួង កិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) កម្ពុជា។

## ឯកសារយោង

Abbashi, Shakeel Abbasia, Muhammad Zubair Anwara, Nusrat Habiba, Qaisar Khana and Kanwal Waqar. 2019. “Identifying Gender Vulnerabilities in Context of Climate Change in Indus Basin.” *Environmental Development* 31: 34–42.

ADB (Asian Development Bank). 2013. *Asian Water Development Outlook 2013: Measuring Water Security in Asia and the Pacific*. Mandaluyong City: ADB.

Alam, Undala Z. 2002. “Questioning the Water Wars Rationale: A Case Study of the Indus Waters Treaty.” *Geographical Journal* 168 (4): 341–353. doi.org/10.1111/j.0016-7398.200 2.00060.x.

Balraj K. Sidhu. (2013). The Kishenganga Arbitration – Transboundary Water Resources Governance –. *Enviromental Policy and Law*, *43/3*, 150. https://doi.org/10.3233/DEV-2012-12111

Biba, Sebastian. 2018. “China’s ‘Old’ and ‘New’ Mekong River Politics: The Lancang-Mekong Cooperation from a Comparative Benefit-Sharing Perspective.” *Water International* 43 (5): 622–641. doi.org/10.1080/00472336.2012.712257.

Campbell, Ian C. 2011. “Managing International River Basins: Successes and Failures of the Mekong River Commission.” In *Water Resources Planning and Management*, edited by R. Quentin Grafton and Karren Hussey, 724–740. doi.org/10.1017/CBO9780511974304.037.

Chang, F. K. 2013. "The Lower Mekong Initiative and U.S. Foreign Policy in Southeast Asia: Energy, Environment and Power." *Orbis* 57 (2): 282–299. doi.org/10.1016/j.orbis.2013.02. 005.

Gerlak, Andrea K., and Andrea Haefner. 2017. "Riparianization of the Mekong River Commission." *Water International* 42 (7): 893–902. doi.org/10.1080/02508060.2017.1376 267.

Gholizadeh, Bahareh, and Mehrdad Niknami. 2020. "The Causes and Effects of Water Conflict: Evidence from Damava." *Bulgarian Journal of Agricultural Science* 26 (3): 598–604.

Haq, Inamul, and Sheeraz Ahmad Sofi. 2019. "Kashmir Conflict and Indus Water Treaty: An Analysis." *Kardan Journal of Social Sciences and Humanities* 2 (2): 44–56.

Hefny, Magdy. 2011. "Water Diplomacy: A Tool for Enhancing Water Peace and Sustainability in the Arab Region." Paper presented in preparation for the Second Arab Water Forum Theme 3: Sustainable and Fair Solutions for the Trans-Boundary Rivers and Groundwater Aquifers, Cairo, 20–23 Nov 2011.

Hirsch, P. (2016). The shifting regional geopolitics of Mekong dams. *Political Geography*, *51*, 63–74.

Khan, M. Yunus. 1990. "Boundary Water Conflict between India and Pakistan." *Water International* 15 (4): 195–199. doi.org/10.1080/02508069008691649.

Kittikhoun, Anoulak, and Denise Michèle Staubli. 2018. "Water Diplomacy and Conflict Management in the Mekong: From Rivalries to Cooperation." *Journal of Hydrology* 567: 654–667.

Li, Xinlin. 2012. "Hydropower in the Mekong River Basin: A Balancing Test." *Environmental Claims Journal* 24 (1): 51–69. doi.org/10.1080/10406026.2012.663299.

Molen, Irna van der, and Antoinette Hildering. 2005. "Water: Cause for Conflict or Co-Operation?" *ISYP Journal on Science and World Affairs* 1 (2): 133–43.

Molnar, Kata, Rosa Cuppari, Susanne Schmeier and Siegfried Demuth. 2017. *Preventing Conflicts, Fostering Cooperation – The Many Roles of Water Diplomacy*. www.waterandchange.org/wp-content/uploads/2018/02/PUB_Water-Diplomacy_Bericht.pdf,

MRC (Mekong River Commission). 2020. "MRC Secretariat Welcomes China's Pledge to Share Mekong Data but Suggests Harnessing Existing Platform." Mekong River Commision. www.mrcmekong.org/news-and-events/news/pr-mrcs-welcomes-china-pledge/.

Parashar, Sachin. 2020. "India Wants Pakistan to Prosecute David Headley for 26/11 Mumbai Terror." *Economic Times,* 20 Sep 2020. https://economictimes.indiatimes.com/news/defenc e/india-wants-pakistan-to-prosecute-david-headley-for-26/11-mumbai-terror-attacks/article show/788862 28.cms.

Petersen-Perlman, Jacob D., Jennifer C. Veilleux and Aaron T. Wolf. 2017. "International Water Conflict and Cooperation: Challenges and Opportunities." *Water International* 42 (2): 105–120.

Qureshi, Waseem Ahmad. 2017a. "The Indus Basin: Water Cooperation, International Law and the Indus Waters Treaty." *Michigan State International Law Review* 26 (1): 45–81.

Qureshi, Waseem Ahmad. 2017b. "The Indus Waters Treaty and the Role of World Bank as Mediator." *Willamette Journal of International Law and Dispute Resolution* 24 (2): 211–232.

Ranjan, Amit. 2016. "Disputed Waters: India, Pakistan and the Transboundary Rivers." *Studies in Indian Politics* 4 (2): 191–205.

Rao, Sahana. 2017. "Governance of Water Resources Shared by India and Pakistan under the Indus Waters Treaty: Successful Elements and Room for Improvement." *NYU Environmental Law Journal* 25: 108–139.

Sarfraz, Hamid. 2013. "Revisiting the 1960 Indus Waters Treaty." *Water International* 38 (2): 204–216.

Schmeier, Susanne. 2011. *Resilience to Climate Change-Induced Challenges in the Mekong River Basin The Role of the MRC.* Water Papers. www.worldbank.org/en/topic/water.

Sinha, Uttam Kumar, Arvind Gupta and Ashok Behuria. 2012. "Will the Indus Water Treaty Survive?" *Strategic Analysis* 36 (5): 735–752.

Sok, Serey. 2020. Transparent Data Sharing among Member Countries: Crucial to Sustainable Management of Mekong River System. *Mekong Connect*, *2*(1), 5–9.

Sunchindah, Apichai. 2005. "Water Diplomacy in the Lancang-Mekong-River Basin: Prospect and Challenges." Prepared for the Workshop on the Growing Integration of Greater Mekong Sub-regional ASEAN States in Asian Region, Yangon, Myanmar, 20–21 Sep 2005.

United Nations. 2002. "World's Water Problems Can Be 'Catalyst for Cooperation' Says Secretary-General in Message on World Water Day." Press Release, 26 Feb 2002. www.un.org/press/en/2002/sgsm8139.doc.htm.

Wani, Khursheed Ahmad, and P. Moorthy. 2014. "Indus Waters Treaty : An Emerging Flashpoint between India and Pakistan." *Pakistan Horizon* 67 (2): 41–59.

World Economic Forum. 2020. The Global Risks Report 2020. WEF_Global_Risk_Report_2020.pdf (weforum.org).

Zawahri, Neda A. 2008. "Designing River Commissions to Implement Treaties and Manage Water Disputes: The Story of the Joint Water Committee and Permanent Indus Commission." *Water International* 33 (4): 464–474.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី២ ឆ្នាំ២០២០។ នៅពេលចងក្រងអត្ថបទនេះ ទិន្នន័យលើ កំណើន ផសស ពិតនៅកម្ពុជា មិនទាន់មានទេ។

## កំណើន ផសស ពិត

គេអាចមើលឃើញភ្លាមនូវការធ្លាក់ចុះកំណើន ផសស ពិត ក្នុងគ្រប់ប្រទេសជ្រើសរើស ទាំងធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ទាំងធៀបនឹងត្រីមាសមុន លើកលែងតែប្រទេសចិនដែលមានសេដ្ឋកិច្ចងើបឡើងវិញយ៉ាងលឿន។ ក្នុងចំណោមប្រាំប្រទេសអាស៊ានជ្រើសរើស ម៉ាឡេស៊ីមានការប៉ះទង្គិចខ្លាំងជាងគេ ដោយកំណើន ផសស បានរួមចុះអស់ ១៧,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ សិង្ហបុរីមានអត្រាកំណើនរួមចុះអស់ ១៣,២% ថៃរួមចុះអស់ ១២,២% ឥណ្ឌូនេស៊ីរួមចុះអស់ ៥,៣% វៀតណាមរួមចុះអស់ ០,៤%។ ធៀបនឹងកាលពីមួយឆ្នាំមុន សេដ្ឋកិច្ចម៉ាឡាស៊ីរួមចុះអស់ ២២,០ឯកតាភាគរយ សិង្ហបុរីរួមចុះអស់ ១៣,៣ឯកតាភាគរយ ថៃរួមចុះអស់ ១៤,៥ឯកតាភាគរយ ឥណ្ឌូនេស៊ីរួមចុះអស់ ១០,៣ឯកតាភាគរយ វៀតណាមរួមចុះអស់ ៦,៣ឯកតាភាគរយ។ ធៀបនឹងត្រីមាសមុន ផសស ម៉ាឡេស៊ីធ្លាក់ចុះ ១៧,៨ឯកតាភាគរយ សិង្ហបុរីធ្លាក់ចុះ ១១,០ឯកតាភាគរយ ថៃធ្លាក់ចុះ ១០,៤ឯកតាភាគរយ ឥណ្ឌូនេស៊ីធ្លាក់ចុះ ៨,៣ឯកតាភាគរយ វៀតណាមធ្លាក់ចុះ ៣,៤ឯកតាភាគរយ។

លើកលែងតែប្រទេសចិន ប្រទេសអាស៊ីជ្រើសរើសនានាមានសេដ្ឋកិច្ចរួមចុះពីខែមេសា ដល់ មិថុនា ក្នុងកម្រិតខ្លាំងជាងកាលពីត្រីមាសមុន។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន សេដ្ឋកិច្ចចិនក៏បានរួមចុះដែរ ប៉ុន្តែបានងើបឡើងវិញយ៉ាងលឿន ដោយ ផសស មានកំណើន ១០,០ឯកតាភាគរយធៀបនឹងត្រីមាសមុន ថ្វីបើវាធ្លាក់ចុះអស់ ៣,០ឯកតាភាគរយ ធៀបនឹងអត្រាកំណើនកាលពីមួយឆ្នាំមុនក្ដី។ ក្នុងក្រុមបួនប្រទេសអាស៊ីជ្រើសរើសនេះ មានបីប្រទេសបានរួមចុះសេដ្ឋកិច្ច។ ធៀបនឹងកាលពីមួយឆ្នាំមុន សេដ្ឋកិច្ចហុងកុងបានរួមចុះខ្លាំងបំផុតរហូតដល់ -៩,០% បន្ទាប់មកគឺកូរ៉េខាងត្បូង (-៣,០%) និង តៃវ៉ាន់ (-០,៦%) ប៉ុន្តែចិនដែលមានអត្រាកំណើនដល់ ៣,២% គឺកំពុងងើបឡើងវិញហើយ។ ធៀបនឹងកាលពីមួយឆ្នាំមុន សេដ្ឋកិច្ចហុងកុង ធ្លាក់ចុះអស់ ៩,៥ឯកតាភាគរយ កូរ៉េខាងត្បូងធ្លាក់ចុះអស់ ៥,១ឯកតាភាគរយ តៃវ៉ាន់ធ្លាក់ចុះអស់ ៣,០ឯកតាភាគរយ។ ធៀបនឹងត្រីមាសមុន ផសស ហុងកុងធ្លាក់ចុះ ០,១ឯកតាភាគរយ កូរ៉េខាងត្បូងធ្លាក់ចុះ ៤,៣ឯកតាភាគរយ តៃវ៉ាន់ធ្លាក់ចុះ ២,១ឯកតាភាគរយ។

ប្រទេសឧស្សាហកម្មជ្រើសរើសទាំងបី ជួបការធ្លាក់ចុះសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរថែមទៀត។ តំបន់អឺរ៉ូ១២ មានអត្រាកំណើន ផសស ទាបបំផុត គិតតាំងពីត្រីមាសទី១ មក ដោយចុះដល់ -១៥,០% នៅត្រីមាសនេះ។ កំណើនសេដ្ឋកិច្ចនៅជប៉ុនធ្លាក់ចុះដល់ -៩,៩% ហើយនៅសហរដ្ឋអាមេរិកចុះដល់ -៩,៥%។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អត្រាកំណើន ផសស នៅតំបន់អឺរ៉ូ១២ ធ្លាក់ចុះអស់ ១៦,១ឯកតាភាគរយ នៅជប៉ុនធ្លាក់ចុះអស់ ១១,១ឯកតាភាគរយ នៅសហរដ្ឋអាមេរិកធ្លាក់ចុះអស់ ១១,៨ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុន អត្រាកំណើន ផសស នៅតំបន់អឺរ៉ូធ្លាក់ចុះអស់ ១១,៧ឯកតាភាគរយ នៅជប៉ុនធ្លាក់ចុះអស់ ៧,៩ឯកតាភាគរយ នៅសហរដ្ឋអាមេរិកធ្លាក់ចុះអស់ ៩,៨ឯកតាភាគរយ។

## អត្រាអតិផរណា

សម្រាប់ប្រទេសជ្រើសរើសទាំង ១៣ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អតិផរណាបានកើនឡើងនៅ កម្ពុជា វៀតណាម និង ចិន ប៉ុន្តែធ្លាក់ចុះក្នុង ១០ប្រទេសទៀត។ បើធៀបនឹងត្រីមាសមុន ប្រទេសជ្រើសរើសទាំងអស់មានអត្រាអតិផរណាធ្លាក់ចុះ។ សម្រាប់ប្រទេសអាស៊ានជ្រើសរើស ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណានៅកម្ពុជាបានកើន ០,៧ឯកតាភាគរយ ដល់ ២,៥% ហើយនៅវៀតណាម កើន ០,១ឯកតាភាគរយ ដល់ ២,៨% ហើយអត្រាអតិផរណាទាំងពីរនេះ វាខ្ពស់ជាងគេក្នុងចំណោមប្រទេសអាស៊ាន។ ផ្ទុយទៅវិញ ថៃមានអត្រាអតិផរណាទាបជាងគេ (-២,៧%) បន្ទាប់មកគឺ ម៉ាឡេស៊ី (-២,៦%) សិង្ហបុរី (-០,៧%) និង ឥណ្ឌូនេស៊ី (២,៣%)។ ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណានៅថៃធ្លាក់ចុះ ៣,៨ឯកតាភាគរយ នៅម៉ាឡេស៊ីធ្លាក់ចុះ ៣,២ឯកតាភាគរយ នៅសិង្ហបុរីធ្លាក់ចុះ ១,៥ឯកតាភាគរយ នៅឥណ្ឌូនេស៊ីធ្លាក់ចុះ ០,៨ឯកតាភាគរយ។ ធៀបនឹងត្រីមាសមុន អត្រាអតិផរណានៅម៉ាឡេស៊ីធ្លាក់ចុះ ៣,៥ឯកតាភាគរយ នៅថៃធ្លាក់ចុះ ៣,១ឯកតាភាគរយ នៅសិង្ហបុរីធ្លាក់ចុះ ១,១ឯកតាភាគរយ និងនៅឥណ្ឌូនេស៊ីធ្លាក់ចុះ ០,៦ឯកតាភាគរយ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស ចិនមានអត្រាអតិផរណាខ្ពស់ជាងគេនៅត្រីមាសទី២ នេះ ដោយវាកើនឡើង ០,១ឯកតាភាគរយ ធៀបនឹងកាលពីមួយឆ្នាំមុន ប៉ុន្តែធ្លាក់ចុះ ១,៧ឯកតាភាគរយ ធៀបនឹងត្រីមាសមុន។ ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណានៅហុងកុងធ្លាក់ចុះ ១,៤ឯកតាភាគរយ ដល់ ១,៣% នៅកូរ៉េខាងត្បូងធ្លាក់ចុះ ០,៨ឯកតាភាគរយ ដល់ -០,១% នៅតៃវ៉ាន់ធ្លាក់ចុះ ១,៨ឯកតាភាគរយ ដល់ -១,០%។

សម្រាប់ប្រទេសឧស្សាហកម្មជ្រើសរើស អត្រាអតិផរណាបន្តធ្លាក់ចុះ ទាំងធៀបនឹងកាលពីមួយឆ្នាំមុន ទាំងធៀបនឹងត្រីមាសមុន ដោយនៅតំបន់អឺរ៉ូ វាធ្លាក់ចុះដល់ ០,៣% នៅជប៉ុនចុះដល់ ០,១% នៅសហរដ្ឋអាមេរិកចុះដល់ ០,៣%។ ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណានៅតំបន់អឺរ៉ូធ្លាក់ចុះ ១,១ឯកតាភាគរយ នៅជប៉ុនធ្លាក់ចុះ ០,៦ឯកតាភាគរយ នៅសហរដ្ឋអាមេរិកធ្លាក់ចុះ ១,៥ឯកតាភាគរយ។ ធៀបនឹងត្រីមាសមុន អត្រាអតិផរណានៅតំបន់អឺរ៉ូធ្លាក់ចុះ ០,៨ឯកតាភាគរយ នៅជប៉ុនធ្លាក់ចុះ ០,៤ឯកតាភាគរយ នៅសហរដ្ឋអាមេរិកធ្លាក់ចុះ ១,៨ឯកតាភាគរយ។

---

អត្ថបទនេះ រៀបរៀងដោយ រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៃវិទ្យាស្ថាន CDRI។

## អត្រាប្តូរប្រាក់

ធៀបនឹងត្រីមាសមុន និងទល់នឹងប្រាក់ដុល្លារអាមេរិក ប្រាក់រៀលកម្ពុជាចុះថ្លៃ ០,៩% ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ីចុះថ្លៃ ៥,១% ប្រាក់រីងហ្គីតម៉ាឡេស៊ីចុះថ្លៃ ២,៤% ប្រាក់បាតថៃចុះថ្លៃ ២,៦% ប៉ុន្តែប្រាក់ដុងវៀតណាមឡើងថ្លៃ ០,៥% រីឯប្រាក់ដុល្លារសិង្ហបុរីនៅថេរត្រឹម ១,៤ដុល្លារសិង្ហបុរី/ដុល្លារអាមេរិក។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស បើធៀបនឹងត្រីមាសមុន និងទល់នឹងប្រាក់ដុល្លារអាមេរិក គឺមានតែដុល្លារតៃវ៉ាន់ប៉ុណ្ណោះដែលបានឡើងថ្លៃ ០,៧% រីឯប្រាក់យ័នចិនចុះថ្លៃ ១,៤% ប្រាក់វ៉ុនកូរ៉េខាងត្បូងចុះថ្លៃ ២,៤% ហើយ ដុល្លារហុងកុងនៅថេរត្រឹម ៧,៨ដុល្លារហុងកុង/ដុល្លារអាមេរិក។

អត្រាប្តូរប្រាក់ អឺរ៉ូ/ដុល្លារអាមេរិក លើកលែងតែការធ្លាក់ចុះបន្តិចដល់ ០,៨អឺរ៉ូ/ដុល្លារ ក្នុងឆ្នាំ២០១៨ (អត្រាមធ្យមក្នុងឆ្នាំ២០១៥/១៤) ប្រាក់អឺរ៉ូនៅថេរត្រឹម ០,៩អឺរ៉ូ/ដុល្លារ តាំងពីឆ្នាំ២០១៥ មក។ ទល់នឹងដុល្លារអាមេរិក ប្រាក់យ៉េនជប៉ុនឡើងថ្លៃ ១,៣% ធៀបនឹងត្រីមាសមុន និងឡើងថ្លៃ ២,១% ធៀបនឹងកាលពីមួយឆ្នាំមុន។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប្រេងដូងប្រេង អង្ករ និងសណ្តែកសៀង ឡើងថ្លៃ រីឯផលិតផលឯទៀតចុះថ្លៃ និងមានតែអង្ករប៉ុណ្ណោះ ដែលបានឡើងថ្លៃធៀបនឹងត្រីមាសមុន។ ធៀបនឹងកាលពីមួយឆ្នាំមុន ប្រេងដូងប្រេងឡើងថ្លៃ ៨,១% ដល់ ៦១៤,០ដុល្លារ/តោន អង្ករឡើងថ្លៃ ២៧,៣% ដល់ ៥៤៧,៥ដុល្លារ/តោន សណ្តែកសៀងឡើងថ្លៃ ០,៥% ដល់ ៣៤៩,៤ដុល្លារ/តោន ប៉ុន្តែពោតចុះថ្លៃ ១៦,៨% ដល់ ១៤៦,៣ដុល្លារ/តោន កៅស៊ូចុះថ្លៃ ២៦,១% ដល់ ១.១៤៤,៤ដុល្លារ/តោន ប្រេងឆៅចុះថ្លៃ ៥៣,៥% ដល់ ៣០,៣ដុល្លារ/ធុង សាំងចុះថ្លៃ ៥៥,៩% ដល់ ២១,៨សេនដុល្លារ/លីត្រ ម៉ាស៊ូតចុះថ្លៃ ៥៣,០% ដល់ ២៤,០សេនដុល្លារ/លីត្រ។ ធៀបនឹងត្រីមាសមុន អង្ករឡើងថ្លៃ ១៣,៨% ប៉ុន្តែពោតចុះថ្លៃ ១២,៧% ប្រេងដូងប្រេងចុះថ្លៃ ១៥,៣% កៅស៊ូចុះថ្លៃ ១៦,៧% សណ្តែកសៀងចុះថ្លៃ ៣,១% ប្រេងឆៅចុះថ្លៃ ៣៨,៣% សាំងចុះថ្លៃ ៣៦,៣% ម៉ាស៊ូតចុះថ្លៃ ៣៨,៨%។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.4 | 7.1 | 7.0 | 7.0 | 7.0 | 7.5 | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.8 | 5.2 | 4.8 | 5.0 | 5.1 | 5.2 | 5.1 | 5.0 | 5.0 | 5.0 | 3.0 | -5.3 |
| ម៉ាឡេស៊ី | 4.6 | 6.0 | 4.9 | 4.3 | 5.9 | 4.8 | 4.5 | 4.9 | 4.4 | 3.6 | 0.7 | -17.1 |
| សិង្ហបុរី | 3.8 | 3.0 | 2.0 | 2.0 | 3.8 | 3.2 | 1.3 | 0.1 | 0.5 | 0.8 | -2.2 | -13.2 |
| ថៃ | 2.8 | 1.6 | 2.8 | 3.2 | 3.8 | 4.1 | 2.8 | 2.3 | 2.4 | 1.6 | -1.8 | -12.2 |
| វៀតណាម | 5.4 | 5.9 | 6.6 | 6.1 | 6.6 | 7.2 | 6.8 | 6.7 | 7.3 | 7.0 | 3.8 | 0.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.7 | 7.3 | 7.0 | 6.7 | 6.9 | 6.6 | 6.4 | 6.2 | 6.0 | 6.0 | -6.8 | 3.2 |
| ហុងកុង | 3.0 | 2.3 | 2.3 | 1.7 | 2.8 | 3.1 | 0.6 | 0.5 | 2.9 | -2.9 | -8.9 | -9.0 |
| កូរ៉េខាងត្បូង | 2.8 | 3.4 | 2.6 | 2.6 | 3.0 | 3.0 | 1.8 | 2.1 | 2.0 | 3.4 | 1.3 | -3.0 |
| តៃវ៉ាន់ | 2.2 | 3.5 | 0.6 | 1.2 | 2.8 | 2.6 | 1.7 | 2.4 | 3.0 | 3.3 | 1.5 | -0.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.1 | 0.7 | 1.3 | 1.6 | 2.3 | 1.9 | 1.2 | 1.1 | 1.2 | 1.0 | -3.3 | -15.0 |
| ជប៉ុន | 1.7 | 0.6 | 0.3 | 0.9 | 1.8 | 0.6 | 0.9 | 1.2 | 1.7 | -0.7 | -2.0 | -9.9 |
| សហរដ្ឋអាមេរិក | 1.8 | 2.4 | 2.3 | 1.6 | 2.3 | 3.0 | 3.2 | 2.3 | 2.1 | 2.3 | 0.3 | -9.5 |

Sources: International Monetary Fund; *Economist*; countries' statistics offices

## តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.0 | 3.9 | 1.2 | 3.0 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.1 | 3.0 | 2.5 |
| ឥណ្ឌូនេស៊ី | 7.0 | 6.4 | 6.4 | 3.5 | 3.8 | 3.2 | 2.6 | 3.1 | 3.4 | 2.9 | 2.9 | 2.3 |
| ម៉ាឡេស៊ី | 2.1 | 3.2 | 2.1 | 2.1 | 3.9 | 1.0 | -0.3 | 0.6 | 1.3 | 1.0 | 0.9 | -2.6 |
| សិង្ហបុរី | 2.3 | 1.0 | -0.5 | -0.8 | 0.6 | 0.4 | 0.5 | 0.8 | 0.5 | 0.6 | 0.4 | -0.7 |
| ថៃ | 2.2 | 1.9 | -0.9 | 0.2 | 0.7 | 1.1 | 0.7 | 1.1 | 0.6 | 0.4 | 0.4 | -2.7 |
| វៀតណាម | 6.6 | 4.8 | 0.6 | 2.7 | 3.4 | 3.6 | 2.6 | 2.7 | 2.2 | 3.7 | 5.6 | 2.8 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.6 | 2.0 | 1.4 | 2.0 | 1.6 | 2.1 | 1.8 | 2.6 | 2.9 | 4.3 | 4.4 | 2.7 |
| ហុងកុង | 4.0 | 4.4 | 3.1 | 2.5 | 1.7 | 2.4 | 2.2 | 2.7 | 3.4 | 3.0 | 2.0 | 1.3 |
| កូរ៉េខាងត្បូង | 1.1 | 1.3 | 0.7 | 0.8 | 2.0 | 1.4 | 0.6 | 0.7 | 0.1 | 0.3 | 1.2 | -0.1 |
| តៃវ៉ាន់ | 0.8 | 1.5 | 0.6 | 1.4 | 0.6 | 1.4 | 0.3 | 0.8 | 0.4 | 0.7 | 0.6 | -1.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.4 | 0.0 | 0.3 | 1.5 | 1.8 | 1.4 | 1.4 | 1.0 | 1.0 | 1.1 | 0.3 |
| ជប៉ុន | 0.4 | 2.8 | 0.9 | -0.1 | 0.6 | 1.0 | 0.3 | 0.7 | 0.3 | 0.5 | 0.5 | 0.1 |
| សហរដ្ឋអាមេរិក | 1.5 | 1.6 | 0.0 | 1.2 | 2.1 | 2.5 | 1.7 | 1.8 | 1.7 | 2.1 | 2.1 | 0.3 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

## តារាង៣៖ អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4027.2 | 4037.6 | 4060.4 | 4053.6 | 4047.0 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 | 4101.4 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10419.2 | 11850.2 | 13394.8 | 13338.3 | 13379.8 | 14227.6 | 14127.8 | 14246.8 | 14117.6 | 14060.5 | 14220.3 | 14944.2 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.1 | 3.3 | 3.9 | 4.1 | 4.3 | 4.0 | 4.1 | 4.1 | 4.2 | 4.2 | 4.2 | 4.3 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 30.7 | 32.5 | 34.2 | 35.3 | 33.9 | 32.3 | 31.6 | 31.6 | 30.7 | 30.3 | 31.2 | 32.0 |
| វៀតណាម (ដុង) | 20990.3 | 21138.2 | 21917.7 | 22507.5 | 22645.9 | 22663.3 | 22902.9 | 23255.5 | 23258.3 | 23217.3 | 23351.0 | 23244.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.1 | 6.2 | 6.3 | 6.6 | 6.8 | 6.6 | 6.7 | 6.8 | 7.0 | 7.0 | 7.0 | 7.1 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1095.0 | 1053.6 | 1131.9 | 1161.0 | 1130.5 | 1099.9 | 1125.0 | 1165.4 | 1193.4 | 1174.7 | 1191.5 | 1219.8 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់) | 29.7 | 30.3 | 31.8 | 32.3 | 30.4 | 30.1 | 30.8 | 31.1 | 31.2 | 30.5 | 30.1 | 29.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 97.6 | 105.9 | 121.0 | 108.8 | 112.1 | 110.4 | 110.1 | 109.9 | 107.3 | 108.7 | 109.0 | 107.6 |

Sources: International Monetary Fund; *Economist*; National Bank of Cambodia

## តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១៣-២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 259.4 | 192.9 | 169.8 | 159.2 | 154.5 | 164.4 | 167.5 | 175.9 | 170.1 | 166.8 | 167.6 | 146.3 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 856.9 | 821.4 | 622.7 | 643.6 | 714.7 | 638.7 | 586.9 | 568.1 | 570.1 | 680.2 | 724.7 | 614.0 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 2575.3 | 1755.6 | 1392.7 | 1416.1 | 1688.3 | 1401.4 | 1436.6 | 1549.5 | 1389.7 | 1410.1 | 1374.4 | 1144.4 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 533.8 | 434.9 | 395.5 | 406.7 | 452.3 | 444.2 | 426.7 | 430.0 | 439.7 | 442.7 | 481.3 | 547.5 |
| សណ្ដែកសៀង (US No.1) - USA (ដុល្លារ/តោន) | 538.4 | 491.8 | 390.4 | 405.7 | 400.6 | 405.4 | 353.3 | 347.8 | 339.7 | 347.3 | 360.7 | 349.4 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 105.9 | 96.2 | 49.6 | 40.7 | 52.6 | 69.5 | 60.5 | 65.1 | 59.7 | 60.3 | 49.1 | 30.3 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 71.2 | 65.6 | 41.0 | 35.2 | 42.4 | 49.6 | 40.9 | 49.4 | 46.0 | 43.3 | 34.2 | 21.8 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 78.4 | 71.5 | 41.7 | 34.8 | 42.9 | 53.8 | 49.5 | 51.1 | 48.9 | 49.4 | 39.2 | 24.0 |

Sources: Food and Agriculture Organisation; US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី២ ឆ្នាំ២០២០ ការអនុម័តវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់សរុប ធ្លាក់ចុះ ៥៣,២% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ត្រឹម ១.២៥៤,១លានដុល្លារ ប៉ុន្តែកើន ៣៦,៩% ធៀបនឹងត្រីមាសមុន។ ការធ្លាក់ចុះធៀបនឹងឆ្នាំមុននេះ បង្កជាសំខាន់ដោយសារការអនុម័តវិនិយោគបានធ្លាក់ចុះ ២៥,៧% ក្នុងវិស័យកសិកម្ម ៨០,៩% ក្នុងវិស័យសេវាកម្ម ៩២,០% ក្នុងផ្នែកសណ្ឋាគារ និងទេសចរណ៍ ប៉ុន្តែក៏មានការជំរុញឡើងដោយសារកំណើនការអនុម័តវិនិយោគ ៥៤៨,២% ក្នុងវិស័យឧស្សាហកម្ម និង ៦១,៣% ក្នុងផ្នែកកាត់ដេរសម្លៀកបំពាក់ដែរ។ ធៀបនឹងត្រីមាសមុន កំណើនក្នុងត្រីមាសទី២ នេះ បង្កឡើងដោយសារកំណើនការអនុម័តវិនិយោគ ២១៥,០% ក្នុងវិស័យឧស្សាហកម្ម និង ៥២,២% ក្នុងផ្នែកសណ្ឋាគារនិងទេសចរណ៍ គួបផ្សំនឹង ការអនុម័តវិនិយោគ ៣៥,៨លានដុល្លារ ក្នុងវិស័យកសិកម្ម ដែលកាលពីត្រីមាសមុនគ្មានការអនុម័តវិនិយោគសោះ។

ភ្ញៀវទេសចរណ៍អន្តរជាតិមកដល់កម្ពុជានៅត្រីមាសទី២ នេះ បានថយចុះ ៩៧,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងថយចុះ ៩៣,៩% ធៀបនឹងត្រីមាសមុន។ ក្នុងត្រីមាសនេះ ភ្ញៀវមកពីចិនមានច្រើនជាងគេ (១៥.៩៤១នាក់) បន្ទាប់មកគឺ ភ្ញៀវមកពីថៃ (៨.៤៣០នាក់) ពីកូរ៉េខាងត្បូង (៩៦២នាក់) ពីសហរដ្ឋអាមេរិក (២៥៩នាក់) ពីវៀតណាម (២៤៨នាក់) ពីជប៉ុន (១៧៨នាក់) ពីអង់គ្លេស (៩៥នាក់) ពីម៉ាឡេស៊ី (៦៩នាក់) ពីបារាំង (៦៥នាក់) និងពីប្រទេសផ្សេងៗទៀត ៨.៥០០នាក់។

ការនាំចេញសរុបកើន ២៥,៨% ធៀបនឹងកាលពីមួយឆ្នាំមុន ឬកើន ១៩,៨% ធៀបនឹងត្រីមាសមុន។ កំណើនធៀបនឹងឆ្នាំមុននេះ ជំរុញឡើងជាសំខាន់ដោយសារកំណើនការនាំចេញ ក្នុងផ្នែកគ្រឿងបង្គុំរថយន្ត (១៣៦,៣%) ផលិតផលកសិកម្ម (៧១,៤%) និងទំនិញផ្សេងទៀត (២៣៩,៥%)។ ការនាំចេញបីមុខនេះ ជាកត្តាជំរុញកំណើនការនាំចេញសរុប ធៀបនឹងត្រីមាសមុន ដោយបានកើនឡើង ៦៥,៤% ១៥,៨% និង ២៦១,១% រៀងគ្នា។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ការនាំចេញសម្លៀកបំពាក់ធ្លាក់ចុះ ២១,៥% ដោយសារមានការធ្លាក់ចុះតម្រូវការ នៅគ្រប់ប្រទេសនាំចូលលើកលែងតែអាស៊ាន។ តម្រូវការនៅសហរដ្ឋអាមេរិកថយចុះ ១៣,៥% នៅសហភាពអឺរ៉ុបចុះ ២៧,៦% នៅជប៉ុនចុះ ១០,៩% នៅអង់គ្លេសចុះ ៣០,៩% និងនៅប្រទេសផ្សេងទៀតចុះ ២៨,៧% ប៉ុន្តែនៅអាស៊ានកើន ៣២,២%។ ធៀបនឹងត្រីមាសមុន ការនាំចេញសម្លៀកបំពាក់ទៅ សហរដ្ឋអាមេរិកធ្លាក់ចុះ ២៦,៦% ទៅសហភាពអឺរ៉ុបចុះ ១៧,៩% ទៅជប៉ុនចុះ ៤០,៤% ទៅអង់គ្លេសចុះ ២៨,២% និងទៅប្រទេសផ្សេងទៀតចុះ ២៥,៨% ប៉ុន្តែការនាំចេញសម្លៀកបំពាក់ទៅអាស៊ាននៅថេរ។ ថ្វីបើមានការធ្លាក់ចុះធៀបនឹងកាលពីមួយឆ្នាំមុន និងធៀបនឹងកាលពីត្រីមាសមុនក្តី ប៉ុន្តែការនាំចេញសម្លៀកបំពាក់ នៅតែមានចំណែកធំជាងគេដល់ ៤៦,៧% នៃការនាំចេញសរុប បន្ទាប់មកគឺ ផលិតផលផ្សេងៗទៀត (៤២,៦%) ផលិតផលកសិកម្ម (៧,២%) គ្រឿងអេឡិចត្រូនិក (២,៦%) គ្រឿងបង្គុំរថយន្ត (១,០%)។ ការនាំចេញអង្ករមានចំណែកធំជាងគេ (៣៤,៦%) ក្នុងការនាំចេញផលិតផលកសិកម្មសរុប បន្ទាប់មកគឺ ឈើ (៣០,៨%) ផលិតផលកសិកម្មផ្សេងទៀត (២១,៤%) កៅស៊ូ (១៣,១%) និង ត្រី (០,០៣%)។ ការនាំចេញផលិតផលកសិកម្មគិតតាមផ្នែក បង្ហាញនូវការធ្លាក់ចុះក្នុងផ្នែកកៅស៊ូ ៥,២% ធៀបនឹងឆ្នាំមុន និងកំណើនគួរឲ្យកត់សំគាល់ក្នុងផ្នែក ឈើ (១៦៦,៥%) ផលិតផលកសិកម្មផ្សេងទៀត (១៣១,៧%) និង អង្ករ (៤៦,១%)។ ការនាំចេញត្រីនៅថេរត្រឹម ០,១លានដុល្លារ។ ធៀបនឹងត្រីមាសមុន មានតែការនាំចេញអង្ករប៉ុណ្ណោះដែលបានធ្លាក់ចុះ ២៧,៧% រីឯការនាំចេញផលិតផលផ្សេងទៀតបានកើនឡើង ក្នុងនេះ ឈើកើន ១១៣,២% ផលិតផលកសិកម្មផ្សេងទៀតកើន ៥៤,៣% កៅស៊ូកើន ២៩,៩% រីឯការនាំចេញត្រីនៅថេរ។

ការនាំចូលសរុបធ្លាក់ចុះ ១៨,១% ធៀបនឹងកាលពីមួយឆ្នាំមុន និងធ្លាក់ចុះ ១៦,១% ធៀបនឹងត្រីមាសមុន។ ការនាំចូលទំនិញផ្សេងទៀតមានចំណែកធំជាងគេ (៨៦,២%) ក្នុងការនាំចូលសរុប បន្ទាប់មកគឺ ម៉ាស៊ូត (៦,១%) សម្ភារសំណង់ (៤,៩%) សាំង (២,៨%)។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ការនាំចូលសាំងកើន ៤,៧% ម៉ាស៊ូតកើន ៦,០% ប៉ុន្តែការនាំចូលទំនិញផ្សេងទៀតធ្លាក់ចុះ ២០,៥% សម្ភារសំណង់ធ្លាក់ចុះ ៧,៧%។ ធៀបនឹងត្រីមាសមុន ការនាំចូលម៉ាស៊ូតកើន ៦,៩% សម្ភារសំណង់កើន ២០,៦% ប៉ុន្តែការនាំចូលទំនិញផ្សេងទៀតធ្លាក់ចុះ ១៩,៩% សាំងធ្លាក់ចុះ ៦,៧%។

ជញ្ជីងពាណិជ្ជកម្មក្នុងត្រីមាសទី២ នៅតែអវិជ្ជមាន ដោយមានឱនភាព ១១០,១លានដុល្លារ ប៉ុន្តែតួលេខនេះបានល្អឡើងគួរឲ្យកត់សំគាល់ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន (ឱនភាព ១.៩៩០,៦លានដុល្លារ) និងធៀបនឹងត្រីមាសមុន (ឱនភាព ១.៧០០,៩លានដុល្លារ)។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី២ ឆ្នាំ២០២០ ចំណូលសរុបរបស់រដ្ឋាភិបាលធ្លាក់ចុះ ១២,៦%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែកើន ០,២% ធៀបនឹងត្រីមាសមុន។ ចំណូលចរន្តធ្លាក់ចុះ ១២,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងធ្លាក់ចុះ ០,៤% ធៀបនឹងត្រីមាសមុន។ ការធ្លាក់ចុះធៀបនឹងកាលពីឆ្នាំមុននេះ កើតមានឡើងដោយសារការធ្លាក់ចុះ ៧,៥% ក្នុងចំណូលពន្ធ ដែលបង្កឡើងដោយសារពន្ធក្នុងស្រុកធ្លាក់ចុះ ៣,២% ពន្ធលើពាណិជ្ជកម្មអន្តរជាតិធ្លាក់ចុះ ៣៧,៥% ចំណូលមិនមែនពន្ធធ្លាក់ចុះ ៥៩,៤%។ ការធ្លាក់ចុះយ៉ាងខ្លាំងក្នុងចំណូលមិនមែនពន្ធ បង្កឡើងដោយសារ ចំណូលលើការលក់ទំនិញនិងសេវាធ្លាក់ចុះ ៦០,២% ចំណូលមិនមែនពន្ធផ្សេងទៀតធ្លាក់ចុះ ៤៩,២% ទោះបីមានការប៉ះប៉ូវដោយកំណើន

---

អត្ថបទនេះ រៀបរៀងដោយ រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

៨,២% ក្នុងចំណូលលើទ្រព្យសម្បត្តិក្ដី។ ដោយឡែក ចំណូលជាមូលធនបានកើន ៤៥,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ប៉ុន្តែបើធៀបនឹងត្រីមាសមុន ចំណូលពន្ធកើន ១១,៥% ចំណូលជាមូលធនកើន ១៥១,៥% ប៉ុន្តែចំណូលមិនមែនពន្ធធ្លាក់ចុះ ៦៧,៧%។

ចំណាយរដ្ឋាភិបាលសរុបកើន ២៦,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងកើន ១៩,៦% ធៀបនឹងត្រីមាសមុន។ ធៀបនឹងកាលពីមួយឆ្នាំមុន ចំណាយជាមូលធនកើន ៦៤,៤% ហើយចំណាយចរន្តកើន ១២,៤% ដែលជំរុញឡើងដោយសារចំណាយលើបៀវត្សរ៍កើន ១,២% ចំណាយលើឧបត្ថម្ភធននិងជំនួយសង្គមកើន ៣៥,២% ចំណាយចរន្តផ្សេងទៀតកើន ២៥,១%។ បើធៀបនឹងត្រីមាសមុន ចំណាយជាមូលធនកើន ៨១,៨% ហើយចំណាយចរន្តកើន ០,៣% ដោយសារចំណាយលើឧបត្ថម្ភធននិងជំនួយសង្គមកើន ១១,៤% ចំណាយចរន្តផ្សេងទៀតកើន ៦,៨% ទោះបីចំណាយលើបៀវត្សរ៍បានធ្លាក់ចុះ ៦,០% ក្ដី។

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី២ ឆ្នាំ២០២០ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ (CPI) នៅភ្នំពេញ កើន ០,៧ឯកតាភាគរយ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែថយចុះ ០,៥ឯកតាភាគរយ ធៀបនឹងត្រីមាសមុន។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន សន្ទស្សន៍ថ្លៃស្បៀងអាហារនិងភេសជ្ជៈមិនមែនស្រា កើន ៣,៣ឯកតាភាគរយ ប៉ុន្តែសន្ទស្សន៍ថ្លៃដឹកជញ្ជូនថយចុះ ៩,៣ឯកតាភាគរយ។

ធៀបនឹងត្រីមាសមុន ប្រាក់រៀលចុះថ្លៃ ០,៦% ទល់នឹងប្រាក់ដុល្លារ ដល់ ៤.០៨៧,០រៀល/ដុល្លារ និងចុះថ្លៃ ០,៦% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៧,៧រៀល/១០០ដុង ប៉ុន្តែឡើងថ្លៃ ២,៤% ទល់នឹងប្រាក់បាតថៃ ដល់ ១២៧,៥រៀល/បាត។

មាសចុះថ្លៃ ១,៥% ធៀបនឹងត្រីមាសមុន ដល់ ១៨៥,៥ ដុល្លារ/ជី ម៉ាស៊ូតចុះថ្លៃ ២៨,៤% ដល់ ២.៣៩៩,០រៀល/លីត្រ ហើយសាំងចុះថ្លៃ ២៩,៨% ដល់ ២.៤៨៣,៨រៀល/លីត្រ។

## អង្កេតលើពលករងាយរងគ្រោះ

ផ្នែកនេះ ពិពណ៌នាពីស្ថានភាពរបស់ពលករងាយរងគ្រោះ ដោយប្រើទិន្នន័យបានពីអង្កេតរបស់ CDRI នៅខែសីហា ២០២០ (ត្រីមាសទី៣) លើពលករងាយរងគ្រោះ ៤៨០នាក់ ក្នុងនោះមានកម្មកររោងចក្រកាត់ដេរ ១២០នាក់ និង ពលករក្នុង ៩ក្រុមទៀត ៣៦០នាក់ (សូមមើលតារាង៨)។ ក្នុងចំណោមពលករងាយរងគ្រោះទាំង ១០ប្រភេទ កម្មករសំណង់មានជំនាញមានប្រាក់ចំណូលប្រចាំថ្ងៃខ្ពស់ជាងគេ (៣១.២៩៨រៀល) បន្ទាប់មកគឺ អ្នកលក់បន្លែតូចតាច (១៩.៤៧៩រៀល) កម្មករសំណង់គ្មានជំនាញ (១៧.៨៧០រៀល) អ្នកលីសែង (១៥.៣៤៦រៀល) អ្នករត់ម៉ូតូឌុប (១៥.២១០រៀល) កម្មកររោងចក្រកាត់ដេរ (១៤.២១១រៀល) អ្នករត់ស៊ីក្លូ (១០.៧៧៩រៀល) អ្នករើសអេតចាយ (១០.៧៤២រៀល)។ ពលករពីរក្រុមដែលមានប្រាក់ចំណូលប្រចាំថ្ងៃទាបជាងគេ គឺ អ្នកស៊ីឈ្នួលធ្វើស្រែ (៨.៧១២រៀល) និង អ្នករត់តុភោជនីយដ្ឋាន (៨.៩៩៧រៀល)។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះ មានការប្រែប្រួលគួរឲ្យកត់សំគាល់ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងធៀបនឹងត្រីមាសមុន។ ធៀបនឹងកាលពីមួយឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃ បានកើនឡើងសម្រាប់ពលករបួនប្រភេទ ពោលគឺ កម្មករសំណង់មានជំនាញ (កើន ២៤,០%) អ្នករត់ម៉ូតូឌុប (៧,០%) អ្នករត់តុភោជនីយដ្ឋាន (៥,១%) អ្នកលក់បន្លែតូចតាច (១,៥%) ប៉ុន្តែបានធ្លាក់ចុះសម្រាប់ អ្នករើសអេតចាយ (ចុះ ១៨,១%) កម្មកររោងចក្រកាត់ដេរ (១១,៦%) អ្នកលីសែង (៧,៣%) អ្នកស៊ីឈ្នួលធ្វើស្រែ (៥,១%) អ្នករត់ស៊ីក្លូ (៣,០%) កម្មករសំណង់គ្មានជំនាញ (២,៥%)។ ធៀបនឹងត្រីមាសមុន ប្រាក់ចំណូលប្រចាំថ្ងៃបានកើនឡើងសម្រាប់ អ្នករត់ម៉ូតូឌុប (កើន ៦៧,៥%) អ្នករើសអេតចាយ (២៩,១%) អ្នករត់ស៊ីក្លូ (១៨,៧%) កម្មករសំណង់មានជំនាញ (១៦,៩%) កម្មកររោងចក្រកាត់ដេរ (៧,១%) អ្នករត់តុភោជនីយដ្ឋាន (៦,៩%) ប៉ុន្តែបានធ្លាក់ចុះសម្រាប់ អ្នកលីសែង (ចុះ ១៤,១%) កម្មករសំណង់គ្មានជំនាញ (៩,៥%) អ្នកលក់បន្លែតូចតាច (៣,៥%) អ្នកស៊ីឈ្នួលធ្វើស្រែ (១,១%)។ ទោះបីប្រាក់ចំណូលប្រចាំថ្ងៃរបស់ អ្នករត់ស៊ីក្លូ អ្នករត់ម៉ូតូឌុប និង អ្នករើសអេតចាយ បានកើនឡើងធៀបនឹងត្រីមាសមុនក្ដី ប៉ុន្តែវានៅទាបជាងត្រីមាសទី១ ឆ្នាំ២០២០ ពីព្រោះវាបានធ្លាក់ចុះខ្លាំងនៅត្រីមាសទី២។

ក្នុងរបាយការណ៍នេះ ក្រៅពីកម្មកររោងចក្រកាត់ដេរ ពលករងាយរងគ្រោះប្រភេទផ្សេងទៀត ត្រូវបានបែងចែកជាបីអនុក្រុម ដោយផ្អែកលើប្រាក់ចំណូលប្រចាំថ្ងៃ ពោលគឺ អនុក្រុមមានចំណូលប្រចាំថ្ងៃ តិចជាង ១០.០០០រៀល, ពី ១០.០០០រៀល ដល់ ១៥.០០០រៀល, និង ច្រើនជាង ១៥.០០០រៀល។ ការប្រែប្រួលក្នុងប្រាក់ចំណូលរបស់ពលករក្នុងអនុក្រុមទាំងនេះ និងក្នុងចំណោមកម្មកររោងចក្រកាត់ដេរ មានពិពណ៌នានៅខាងក្រោម។

ដូចបានលើកនៅខាងលើ អ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នករត់តុភោជនីយដ្ឋាន រកចំណូលប្រចាំថ្ងៃបានតិចជាងគេ ហើយភាគច្រើនមកពីបួនខេត្ត គឺ កណ្ដាល (៣៧,៥%) កំពង់ស្ពឺ (១៥,០%) កំពត (១០,០%) ព្រៃវែង (១០,០%)។ ពួកគាត់ ៥១,៣% មានដីកសិកម្មតិចជាង ១ហិកតា, ១៦,៣% មាន ១ហិកតា, ១០,០០% មាន ១,៥-២ហិកតា, ហើយ ២៥,០% គ្មានដីកសិកម្មទេ។ ពួកគាត់ភាគច្រើនមកពីគ្រួសារធំៗ មានសមាជិកពី ៥-៨នាក់ (៦៥,៨%), មានសមាជិក ៤នាក់ (២៣,៨%), មានសមាជិកត្រឹមឬតិចជាង ៣នាក់ (១០,០%)។ តាមគាត់រាយការណ៍ប្រាប់ មាន ៧០% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ៣០,០% មិនមែនជាអ្នករកចំណូលចម្បងទេ ១០០,០% ធ្វើចំណាកស្រុកតែម្នាក់ឯងមកធ្វើការនៅទីក្រុង ហើយ ៩៧,៥% ធ្វើការនៅទីក្រុងរហូតដល់ ១២ខែក្នុងមួយឆ្នាំ។ ពួកគាត់ ៦០,០% បានធ្វើការជាអ្នកស៊ីឈ្នួលធ្វើស្រែ ឬអ្នករត់តុភោជនីយដ្ឋាន បាន ១-៣ឆ្នាំ ៣៧,៥% ធ្វើបានជាង ៣ឆ្នាំ និង ២,៥% បានតិចជាង ១ឆ្នាំ។ តបនឹងសំណួរ "តើប្រាក់ចំណូលរបស់អ្នកអាចផ្គត់ផ្គង់គ្រួសារបានឬទេ?" មាន ៧៨,៨% ប្រាប់ថា "បានមួយភាគ" ១១,៣% ប្រាប់ថា "ផ្គត់ផ្គង់បាន" និង ១០,០% ថា "មិនបានទេ"។ ប្រាក់ចំណូលរបស់គាត់ចំណាយជាសំខាន់លើ ស្បៀងអាហារ

(៦២,៦%) ចំណាយផ្សេងទៀត (២៩,៩%) ការថែទាំសុខភាព (៧,៤%) កន្លែងស្នាក់នៅ (០,២%)។

អ្នករត់ស៊ីក្លូ និងអ្នករើសអេតចាយ ស្ថិតក្នុងក្រុមមានប្រាក់ចំណូល ១០.០០០-១៥.០០០រៀល/ថ្ងៃ ហើយភាគច្រើនមកពីប្រាំខេត្ត គឺ ព្រៃវែង (៣៨,៦%) តាកែវ (២១,៣%) កណ្តាល (១៣,៨%) កំពង់ស្ពឺ (១០,០%) ស្វាយរៀង (៨,៨%)។ ពួកគាត់ ៥២,៥% គ្មានដីកសិកម្មទេ ៣០,០% មានតិចជាង ១ហិកតា, ៨,៨% មាន ១ហិកតា, ៥,០% មាន ២ហិកតា, ៣,៧៥% មាន ១,៥ហិកតា។ ពួកគាត់ភាគច្រើនមកពីគ្រួសារធំៗ មានសមាជិកលើសពី ៥នាក់ (៦២,៥%) មានសមាជិក ៤នាក់ (២១,៣%) មានសមាជិកត្រឹមឬតិចជាង ៣នាក់ (១៦,២៥%)។ ពួកគាត់ ៩២,៥% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ៥១,៣% ធ្វើចំណាកស្រុកតែម្នាក់ឯងមកទីក្រុង ៤៨,៨% ធ្វើចំណាកស្រុកមកជាមួយគ្រួសារ ហើយ ៨៦,៣% មកធ្វើការជាអ្នករត់ស៊ីក្លូ ឬអ្នករើសអេតចាយរហូតដល់ ១០-១២ខែ/ឆ្នាំ។ ប្រាក់ចំណូលរបស់គាត់ចំណាយជាសំខាន់លើ ស្បៀងអាហារ (៧៣,៦%) កន្លែងស្នាក់នៅ (១២,២%) ចំណាយផ្សេងទៀត (៩,០%) ការថែទាំសុខភាព (៥,១%) និង ការដឹកជញ្ជូន (០,០៩%)។

អ្នកលីសែង អ្នកលក់បន្លែតូចតាច អ្នករត់ម៉ូតូឌុប កម្មករសំណង់គ្មានជំនាញ និង កម្មករសំណង់មានជំនាញ រកចំណូលបានលើសពី ១៥.០០០រៀល/ថ្ងៃ ហើយភាគច្រើនមកពីខេត្ត ព្រៃវែង (៣០,៥%) ស្វាយរៀង (២៤,០%) កណ្តាល (៧,៥%) ភ្នំពេញ (៦,៥%)។ ពួកគាត់ ២៨,០% គ្មានដីកសិកម្មទេ ២៧,៥% មានតិចជាង ១ហិកតា, ២៦,០% មានច្រើនជាង ១ហិកតា, ១៨,៥% មាន ១ហិកតា។ ពួកគាត់ច្រើនមកពីគ្រួសារធំៗ មានសមាជិកពី ៥-៨នាក់ (៤៣,០%) មានសមាជិក ៤នាក់ (២៥,០%) មានសមាជិកត្រឹម ឬតិចជាង ៣នាក់ (១៣,០%) មានសមាជិកត្រឹមឬច្រើនជាង ៩នាក់ (៣,០%)។ ពួកគាត់ ៩១,៥% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយ ៤៧,៥% មកធ្វើការជាអ្នកលីសែង អ្នកលក់បន្លែតូចតាច អ្នករត់ម៉ូតូឌុប កម្មករសំណង់គ្មានជំនាញ ឬ កម្មករសំណង់មានជំនាញ ១២ខែ/ឆ្នាំ, ១៨,០% មកធ្វើការ ១០ខែ/ឆ្នាំ, ១០,០% មក ៦ខែ, ៧,០% មក ៨ខែ, ៥,០% មក ៩ខែ, ៤,៥% មក ៧ខែ, ៣,០% មក ៥ខែ, ៤,០% មក ១១ខែ, ០,៥% មកត្រឹម ៣ខែ។ ប្រាក់ចំណូលរបស់គាត់ចំណាយជាសំខាន់លើ ស្បៀងអាហារ (៧១,៦%) កន្លែងស្នាក់នៅ (១៤,៩%) ចំណាយផ្សេងទៀត (៥,៤%) ការថែទាំសុខភាព (៤,២%) និង ការដឹកជញ្ជូន (៣,៨%)។

កម្មកររោងចក្រកាត់ដេរ រកចំណូលបានជាមធ្យម ១៤.២១១រៀល/ថ្ងៃ។ ពួកគាត់មកពី ១៦ខេត្ត មានជាអាទិ ព្រៃវែង (២៥,៨%) កណ្តាល (១៣,៣%) តាកែវ (១០,៨%) កំពង់ចាម (៩,២%) កំពង់ធំ (៩,២%) កំពង់ស្ពឺ (៧,៥%) ។ ពួកគាត់ ៣៩,២% គ្មានដីកសិកម្មទេ ២៥,០% មានតិចជាង ១ហិកតា, ២០,០% មាន ១ហិកតា, ៩,២% មាន ២ហិកតា, ៤,២% មាន ១,៥ហិកតា, ២,៥% មាន ២,៥-៤ហិកតា។ ក្នុងចំណោមកម្មកររោងចក្រកាត់ដេរឆ្លើយសម្ភាសន៍ មាន ៤៤,២% មកពីគ្រួសារធំៗមានសមាជិកត្រឹមឬច្រើនជាង ៥នាក់, ៣០,០% មកពីគ្រួសារមានសមាជិក ៤នាក់, ២៥,៨% មកពីគ្រួសារមានសមាជិកត្រឹមឬតិចជាង ៣នាក់។ តបនឹងសំណួរ "តើប្រាក់ចំណូលរបស់អ្នកអាចផ្គត់ផ្គង់គ្រួសារបានឬទេ?" មាន ៤៧,៥% ប្រាប់ថា "បានមួយភាគ" ២៨,៣% ប្រាប់ថា "ផ្គត់ផ្គង់បាន" និង ២៤,២% ថា "មិនបានទេ"។ ប្រាក់ចំណូលរបស់គាត់ចំណាយជាសំខាន់លើ ស្បៀងអាហារ (៦៧,៤%) កន្លែងស្នាក់នៅ (២៤,២%) ចំណាយផ្សេងទៀត (៥,៧%) ការថែទាំសុខភាព (២,១%) និង ការដឹកជញ្ជូន (០,៧%)។

---

*តពីទំព័រ ២៦* **ព័ត៌មានថ្មីៗ...**

មជ្ឈមណ្ឌលនេះ បានទទួលស្វាគមន៍ ជាអ្នកស្រាវជ្រាវស្ត្រីចូលថ្មី គាំង សារ៉ែន ដែលមានបទពិសោធន៍ក្នុងការស្រាវជ្រាវខាងផ្នែកយេនឌ័រ និងការអភិវឌ្ឍ ព្រមទាំង អ្នកហាត់ការចូលថ្មីពីរនាក់ គឺ គីម ឆាយណា និង សេង សុគន្ធពិសិដ្ឋ។

### មជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ (CPARD)

មានគម្រោងប្រាំកំពុងអនុវត្តទៅមុខៗ។ ការប្រមូលទិន្នន័យសម្រាប់គម្រោងផ្តល់មូលនិធិដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ស្តីពី *ការវិភាគយេនឌ័រ និងការអភិវឌ្ឍសម្រាប់គ្រប់គ្នា (GIDA)* បានចប់រួចរាល់នៅដើមខែសីហា ហើយការវិភាគទិន្នន័យ និងការសរសេររបាយការណ៍បានជឿនលឿនទៅមុខយ៉ាងល្អ។ ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍ សម្រាប់គម្រោងផ្តល់មូលនិធិដោយ Sida ស្តីពី *ការអនុវត្តស្តង់ដាសុវត្ថិភាពក្នុងសាកវប្បកម្មនៅកម្ពុជា៖ ករណីដំណាំបន្លែ* បានចប់សព្វគ្រប់ ហើយរបាយការណ៍បានផ្ញើជូនអ្នកជួយពិនិត្យ និងអ្នកកែសម្រួលអត្ថបទ រួចហើយ។ ឯកសារគោលគំនិត បានចងក្រងស្រេចបាច់សម្រាប់គម្រោង *ការដាក់បញ្ចូលកសិករខ្នាតតូច ទៅក្នុងបណ្តាញពាណិជ្ជកម្មតាមរយៈភាពជាដៃគូរវាង វិស័យសាធារណៈនិងឯកជន* ដែលជាការសិក្សាស្រាវជ្រាវទី១ នៅក្នុងគម្រោងថ្នាក់តំបន់នៃ *បណ្តាញក្រុមផ្តល់គំនិតផ្នែកកសិកម្ម និងអភិវឌ្ឍន៍ជនបទ សម្រាប់បណ្តាប្រទេសនៅមហាអនុតំបន់មេគង្គ* (NARDT) និងផ្តល់ថវិកាដោយ មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)។ ការសរសេររបាយការណ៍សម្រាប់គម្រោងផ្តល់មូលនិធិដោយ Sida ស្តីពី *ការវិភាគខ្សែសង្វាក់តម្លៃផ្លែស្វាយ* ត្រូវពន្យាពេលមួយរយៈដោយសារក្រុមស្រាវជ្រាវកំពុងមមាញឹកក្នុងគម្រោង GIDA ។ ឯកសារគោលគំនិតសម្រាប់គម្រោងផ្តល់មូលនិធិដោយ Sida ស្តីពី *ស្ថានភាពបច្ចុប្បន្ននៃឧស្សាហកម្មកែច្នៃកសិផល និងសក្តានុពលសម្រាប់វិនិយោគទៅអនាគត* កំពុងលូតលាស់ទៅមុខៗ។

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១៣-២០

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 930.5 | 56.5 | 169.8 | 117.1 | 62.9 | 214.9 | 17.2 | 48.2 | 1.9 | 27.5 | 0.0 | 35.8 |
| ឧស្សាហកម្ម | 3257.0 | 1002.5 | 1014.7 | 1436.4 | 982.2 | 1186.2 | 292.9 | 113.7 | 302.0 | 919.9 | 234.0 | 737.0 |
| . សម្លៀកបំពាក់ | 324.1 | 393.5 | 225.2 | 380.7 | 211.1 | 187.3 | 73.9 | 34.4 | 47.3 | 74.1 | 106.0 | 55.5 |
| សេវាកម្ម | 140.7 | 622.6 | 2734.4 | 1664.3 | 3858.6 | 4351.8 | 1625.6 | 2518.2 | 849.7 | 1440.4 | 682.1 | 481.2 |
| . សណ្ឋាគារ និងទេសចរណ៍ | 106.0 | 446.9 | 98.6 | 1366.9 | 2759.6 | 1584.0 | 1618.8 | 2518.2 | 808.7 | 1703.8 | 133.0 | 202.4 |
| សរុប | 4328.0 | 1583.9 | 3918.9 | 3217.7 | 4903.7 | 5752.9 | 1935.6 | 2680.1 | 1153.5 | 2387.8 | 916.1 | 1254.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 4.9 | 38.5 | -57.0 | 107.0 | -61.6 | 36.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 63.4 | -63.4 | 147.4 | -17.9 | 52.4 | 17.3 | 312.5 | 12.6 | 8.9 | 29.4 | -52.7 | -53.2 |

Note: Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 227.3 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១៣-២០

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 463.1 | 560.3 | 694.7 | 830.0 | 1210.8 | 2024.4 | 683.4 | 609.1 | 572.5 | 496.9 | 259.7 | 15.9 |
| វៀតណាម | 854.1 | 905.8 | 987.8 | 959.7 | 835.4 | 800.1 | 186.9 | 214.8 | 235.7 | 271.5 | 179.5 | 0.2 |
| កូរ៉េខាងត្បូង | 435.0 | 424.4 | 395.3 | 357.2 | 345.0 | 301.8 | 95.7 | 43.6 | 47.4 | 68.1 | 41.7 | 1.0 |
| ថៃ | 221.3 | 279.5 | 349.9 | 398.1 | 394.9 | 382.3 | 97.9 | 76.3 | 113.9 | 178.4 | 152.7 | 8.4 |
| សហរដ្ឋអាមេរិក | 185.0 | 191.4 | 217.5 | 238.7 | 256.5 | 250.8 | 79.0 | 53.2 | 45.5 | 71.2 | 42.7 | 0.3 |
| ជប៉ុន | 206.9 | 215.8 | 193.3 | 191.6 | 203.4 | 210.5 | 60.2 | 40.4 | 48.9 | 58.2 | 39.8 | 0.2 |
| បារាំង | 131.5 | 141.1 | 145.7 | 150.3 | 166.4 | 170.8 | 59.4 | 27.3 | 32.9 | 44.5 | 41.8 | 0.1 |
| ចក្រភពអង់គ្លេស | 123.9 | 133.3 | 154.3 | 159.5 | 171.2 | 162.4 | 59.4 | 29.7 | 28.5 | 45.6 | 44.2 | 0.1 |
| ម៉ាឡេស៊ី | 130.7 | 144.4 | 149.4 | 152.8 | 179.3 | 201.1 | 48.7 | 43.2 | 46.5 | 64.6 | 24.9 | 0.1 |
| តាមផ្លូវអាកាស | 2017.7 | 2273.5 | 2476.0 | 2778.0 | 3312.7 | 6405.6 | 1299.1 | 1054.8 | 1039.9 | 1010.2 | 663.6 | 26.3 |
| តាមផ្លូវគោក និងទឹក | 2192.5 | 2229.3 | 2299.2 | 2331.4 | 2289.4 | 3242.2 | 578.7 | 405.8 | 436.0 | 786.1 | 491.6 | 8.4 |
| សរុប | 4210.2 | 4502.8 | 4775.2 | 4980.4 | 5602.2 | 9647.7 | 1877.9 | 1460.6 | 1475.8 | 1796.3 | 1155.2 | 34.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 2.9 | -22.2 | 1.0 | 21.7 | -35.7 | -93.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 17.5 | 7.0 | 6.1 | 4.3 | 12.5 | 72.2 | 9.7 | 13.2 | 7.4 | -1.6 | -38.5 | -97.4 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១៣-២០ *

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 6106.4 | 8106.0 | 9256.4 | 10043.3 | 10772.9 | 12783.8 | 3222.7 | 3379.0 | 4263.9 | 3524.9 | 3550.1 | 4251.5 |
| សម្លៀកបំពាក់ | 5015.4 | 5960.5 | 6827.0 | 7308.0 | 8020.3 | 9506.0 | 2463.4 | 2526.3 | 3143.8 | 2530.9 | 2647.2 | 1983.8 |
| - *សហរដ្ឋអាមេរិក* | 2143.3 | 1963.6 | 2009.4 | 1831.5 | 1923.8 | 2483.2 | 739.8 | 802.9 | 1006.5 | 848.0 | 945.9 | 694.3 |
| - *សហភាពអឺរ៉ុប* | 1716.9 | 2403.7 | 2903.9 | 2928.7 | 2782.2 | 3155.3 | 719.2 | 801.1 | 965.4 | 716.2 | 706.3 | 579.9 |
| - *អាស៊ាន* | 39.4 | 83.3 | 103.4 | 98.4 | 106.9 | 135.3 | 38.1 | 41.3 | 48.2 | 53.1 | 54.6 | 54.6 |
| - *ជប៉ុន* | 188.6 | 383.1 | 524.2 | 655.5 | 701.2 | 890.8 | 262.9 | 175.8 | 291.2 | 236.8 | 262.9 | 156.7 |
| - *ចក្រភពអង់គ្លេស* | | - | - | 439.8 | 904.0 | 1007.0 | 211.5 | 197.7 | 272.9 | 200.3 | 190.2 | 136.6 |
| - *ប្រទេសផ្សេងៗ* | 927.2 | 1126.8 | 1286.3 | 1354.2 | 1602.2 | 1834.3 | 491.7 | 507.5 | 559.7 | 476.4 | 487.3 | 361.7 |
| គ្រឿងអេឡិចត្រូនិក | - | - | - | - | 380.0 | 328.7 | 71.9 | 123.8 | 142.3 | 116.3 | 113.0 | 111.0 |
| គ្រឿងបង្គុំរថយន្ត | - | - | - | - | 11.6 | 94.4 | 20.4 | 18.2 | 22.7 | 24.1 | 26.0 | 43.0 |
| កសិកម្ម | 376.7 | 624.4 | 548.8 | 534.1 | 706.4 | 850.9 | 210.4 | 177.7 | 211.0 | 288.1 | 262.9 | 304.5 |
| - *កៅស៊ូ* | 176.6 | 153.9 | 165.4 | 165.3 | 273.5 | 217.6 | 43.8 | 42.2 | 60.0 | 73.3 | 30.8 | 40.0 |
| - *ឈើ* | 36.8 | 132.0 | 46.3 | 47.2 | 100.5 | 142.3 | 22.2 | 35.2 | 42.4 | 47.5 | 44.0 | 93.8 |
| - *ត្រី* | 2.0 | 0.8 | 0.5 | 0.6 | 0.6 | 1.3 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 |
| - *អង្ករ* | 146.4 | 248.5 | 315.3 | 300.8 | 255.1 | 413.6 | 122.4 | 72.2 | 84.5 | 140.2 | 145.9 | 105.5 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 14.9 | 89.1 | 21.3 | 20.2 | 76.7 | 76.2 | 21.9 | 28.1 | 24.1 | 26.9 | 42.2 | 65.1 |
| ផ្សេងៗ | 714.4 | 1520.1 | 1880.2 | 2201.2 | 1654.7 | 2003.8 | 456.6 | 532.9 | 744.0 | 565.6 | 501.0 | 1809.2 |
| ការនាំចូលសរុប | 8639.4 | 10295.4 | 11494.5 | 15013.4 | 16815.4 | 16904.7 | 4437.7 | 5328.6 | 5091.4 | 5324.3 | 5250.9 | 4361.5 |
| សាំង | 306.4 | 334.7 | 377.3 | 384.8 | 256.7 | 320.5 | 121.1 | 117.1 | 118.6 | 121.9 | 131.4 | 122.6 |
| ម៉ាស៊ូត | 569.1 | 602.3 | 607.8 | 709.1 | 472.9 | 594.1 | 228.2 | 250.2 | 166.4 | 248.9 | 248.1 | 265.1 |
| សម្ភារសំណង់ | 80.8 | 117.6 | 164.4 | 253.2 | 304.3 | 564.5 | 170.8 | 231.4 | 271.2 | 224.4 | 177.0 | 213.5 |
| ផ្សេងៗ | 7682.6 | 9240.7 | 10345.1 | 13666.3 | 15781.6 | 15425.7 | 3917.7 | 4729.9 | 4535.2 | 4729.1 | 4694.4 | 3760.4 |
| ជញ្ជីងពាណិជ្ជកម្ម | -1610.9 | -2184.3 | -2238.1 | -4970.0 | -5974.1 | -4120.9 | -1215.0 | -1990.6 | -827.5 | -1799.4 | -1700.9 | -110.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | 7.0 | 2.6 | 24.4 | -19.5 | 4.6 | -25.1 |
| ការនាំចេញសរុប | - | - | - | - | - | - | 2.8 | 7.8 | 26.2 | -17.3 | 0.7 | 19.8 |
| ការនាំចូលសរុប | - | - | - | - | - | - | 6.0 | 27.2 | -4.5 | 4.6 | -1.4 | -16.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 7.4 | 10.7 | 14.5 | 7.0 | 9.7 | 18.5 | 17.7 | 12.8 | 9.5 | 9.9 | 7.5 | -21.5 |
| ការនាំចេញសរុប | 14.3 | 16.1 | 14.2 | 8.5 | 7.9 | 17.9 | 13.7 | 12.6 | 11.8 | 12.4 | 10.2 | 25.8 |
| ការនាំចូលសរុប | 15.4 | 19.7 | 11.7 | 30.6 | 12.0 | 0.5 | 4.6 | 18.5 | 28.0 | 27.1 | 18.3 | -18.1 |

Note: Import data include tax-exempt imports.
Sources: Department of Trade Preference Systems, Ministry of Commerce; Customs and Excise Department, Ministry of Economy and Finance website

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១៣-២០ (ប៊ីលានរៀល)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 8255.2 | 10543.4 | 11879.9 | 14201.5 | 16582.0 | 19743.1 | 5097.5 | 6357.1 | 6364.5 | 6930.3 | 5544.2 | 5554.9 |
| ចំណូលចរន្ត | 8233.2 | 10359.4 | 11759.0 | 14088.7 | 16481.4 | 19549.0 | 5066.8 | 6322.2 | 6309.2 | 6869.7 | 5524.0 | 5504.1 |
| ចំណូលពន្ធ | 7198.1 | 8995.2 | 10502.4 | 12196.5 | 14314.3 | 17019.2 | 4524.3 | 5663.5 | 5415.1 | 6009.8 | 4697.1 | 5236.7 |
| ពន្ធក្នុងស្រុក | 5728.1 | 7226.5 | 8591.7 | 10185.8 | 12338.7 | 14648.3 | 3904.9 | 4944.9 | 4634.1 | 5215.9 | 4076.5 | 4787.8 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1470.0 | 1822.7 | 1910.7 | 2010.7 | 1875.6 | 2370.9 | 619.4 | 718.6 | 781.0 | 793.9 | 620.6 | 448.9 |
| ចំណូលមិនមែនពន្ធ | 1035.2 | 1310.3 | 1256.6 | 1892.2 | 2167.2 | 2520.9 | 542.5 | 658.7 | 894.1 | 859.9 | 826.9 | 267.4 |
| ចំណូលលើទ្រព្យសម្បត្តិ | 84.0 | 88.5 | 77.3 | 116.0 | 127.2 | 197.3 | 177.4 | 34.0 | 30.2 | 22.9 | 289.6 | 36.8 |
| លក់ទំនិញ និងសេវា | 750.3 | 871.2 | 1047.1 | 1248.3 | 1517.0 | 2075.6 | 330.7 | 531.2 | 798.5 | 750.0 | 500.9 | 211.6 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 200.8 | 350.5 | 132.2 | 528.0 | 523.1 | 253.9 | 34.5 | 93.5 | 65.5 | 87.1 | 36.4 | 47.5 |
| ចំណូលជាមូលធន | 73.4 | 184.0 | 121.0 | 113.4 | 100.5 | 194.1 | 30.7 | 35.0 | 55.4 | 60.7 | 20.2 | 50.8 |
| ចំណាយសរុប | 12535.7 | 13306.5 | 13849.5 | 13775.4 | 17251.0 | 19027.1 | 4150.4 | 4997.6 | 5386.5 | 7676.8 | 5301.7 | 6342.8 |
| ចំណាយជាមូលធន | 5567.5 | 5590.7 | 5290.3 | 3785.3 | 5207.2 | 5730.2 | 1025.0 | 1392.7 | 1358.6 | 3195.4 | 1259.3 | 2289.2 |
| ចំណាយចរន្ត | 6968.3 | 7715.8 | 8544.6 | 9990.1 | 12043.7 | 13297.0 | 3125.4 | 3604.9 | 4027.9 | 4481.3 | 4042.5 | 4053.5 |
| បៀវត្សរ៍ | 2997.3 | 3755.5 | 4271.9 | 5381.7 | 6647.4 | 7558.4 | 1820.2 | 1911.1 | 2102.0 | 1883.3 | 2058.0 | 1934.4 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1563.0 | 1627.0 | 1742.9 | 1774.9 | 2314.8 | 2505.4 | 729.2 | 1061.9 | 855.5 | 1620.3 | 1288.2 | 1435.6 |
| ចំណាយចរន្តផ្សេងទៀត | 2408.0 | 2333.4 | 2529.8 | 2833.5 | 5394.3 | 5738.6 | 1305.2 | 1693.8 | 1925.8 | 2598.1 | 1984.4 | 2119.2 |
| សមតុល្យជាទូទៅ | -160.8 | -2763.1 | -1969.6 | 426.1 | -669.1 | -205.4 | 947.1 | 1,359.6 | 978.0 | -746.4 | 242.4 | -787.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | -4280.6 | 3972.1 | 3729.4 | 1878.9 | 3358.1 | 716.1 | 652.8 | 895.5 | 608.8 | 1383.3 | 369.5 | 1180.5 |
| ហិរញ្ញប្បទានក្នុងស្រុក | 4326.2 | -1428.7 | -2034.9 | -1858.7 | -2454.1 | 2513.5 | -44.4 | -7.6 | 11.9 | -18.0 | 3.2 | 18.7 |

Source: Ministry of Economy and Finance website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១៣-២០

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.0 | 3.9 | 1.2 | 3.1 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.0 | 3.0 | 2.5 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 3.9 | 4.9 | 4.0 | 5.6 | 3.4 | 2.5 | 2.1 | 1.6 | 2.2 | 2.4 | 3.7 | 4.9 |
| - ដឹកជញ្ជូន | -0.6 | -1.0 | -9.2 | -6.9 | 4.1 | 2.9 | -3.8 | -1.5 | -2.5 | -1.4 | 2.6 | -10.8 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4037.3 | 4036.2 | 4060.4 | 4053.7 | 4047.5 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 | 4087.0 |
| រៀលក្នុង ១ បាតថៃ | 133.1 | 124.9 | 119.4 | 115.5 | 120.0 | 125.9 | 127.4 | 128.9 | 133.7 | 134.9 | 130.7 | 127.5 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.3 | 19.1 | 18.7 | 18.2 | 17.9 | 17.7 | 17.4 | 17.5 | 17.7 | 17.6 | 17.6 | 17.7 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 175.9 | 152.3 | 140.6 | 151.2 | 151.5 | 152.8 | 156.6 | 157.1 | 175.7 | 178.1 | 188.3 | 185.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 5019.0 | 4852.1 | 3771.3 | 3004.0 | 3385.8 | 3808.7 | 3413.9 | 3595.4 | 3499.7 | 3499.5 | 3343.5 | 2393.0 |
| ថ្លៃសាំង (រៀល/លីត្រ) | 5264.2 | 5083.3 | 3951.7 | 3336.8 | 3716.0 | 3982.5 | 3405.7 | 3770.2 | 3629.3 | 3685.9 | 3538.8 | 2483.8 |

Sources: National Institute of Statistics, National Bank of Cambodia, CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១៣-២០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 21260.1 | 26699.7 | 26665.5 | 31814.5 | 42575.3 | 55214.3 | 58148.8 | 55238.0 | 58667 | 60182.9 | 57001.8 | 63515.6 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 11508.3 | 15859.8 | 22157.6 | 25802.3 | 28743.5 | 33228.9 | 33997.2 | 55274.0 | 34814.3 | 34856.1 | 62221.0 | 60598.8 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2794.9 | -4359.1 | -6428.8 | -8148.5 | -11066.5 | -14803.7 | -17381.0 | -19828.0 | -21574.8 | -23884.4 | -24650.6 | -24152.1 |
| ឥណទានដល់វិស័យឯកជន | 27608.8 | 36244.6 | 46071 | 56458.8 | 66922.6 | 82419.3 | 86575.2 | 111686.0 | 119358.9 | 125629.4 | 131815.3 | 132849.9 |
| រូបិយវត្ថុទូទៅ | 32768.4 | 42559.5 | 48823.1 | 57616.6 | 71318.9 | 88443.2 | 92146.0 | 110512.0 | 116766.5 | 118436.4 | 119222.8 | 124114.4 |
| រូបិយវត្ថុ | 4878.2 | 6308.4 | 6741.4 | 7273.0 | 9428.4 | 10226.8 | 10782.0 | 9883.0 | 11933.4 | 11906.3 | 12880.5 | 12650.4 |
| រូបិយវត្ថុផ្សេងៗ | 21260.1 | 26699.7 | 42081.7 | 50343.8 | 61890.4 | 78216.4 | 81364.0 | 95196.0 | 98378.3 | 99650.6 | 99700.8 | 103956.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ | 14.6 | 29.9 | 14.7 | 18.0 | 23.8 | 24.0 | 24.0 | 22.6 | 21.3 | 20.4 | 29.4 | 12.3 |
| រូបិយវត្ថុ | 20.6 | 29.3 | 6.9 | 7.9 | 29.6 | 8.5 | 8.5 | 12.6 | 18.0 | 32.7 | 19.5 | 28.0 |
| រូបិយវត្ថុផ្សេងៗ | 13.6 | 30.0 | 16.1 | 19.6 | 22.9 | 26.4 | 26.4 | 24.1 | 21.7 | 18.8 | 22.5 | 9.2 |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2017 | 2018 | 2019 | | | | 2020 | | | 2020 | | |
| | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នករត់ស៊ីក្លូ | 10793 | 10793 | 11764 | 10567 | 11114 | 12046 | 10997 | 9081 | 10779 | -6.5 | -14.1 | -3.0 |
| អ្នកលីសែង | 14942 | 14942 | 15882 | 17323 | 16560 | 18802 | 18246 | 17856 | 15346 | 14.9 | 3.1 | -7.3 |
| អ្នកលក់បន្លែតូចតាច | 17015 | 17015 | 18912 | 21472 | 19197 | 18651 | 15207 | 20181 | 19479 | -19.6 | -6.0 | 1.5 |
| អ្នករើសអេតចាយ | 11591 | 11591 | 12941 | 12685 | 13123 | 13099 | 14759 | 8322 | 10742 | 14 | -34.4 | -18.1 |
| អ្នករត់តុភោជនីយដ្ឋាន* | 22901 | 22901 | 8299 | 8348 | 8564 | 8724 | 8706 | 8420 | 8997 | 4.9 | 0.9 | 5.1 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 17341 | 17341 | 8209 | 7909 | 9180 | 9376 | 9154 | 8812 | 8712 | 11.5 | 11.4 | -5.1 |
| កម្មកររោងចក្រកាត់ដេរ | 14231 | 14231 | 16073 | 15166 | 16076 | 16578 | 16483 | 13271 | 14211 | 2.6 | -12.5 | -11.6 |
| អ្នករត់ម៉ូតូឌុប | 8093 | 8093 | 14705 | 15104 | 14219 | 14904 | 17748 | 9081 | 15210 | 20.7 | -11.9 | 7.0 |
| កម្មករសំណង់គ្មានជំនាញ | 8055 | 8055 | 19820 | 17987 | 18322 | 18814 | 22916 | 19741 | 17870 | 15.6 | 9.7 | -2.5 |
| កម្មករសំណង់មានជំនាញ | 14093 | 14093 | 26265 | 24743 | 25235 | 27225 | 27164 | 26778 | 31298 | 3.4 | 8.2 | 24.0 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. **Not available. Source: CDRI

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ**...

គ្រប់គ្នា ជាពិសេស ដើម្បីសម្រេចគោលដៅទាំងឡាយនៃគោលដៅអភិវឌ្ឍន៍សង្គមរបស់កម្ពុជា និងចក្ខុវិស័យរបស់កម្ពុជាសម្រាប់ឆ្នាំ២០៣០ និង ២០៥០ និងក្នុងការកែសម្រួលតាមរបៀបរបបថ្មីក្រោយពេលមានជំងឺឆ្លងរាលដាលកូវីដ១៩។

ថ្ងៃទី១៣ កក្កដា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI និង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា បានពិភាក្សាពីកិច្ចសហការ។** នាយកប្រតិបត្តិ និង នាយកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI បានជួបជាមួយ បណ្ឌិត តិច វណ្ណារ៉ា នាយកប្រតិបត្តិនៃ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា ដើម្បីពិភាក្សាពីឱកាសសម្រាប់ការស្រាវជ្រាវដោយរួមសហការគ្នា សម្រាប់ផ្ដល់ព័ត៌មានដល់ការកសាងគោលនយោបាយ និងច្បាប់ផ្សេងៗរបស់ស្ថាប័នរដ្ឋាភិបាលកម្ពុជានានា។

ថ្ងៃទី២២ កក្កដា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI និង ក្រសួងអប់រំ យុវជន និងកីឡា បានពិភាក្សាពី ក្របខ័ណ្ឌនៃភាពជាដៃគូនិងសហប្រតិបត្តិការ ដើម្បីភ្ជិតគម្លាតរវាង អ្នកស្រាវជ្រាវផ្នែកគោលនយោបាយអប់រំនិងយុវជនជាមួយនឹង អ្នកកសាងគោលនយោបាយ។** បន្តពីទស្សនកិច្ចនៅថ្ងៃទី១១ ឧសភា របស់នាយកប្រតិបត្តិ CDRI ដើម្បីសំដែងការគួរសមជូនដល់ ឯ.ឧ បណ្ឌិត ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា គណៈប្រតិភូ CDRI រួមមាន នាយកស្រាវជ្រាវ នាយកមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍អប់រំ និង មន្ត្រីទំនាក់ទំនងខាងក្រៅ បានជួបជាមួយ បណ្ឌិត បូ ចាន់កូលិកា អនុប្រធានក្រុមប្រឹក្សាស្រាវជ្រាវផ្នែកអប់រំ និងនាយកផែនការគោលនយោបាយ នៃក្រសួងអប់រំ និងសហការីមួយចំនួន ដើម្បីពិភាក្សាពីក្របខ័ណ្ឌខាងលើដែលសំដៅជំរុញ គោលនយោបាយផ្អែកលើភស្ដុតាងសម្រាប់ការអប់រំនិងយុវជន និងការអភិវឌ្ឍ។

ថ្ងៃទី២៨ កក្កដា ក្រសួងអប់រំ ក្រុងភ្នំពេញ

**រដ្ឋមន្ត្រីក្រសួងអប់រំ បានផ្ដល់ព័ត៌មានពីអាទិភាពក្នុងការអប់រំដល់គណៈប្រតិភូ CDRI ។** ឯ.ឧ បណ្ឌិត ហង់ជួន ណារ៉ុន បានជួបជាមួយ នាយកប្រតិបត្តិ នាយកស្រាវជ្រាវ នាយកមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ និង មន្ត្រីទំនាក់ទំនងខាងក្រៅនៃ CDRI ដើម្បីពិភាក្សាពី ផែនការបង្កើតក្របខ័ណ្ឌនៃភាពជាដៃគូនិងសហប្រតិបត្តិការរវាងក្រសួងអប់រំ នឹង CDRI ។ ឯ.ឧ រដ្ឋមន្ត្រីបានប្រាប់គណៈប្រតិភូ CDRI ពីចក្ខុវិស័យ និងចំណុចផ្ដោតជាយុទ្ធសាស្ត្ររបស់ ឯកឧត្តម លើការអប់រំ និងកម្មវិធីសិក្សាប្រកបដោយនវានុវត្តន៍ ក្នុងនោះមានទាំងជំនាញទន់ផងដែរ។ ការអប់រំនិងបណ្ដុះបណ្ដាលមានគុណភាព កាន់តែសំខាន់ខ្លាំងឡើងយោងតាមការប្រែប្រួលយ៉ាងលឿន ក្នុងសេដ្ឋកិច្ចនិងសង្គមសព្វថ្ងៃនិងកាលៈទេសៈធ្ងន់ធ្ងរអស្ចារ្យដោយសារកូវីដ១៩។ ឯ.ឧ រដ្ឋមន្ត្រីបានបញ្ជាក់ជាពិសេសថា "មធ្យោបាយល្អបំផុត ដើម្បីបំពាក់សមត្ថភាពឲ្យកុមារ និងយុវជនសម្រាប់អនាគតកាលគឺ ត្រូវដាក់ការរៀនសូត្ររបស់អ្នកទាំងនេះ នៅចំណុចកណ្ដាលនៃការយកចិត្តទុកដាក់"។

ថ្ងៃទី៣០ កក្កដា ក្រុងភ្នំពេញ

**គណៈប្រតិភូ CDRI ដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល CDRI បានទៅជួបសំដែងការគួរសមជូន ឯ.ឧ ជា ចាន់តូ ។** ឯ.ឧ ជា ចាន់តូ ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា សហស្ថាបនិកនៃ CDRI និងជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាភិបាល CDRI បានទទួលស្វាគមន៍ គណៈប្រតិភូ CDRI រួមមាន ឯ.ឧ បណ្ឌិត ម៉ី កល្យាណ ប្រធានក្រុមប្រឹក្សាភិបាល, នាយកប្រតិបត្តិ, និង នាយកស្រាវជ្រាវ។ ឯ.ឧ ជា ចាន់តូ បានរំលឹកប្រកបដោយមោទនភាព និងសេចក្ដីរីករាយលើ ការបង្កើត CDRI ដោយសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកស្រី អេវ៉ា មីស្លីវិក និង ឯ.ឧ ផ្ទាល់ នៅឆ្នាំ១៩៩០។

ថ្ងៃទី១១ សីហា ក្រុងភ្នំពេញ

**ការចុះហត្ថលេខាលើ អនុស្សរណៈយោគយល់គ្នា ស្ដីពីសហប្រតិបត្តិការ និងភាពជាដៃគូ រវាង CDRI នឹង ក្រសួងអប់រំ។** អនុស្សរណៈនេះ សំដៅជួយគាំទ្រដល់កិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ ដើម្បីពង្រឹងពង្រីកការអប់រំប្រកបដោយគុណភាព សមធម៌ និងភាពសម្រាប់គ្រប់គ្នា តាមការសម្រេចឲ្យបាននូវគោលដៅនានាដូចមានកំណត់ក្នុង ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៩-២៣ ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ និង គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍយុវជន និងតាមការកែសម្រួលតាមរបៀបរបបថ្មី ក្រោយពេលមានជំងឺឆ្លងរាលដាលកូវីដ១៩។ វិស័យធ្វើសហប្រតិបត្តិការ មានជាអាទិ៍ ការស្រាវជ្រាវរួមគ្នាសម្រាប់ផ្ដល់ព័ត៌មានដល់ ការកសាងគោលនយោបាយដោយមានភស្ដុតាងបញ្ជាក់, ការកសាងសមត្ថភាពស្រាវជ្រាវនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ការប្រមូល គ្រប់គ្រង និងចែករំលែកទិន្នន័យ, ការវាយតម្លៃឥទ្ធិពលភ្លាមៗ និងក្នុងរយៈពេលវែងនៃកូវីដ១៩, ការរៀបចំកិច្ចសន្ទនា ផ្នែកគោលនយោបាយ សិក្ខាសាលាបណ្ដុះបណ្ដាល សន្និសីទផ្នែកសិក្សាស្រាវជ្រាវ និងព្រឹត្តិការណ៍សំខាន់ៗផ្សេងទៀត, ហើយនិងការពិគ្រោះយោបល់ជាទៀងទាត់ ការផ្លាស់ប្ដូរគ្នានូវបុគ្គលិកនិងទស្សនកិច្ច។ ភាគីទាំងពីរនឹងប្រើប្រាស់ ការស្រាវជ្រាវដោយរួមសហការគ្នា ការរៀនសូត្រទៅវិញទៅមក និងគំរូកសាងសមត្ថភាពបុគ្គលនិងស្ថាប័ន ដើម្បីទាញយក និងចែករំលែកបទពិសោធន៍ ចំណេះដឹង និងជំនាញ នៅក្នុងអង្គការរបស់ខ្លួន និងពង្រឹងសមត្ថភាពស្រាវជ្រាវដោយផ្អែកលើភស្ដុតាង។

ថ្ងៃទី១៣ សីហា សណ្ឋាគារកាំបូឌីយ៉ាណា ក្រុងភ្នំពេញ

**សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវស្ដីពី ការចូលរួមចំណែកនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់ កំណើននិងការប្រែក្លាយឧស្សាហកម្មសម្រាប់គ្រប់គ្នា៖ ការវិភាគពីកត្តាសំខាន់ៗនៅកម្ពុជា។** សិក្ខាសាលានេះរៀបចំឡើងដោយ CDRI និងដំណើរការក្រោមអធិបតីភាពរបស់នាយកប្រតិបត្តិ CDRI និង ឯ.ឧ ហ៊ីង ស៊ីដេត អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិង

វិជ្ជាជីវៈ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ បទបង្ហាញទាំងបីគ្របដណ្តប់លើ ១) ការណែនាំបង្ហាញពីគម្រោងស្រាវជ្រាវ ២) ការចូលរួមចំណែកនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់ កំណើន និងការប្រែក្លាយឧស្សាហកម្មសម្រាប់គ្រប់គ្នា៖ ការវិភាគពីកត្តាសំខាន់ៗនៅកម្ពុជា និង ៣) ការពិនិត្យស្រាវជ្រាវស៊ីជម្រៅពីឧស្សាហកម្មនៅកម្ពុជា៖ ជំនាញ និងការប្រែក្លាយ។ បទបង្ហាញទី១ និង ទី២ ធ្វើឡើងដោយអ្នកស្រាវជ្រាវនៃ CDRI, ហើយ បទបង្ហាញទី៣ ធ្វើឡើងដោយនិស្សិតថ្នាក់បណ្ឌិតនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រនៃកម្ពុជា។ នៅពេលរសៀល អ្នកចូលរួមបានធ្វើទស្សនកិច្ចនៅក្រុមហ៊ុន Confirel Co. Ltd ។

ថ្ងៃទី១៤ សីហា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI និង អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា។** ឯ.ឧ ប្រាក់ សាអឿន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និង នាយកប្រតិបត្តិ CDRI បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាមួយ ដើម្បីធ្វើសហប្រតិបត្តិការក្នុងការស្រាវជ្រាវ ការចែករំលែកបទពិសោធន៍និងព័ត៌មាន និងការកសាងសមត្ថភាព ដោយផ្តោតលើ អភិបាលកិច្ចនិងកំណែទម្រង់ការអភិវឌ្ឍសេដ្ឋកិច្ច សុខុមាលភាពនិងការអប់រំ និង បរិស្ថាន។ សកម្មភាពសហប្រតិបត្តិការ រួមមាន ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយរួមគ្នា, សិក្ខាសាលា សន្និសីទ និងការបណ្តុះបណ្តាល, ការចែករំលែកធនធានស្រាវជ្រាវ ស្ថិតិនិងព័ត៌មាន ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ, និងការអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ថ្ងៃទី២៤ សីហា សន្និសីទតាមអ៊ិនធើណិត

**វិទ្យាស្ថាន CDRI បានរៀបចំសន្និសីទផ្សព្វផ្សាយតាមអ៊ិនធើណិតថ្នាក់តំបន់មួយ។** CDRI ដោយរួមសហការជាមួយដៃគូស្រាវជ្រាវនៅប្រទេស ចិន ថៃ និង វៀតណាម បានរួមគ្នារៀបចំសន្និសីទតាមអ៊ិនធើណិតមួយ សម្រាប់កម្មវិធីស្រាវជ្រាវ ស្តីពីការលើកកម្ពស់ការស្រាវជ្រាវ និង កិច្ចសន្ទនាស្តីពីការធ្វើកសិកម្មតាមកិច្ចសន្យា នៅតំបន់មេគង្គ-ឡានឆាង។ គម្រោងនេះទទួលថវិកាពី មូលនិធិពិសេសនៃ សហប្រតិបត្តិការមេគង្គ-ឡានឆាង ហើយបានជួយឲ្យមានការ យល់ដឹងស៊ីជម្រៅពីស្ថានភាព និង ឧបសគ្គនៃការធ្វើកសិកម្មតាមកិច្ចសន្យា នៅតាមប្រទេសក្នុងតំបន់មេគង្គ, កំណត់កត្តានាំឲ្យមានជោគជ័យ ឬបរាជ័យ, វាយតម្លៃពីហានិភ័យនិងអត្ថប្រយោជន៍ និងចងក្រងឯកសារពីរបៀបរបបល្អនៃការធ្វើកសិកម្មតាមកិច្ចសន្យានូវ ផលិតផលកសិកម្មផ្សេងៗ (ស្រូវ ស្វាយ ម្រេច ស្វាយចន្ទី កាហ្វេ ចេកអំបូងលឿង ទុរេន)។ ផ្អែកលើលទ្ធផលស្រាវជ្រាវឃើញ CDRI មានផែនការធ្វើការសិក្សាកាន់តែលំអិតមួយទៀតជាមួយ នាយកដ្ឋានកសិ-ឧស្សាហកម្ម (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ), វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, និង អង្គការសង្គមស៊ីវិលផ្សេងៗ ដើម្បីផ្តល់ព័ត៌មានដល់ការកសាងគោលនយោបាយ និងច្បាប់។

ថ្ងៃទី២ កញ្ញា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI បានទទួលស្វាគមន៍ លោក យ៉ន សុវណ្ណ អគ្គនាយកនៃក្រុមហ៊ុន បាយ៉ន និងសមាជិកក្រុមប្រឹក្សាភិបាលនៃសហព័ន្ធស្រូវអង្ករកម្ពុជា។** លោក យ៉ន សុវណ្ណ បានអញ្ជើញមក CDRI ដើម្បីផ្តល់ព័ត៌មានដល់អ្នកស្រាវជ្រាវ និងអ្នកគ្រប់គ្រងនានានៃ CDRI អំពីសន្ទស្សន៍ជាតិស្ករទាប ទៅមធ្យម (low to mid glycaemic index) នៃផលិតផលអង្ករ ដែលបង្កើតឡើង និងផ្សព្វផ្សាយដោយក្រុមហ៊ុន បាយ៉ន ដោយរួមសហការជាមួយមូលនិធិ Glycaemic Index Foundation នៅអូស្ត្រាលី និងអង្គភាពស្រាវជ្រាវសន្ទស្សន៍ Glycaemic នៅសិង្ហបុរី។

ថ្ងៃទី៣ កញ្ញា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI បានទទួលស្វាគមន៍ លោក Zhang Bao ជាសមាជិកថ្មីនៃក្រុមប្រឹក្សាភិបាល CDRI ។** នាយកប្រតិបត្តិ, តំណាងបុគ្គលិក, ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្មនិងអភិវឌ្ឍន៍ជនបទ, និងលេខាធិការនៃក្រុមប្រឹក្សាភិបាលនៃ CDRI បានទទួលស្វាគមន៍ លោក Zhang Bao ដែលបានទទួលការតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាភិបាល CDRI នៅខែសីហា។ លោក Zhang Bao ជាប្រធានអ្នកយកព័ត៌មានប្រចាំនៅកម្ពុជា សម្រាប់ព្រឹត្តិប័ត្រ *China Economic Daily* និងមានបទពិសោធន៍ផ្នែកស្រាវជ្រាវពីការអភិវឌ្ឍនៅចិន និងអន្តរជាតិ។

ថ្ងៃទី៣ កញ្ញា ក្រុងភ្នំពេញ

**សិក្ខាសាលាពិគ្រោះយោបល់លើឯកសារព្រាងនៃ ផែនការមេកសិកម្មជាតិឆ្នាំ២០៣០។** នាយកប្រតិបត្តិ និង អ្នកស្រាវជ្រាវជាន់ខ្ពស់ម្នាក់ នៃមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្មនិងអភិវឌ្ឍន៍ជនបទ នៃ CDRI បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់លើឯកសារព្រាងនៃ ផែនការមេកសិកម្មជាតិឆ្នាំ២០៣០ ដែលរៀបចំឡើងដោយ វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងគាំទ្រដោយ អង្គការអុកស្វាមកម្ពុជា។ សិក្ខាសាលានេះមានការចូលរួមពី អ្នកតំណាងនៃ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ធនាគារអភិវឌ្ឍន៍ ក្រុមផ្តល់គំនិត និងស្ថាប័នសិក្សាអប់រំ ជាច្រើន។ CDRI បានធ្វើសុន្ទរកថាគន្លឹះ ស្តីពីផលប៉ះពាល់នៃកូវីដ១៩ និងការប្រែប្រួលផ្សេងៗបង្កឡើងដោយធម្មជាតិ និងដោយសកម្មភាពមនុស្ស។

ថ្ងៃទី៩ កញ្ញា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI បានជួបជាមួយ តំណាងប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ។** ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និង ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវនានា នៃ CDRI បានជួបជាមួយ លោកស្រី Pauline Tamesis តំណាងថ្មីប្រចាំប្រទេសកម្ពុជានៃអង្គការសហប្រជាជាតិ និង Kongchheng Poch សេដ្ឋវិទូជាន់ខ្ពស់នៅការិយាល័យប្រចាំប្រទេសកម្ពុជា នៃអង្គការសហប្រជាជាតិ។ ភាគីទាំងពីរបានចែករំលែកទស្សនៈរបស់ខ្លួន ក្របខ័ណ្ឌ និងផែនការការងារផ្សេងៗ ដើម្បីចូលរួមចំណែកដល់ដំណើរការស្តារឡើងវិញបន្ទាប់ពីមានកូវីដ១៩ នៅកម្ពុជា និងពិនិត្យពីបែបបទដែល CDRI

អាចធ្វើការជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ ដើម្បីជួយគាំទ្រដល់រដ្ឋាភិបាលកម្ពុជា "ក្នុងការកសាងឡើងវិញឲ្យបានកាន់តែល្អ" ចេញពីជំងឺឆ្លងរាលដាលកូវីដ១៩។ ការជួបប្រជុំធ្វើបច្ចុប្បន្នភាពជាទៀងទាត់ នឹងជួយឲ្យមានថាមពលគុណឡើងរវាងការស្រាវជ្រាវរបស់ CDRI នឹង កម្មវិធីផ្សេងៗរបស់អង្គការសហប្រជាជាតិ ហើយកិច្ចសន្ទនាផ្នែកគោលនយោបាយមួយខ្សែ ជាមួយដៃគូនិងអ្នកកសាងគោលនយោបាយសំខាន់ៗ នឹងជួយផ្ដល់ព័ត៌មានដល់ការកសាងគោលនយោបាយ។

ថ្ងៃទី១០ កញ្ញា CDRI ក្រុងភ្នំពេញ

**អង្គការមូលនិធិអាស៊ី (TAF) បានធ្វើទស្សនកិច្ចសំដែងការគួរសមនៅ CDRI ។** លោក Meloney Lindberg តំណាងប្រចាំប្រទេស និង លោកស្រី ហៀង សោភា អ្នកគ្រប់គ្រងកម្មវិធីនៃកម្មវិធីពន្លកចំណេះនៃអង្គការមូលនិធិអាស៊ី (TAF) បានធ្វើទស្សនកិច្ចសំដែងការគួរសមនៅ CDRI ។ ដោយបានជំនួយគាំទ្រពី ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី (DFAT) កិច្ចសហការជាដៃគូរវាង TAF នឹង CDRI ផ្ដោតលើ ការស្រាវជ្រាវ កិច្ចសន្ទនាផ្នែកគោលនយោបាយ និងការកសាងសមត្ថភាពនៅឧត្តមសិក្សា។ គម្រោងស្រាវជ្រាវកំពុងដំណើរការក្នុងភាពជាដៃគូនេះ រួមមានការចាប់អនុវត្តបច្ចេកវិទ្យាអប់រំ ក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩, ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងជម្រើសជំនាញឯកទេសចម្បងៗ, អន្តរជាតូបនីយកម្មនៃឧត្តមសិក្សានៅកម្ពុជា, និង វិធីបែងចែកប្រភេទគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា។

ថ្ងៃទី១១ កញ្ញា CDRI ក្រុងភ្នំពេញ

**ព្រឹត្តិការណ៍ជួបជុំបុគ្គលិក CDRI សម្រាប់ការកំសាន្ត ការកសាងសាមគ្គីក្នុងក្រុម និងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។** ព្រឹត្តិការណ៍បានចាប់ផ្ដើមដោយ បណ្ណារក្សថ្មីឡើងអធិប្បាយពីបទពិសោធន៍គាត់នាំមកជូន CDRI ក្នុងការគ្រប់គ្រងចំណេះដឹង និងបង្រៀនភាសា។ បន្ទាប់មកមានបទបង្ហាញដោយ អ្នកស្រាវជ្រាវមិនទាន់មានបទពិសោធន៍ច្រើនស្ដីពី ឧបករណ៍គ្រប់គ្រងទិន្នន័យ និង បទពិសោធន៍ផ្ទាល់ខ្លួននិងក្នុងវិជ្ជាជីវៈ ជាអ្នកស្រាវជ្រាវនៅ CDRI ។ បុគ្គលិក និងថ្នាក់គ្រប់គ្រង CDR បានសំណេះសំណាលលាគ្នាជាមួយ លោក ឈឹម ឈុន ជាអ្នកស្រាវជ្រាវបម្រើការយូរឆ្នាំនៅ CDRI និងបានថ្លែងអំណរគុណ ដល់ការចូលរួមចំណែកដ៏មានតម្លៃរបស់គាត់ដល់ការស្រាវជ្រាវនៅ CDRI ។

ថ្ងៃទី១១ កញ្ញា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI បានជួបជាមួយ បណ្ឌិត Gong Sen អនុប្រធានប្រតិបត្តិនៃ មជ្ឈមណ្ឌលសម្រាប់ចំណេះដឹងអន្តរជាតិពីការអភិវឌ្ឍ (CIKD) នៅប្រទេសចិន។** ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និង អ្នកស្រាវជ្រាវ នៃ CDRI បានជួបជាមួយ បណ្ឌិត Gong Sen តាមកម្មវិធីអ៊ិនធើណិត Zoom ។ ភាគីទាំងពីរបានប្រាប់គ្នាទៅវិញទៅមកពី ទិសដៅនិងបេសកកម្មជាយុទ្ធសាស្ត្ររបស់ខ្លួន និងពិនិត្យពិភាក្សាពីផ្នែកសម្រាប់ធ្វើសហប្រតិបត្តិការ និងកិច្ចសហការជាដៃគូ មានជាអាទិ៍ ការផ្លាស់ប្ដូរគ្នានូវលទ្ធផលស្រាវជ្រាវក្នុងបញ្ហាអភិវឌ្ឍន៍អន្តរជាតិ ការកសាងនិងគ្រប់គ្រងចំណេះដឹង និងការប្រើប្រាស់ចំណេះដឹង។ ផ្នែកដែលមានផលប្រយោជន៍ទៅវិញទៅមក រួមមាន ឧទ្យានឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស, នគរូបនីយកម្ម (បទពិសោធន៍ចិន), ការកាត់បន្ថយភាពក្រីក្រ, ភាពធន់នឹងកត្តាបង្កការតឹងតែងក្នុងសង្គមនិងសេដ្ឋកិច្ច ផុសចេញពីកូវីដ១៩ និងការប៉ះទង្គិច និង ការតឹងតែងផ្សេងៗទៀតដល់សុខុមាលភាព ការអភិវឌ្ឍកម្លាំងពលកម្ម ហើយនិង បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធ។

ថ្ងៃទី១១ កញ្ញា ក្រុងភ្នំពេញ

**គណៈប្រតិភូ CDRI បានទៅជួបសំដែងការគួរសមដល់ លោក Wang Dexin ជានាយកនៅការិយាល័យនយោបាយនៃស្ថានទូតចិននៅកម្ពុជា។** គណៈប្រតិភូ CDRI រួមមាន នាយកប្រតិបត្តិ នាយកស្រាវជ្រាវ និង នាយកមជ្ឈមណ្ឌលស្រាវជ្រាវពីរនាក់ បានទៅជួបសំដែងការគួរសមនៅឯស្ថានទូតចិន។ ក្នុងប្រាំឆ្នាំកន្លងមកនេះ CDRI បានកសាងចំណងទាក់ទងរឹងមាំជាមួយស្ថានទូតចិន តាមរយៈការផ្លាស់ប្ដូរគ្នានូវអ្នកស្រាវជ្រាវ និងការស្រាវជ្រាវដោយរួមសហការគ្នាក្នុងសហប្រតិបត្តិការមេគង្គ-ឡានឆាង។

ថ្ងៃទី២៩ ការសន្ទនាតាមកម្មវិធីអ៊ិនធើណិត Zoom ឬតាមវត្តមានផ្ទាល់នៅ មជ្ឈមណ្ឌលចំណេះដឹង នៃ CDRI

**ការសន្ទនាផ្នែកគោលនយោបាយ ស្ដីពី ការបង្រៀន និងការរៀនសូត្រ ក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩៖ ចម្លើយតបរបស់សាលា និងបទពិសោធន៍របស់និស្សិត។** CDRI បានរួមគ្នាជាមួយ អង្គការមូលនិធិអាស៊ី (TAF) រៀបចំកិច្ចសន្ទនាផ្នែកគោលនយោបាយមួយ ស្ដីពី ការបង្រៀន និងការរៀនសូត្រ ក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩៖ ចម្លើយតបរបស់សាលា និងបទពិសោធន៍របស់និស្សិត។ ការពិភាក្សាផ្ដោតលើ ចម្លើយតបរបស់ក្រសួងអប់រំ និងគ្រឹះស្ថានសិក្សាអប់រំ ទៅនឹងជំងឺឆ្លងរាលដាល និងបទពិសោធន៍របស់និស្សិតជាមួយនឹងការរៀនសូត្រអនឡាញ។ សំណួរសំខាន់ៗ រួមមាន តើសាលារៀន សាកលវិទ្យាល័យ និងនិស្សិត បានត្រៀមរៀបចំល្អប៉ុណ្ណា ដើម្បីងាកទៅប្រើវិធីថ្មីក្នុងការបង្រៀន និងរៀនសូត្រ? តើសាលារៀន និងសាកលវិទ្យាល័យបានឆ្លើយតបយ៉ាងណា ទៅនឹងកំហិតផ្សេងៗដែលបង្កឡើងដោយជំងឺឆ្លងរាលដាល? តើគេរៀនសូត្របានអ្វីខ្លះពី កិច្ចប្រឹងប្រែងឆ្លើយតប និងបទពិសោធន៍របស់និស្សិត ជាមួយនឹងបរិស្ថានរៀនសូត្រថ្មីនេះ?

ថ្ងៃទី៣០ កញ្ញា ក្រសួងហិរញ្ញវត្ថុ ក្រុងភ្នំពេញ

**ជំហាននានា សម្រាប់អនុវត្តអនុស្សរណៈយោគយល់គ្នារវាង CDRI នឹង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។** នាយកប្រតិបត្តិ និងមន្ត្រីទំនាក់ទំនងខាងក្រៅ នៃ CDRI បានជួបជាមួយ ឯ.ឧ វង្សី វិស្សុត រដ្ឋលេខាធិការនៃក្រសួងហិរញ្ញវត្ថុ ដើម្បីពិភាក្សាពីជំហាននានាសម្រាប់អនុវត្តការស្រាវជ្រាវ និងការវិភាគគោលនយោបាយដោយ

រួមសហការគ្នា ស្របតាមអនុស្សរណៈយោគយល់គ្នា។ ឯកឧត្តម បានលើកទឹកចិត្ត CDRI ឲ្យប្រឹងឆ្លើយតបទៅនឹងតម្រូវការ ព័ត៌មាន/ចំណេះដឹង និងដាក់អនុវត្តបានទាន់ពេលនូវចក្ខុវិស័យ ជាយុទ្ធសាស្ត្រ និងផែនការរយៈពេលវែង។

## ការស្រាវជ្រាវ

### មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ (CDET)

ដោយរួមសហការជាមួយ វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT) មជ្ឈមណ្ឌល CDET កំពុងអនុវត្ត *អង្កេតវាយតម្លៃជំនាញផ្នែកឌីជីថល* ក្នុងគម្រោងស្រាវជ្រាវដែលទទួលថវិកាពី មូលនិធិអភិវឌ្ឍន៍ និងស្រាវជ្រាវកសាងសមត្ថភាព របស់ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។ ក្នុងនេះមាន សិក្ខាសាលាពិគ្រោះយោបល់អនឡាញមួយបានធ្វើឡើងនៅថ្ងៃទី១ កក្កដា ដើម្បីប្រមូលធាតុចូលបន្ថែម សម្រាប់ពង្រឹងការរចនារៀបចំការស្រាវជ្រាវ បញ្ជីសំណួរ និងឧបករណ៍អង្កេតផ្សេងៗ ហើយការបណ្ដុះបណ្ដាលអ្នកធ្វើអង្កេត បានចាប់ផ្ដើមបន្ទាប់ពីសិក្ខាសាលានេះ។ ការប្រមូលទិន្នន័យសម្រាប់អង្កេតលើនិស្សិត បានចប់រួចរាល់នៅខែសីហា រីឯអង្កេតលើសហគ្រាស កំពុងដំណើរការទៅមុខ។

ក្រុមស្រាវជ្រាវបានបង្ហើយរបាយការណ៍ស្ដីពី *អ្នកលក់ដូរតាមចិញ្ចើមថ្នល់ ការងាររបស់យុវជន និងការកាត់បន្ថយភាពក្រីក្រ* ដែលត្រូវបានកែសម្រួល ដោយផ្អែកលើព័ត៌មានត្រឡប់បានពីការពិនិត្យផ្ទៃក្នុង ហើយនឹងត្រូវបោះពុម្ពផ្សាយជា ឯកសារពិភាក្សារបស់ វិទ្យាស្ថាន CDRI ។ ដំណាក់កាលទី១ នៃគម្រោង *ការចូលរួមចំណែកនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់ កំណើននិងការប្រែក្លាយឧស្សាហកម្មសម្រាប់គ្រប់គ្នា៖ ការវិភាគពីកត្តាសំខាន់ៗក្នុង ៦ប្រទេស* ដែលទទួលអំណោយមូលនិធិពីសាកលវិទ្យាល័យហ្ស៊ូរិកនៃការអប់រំគ្រូ (PH Zurich, Switzerland) បានចប់សព្វគ្រប់ ដោយមានធ្វើសិក្ខាសាលាផ្សព្វផ្សាយ នៅថ្ងៃទី១៣ សីហា នៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រុងភ្នំពេញ និងការចេញផ្សាយឯកសារពិភាក្សាមួយរបស់ CDRI ។ គម្រោង *ពាណិជ្ជកម្មផ្នែកកសិកម្មរវាងប្រទេសចិន នឹងបណ្ដាប្រទេសនៅតំបន់មេគង្គ-ឡានឆាង៖ ការវិភាគខ្សែសង្វាក់តម្លៃ* ដែលទទួលបានថវិកាពី មូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង ក៏បានចប់សព្វគ្រប់ ដោយមានធ្វើសិក្ខាសាលាផ្សព្វផ្សាយអនឡាញមួយ មានការចូលរួមពីដៃគូស្រាវជ្រាវ ក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងមហាអនុតំបន់មេគង្គ។ សំណើបោះពុម្ពសៀវភៅមួយបានដាក់ជូនទៅ វិទ្យាស្ថាន ISEAS-Yusof Ishak Institute នៅសិង្ហបុរី ដែលបានយល់ព្រមជាគោលការណ៍ ដើម្បីបោះពុម្ពផ្សាយកម្រងឯកសារស្រាវជ្រាវតាមប្រទេសនេះ។ ក្រុមស្រាវជ្រាវបានធ្វើការជាច្រើន ដើម្បីដាក់ស្នើឡើងវិញនូវឯកសារព្រាង ហើយសៀវភៅនេះគ្រោងបោះពុម្ពផ្សាយនៅឆ្នាំ២០២១។

មជ្ឈមណ្ឌល CDET ក៏ទទួលបានអំណោយមូលនិធិពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា ដើម្បីរួមសហការជាដៃគូជាមួយ មហាវិទ្យាល័យសេដ្ឋកិច្ច និងការគ្រប់គ្រងអាជីវកម្ម នៃសាកលវិទ្យាល័យជាតិនៃប្រទេសឡាវ (NUOL), មជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម (CESD) នៅមីយ៉ាន់ម៉ា, និង មជ្ឈមណ្ឌលសម្រាប់ការវិភាគ និងព្យាករណ៍ (CAF) នៅវៀតណាម, ក្នុងគម្រោងស្រាវជ្រាវរយៈពេលបីឆ្នាំមួយស្ដីពី *ផលប៉ះពាល់នៃ កូវីដ១៩ លើការអភិវឌ្ឍសម្រាប់គ្រប់គ្នា និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ៖ ការវាយតម្លៃរហ័ស និងក្រោយពេលមានជំងឺឆ្លងរាលដាលនៅមហាអនុតំបន់មេគង្គ* ដោយក្នុងនេះ CDRI ដើរតួនាទីជាអ្នកសម្របសម្រួលសម្ព័ន្ធស្រាវជ្រាវនេះ។

### មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ (CERI)

មជ្ឈមណ្ឌលនេះបានចេញផ្សាយ ឯកសារពិភាក្សាពីរ ស្ដីពី ១) *លក្ខណៈសំគាល់ និងបញ្ហាផ្សេងៗ នៃការហាត់ការនៅតាមសហគ្រាសឯកជននៅកម្ពុជា* និង ២) *ការស្វែងយល់ពីទស្សនៈ និងវិធីសាស្ត្ររបស់ព្រឹទ្ធបុរសកម្ពុជា លើគណនេយ្យភាពនៃសាកលវិទ្យាល័យ* និងបានចេញផ្សាយអត្ថបទពីរក្នុង ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ក្រោមចំណងជើងថា "ការពិនិត្យឡើងវិញពីការអភិវឌ្ឍ និង អនុវត្តការអប់រំនិងបណ្ដុះបណ្ដាល ផ្អែកលើសមត្ថភាព" និង "ទៅមុខមិនទាល់៖ ច្រកឆ្លងចូលគ្នារវាងប្រព័ន្ធអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងប្រព័ន្ធអប់រំសិក្សាធិការ នៅកម្រិតឧត្ដមសិក្សា"។ ឯកសារទាំងនេះទទួលបានមូលនិធិពី ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ (SDC), ទីភ្នាក់ងារសម្រាប់ សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida), និង ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី (DFAT) តាមរយៈមូលនិធិអាស៊ី (TAF)។

ក្នុងពេលធ្ងន់ធ្ងរមិនធ្លាប់ជួប ដោយសារមានជំងឺឆ្លងរាលដាលកូវីដ១៩ មជ្ឈមណ្ឌល CERI បានធ្វើការសិក្សាមួយស្ដីពី *ការចាប់អនុវត្តដោយបង្ខំនូវបច្ចេកវិទ្យាអប់រំ ក្នុងអំឡុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩៖ ករណីស្ថាប័នឧត្ដមសិក្សានៅតាមបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍*។ ការសិក្សានេះ សំដៅវាស់វែង ភាពត្រៀមស្រេចបាច់ផ្នែកបច្ចេកវិទ្យា និងការចាប់អនុវត្តបច្ចេកវិទ្យារៀនសូត្រតាមអនឡាញ ក្នុងឧត្ដមសិក្សានៅកម្ពុជា។ ទិន្នន័យបានប្រមូលចប់ ហើយបច្ចុប្បន្នកំពុងយកមកវិភាគ ដើម្បីចាប់ផ្ដើមសរសេររបាយការណ៍នៅត្រីមាសទី៤។ ការសិក្សាតំណាងឲ្យទូទាំងប្រទេសនេះ ត្រូវបានផ្ដល់មូលនិធិរួមគ្នា ដោយ DFAT (តាមរយៈ TAF) ហើយនិង មូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង។ លទ្ធផលរកឃើញនឹងជួយរួមចំណែកដល់ការកសាងគោលនយោបាយ និងការពិភាក្សា លើការកែសម្រួលក្រោយពេលមានជំងឺឆ្លងរាលដាលកូវីដ១៩ នៅឯ ក្រសួងអប់រំ យុវជន និងកីឡា ហើយនិង ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

មជ្ឈមណ្ឌលនេះ បានរៀបចំវគ្គបណ្ដុះបណ្ដាលកសាងសមត្ថភាពក្នុងអង្គភាពមួយខ្សែ ដែលគ្របដណ្ដប់លើប្រធានបទ

ជាច្រើន មានតាំងពី ការរៀបចំការចុះសិក្សាដល់កន្លែង ការប្រមូល និងវិភាគទិន្នន័យ រហូតដល់ ការសរសេររបាយការណ៍ និងការផ្សព្វផ្សាយលទ្ធផលរកឃើញ។ ការបណ្ដុះបណ្ដាលនេះផ្ដោតលើអ្នកហាត់ការ និងអ្នកស្រាវជ្រាវនៅមានបទពិសោធន៍តិច។

នៅថ្ងៃទី២៩ កញ្ញា នៅមជ្ឈមណ្ឌលចំណេះដឹងរបស់ CDRI មជ្ឈមណ្ឌល CERI បានរួមគ្នាជាមួយ TAF រៀបចំការពិភាក្សាផ្នែកគោលនយោបាយមួយស្ដីពី ការបង្រៀននិងការរៀនសូត្រក្នុងរយៈពេលមានជំងឺឆ្លងរាលដាលកូវីដ១៩៖ ចម្លើយតបរបស់សាលា និងបទពិសោធន៍របស់និស្សិត។ ការពិភាក្សាផ្ដោតលើ ចម្លើយតបរបស់ក្រសួងអប់រំ និងគ្រឹះស្ថានសិក្សាអប់រំនានា ទៅនឹងជំងឺឆ្លងរាលដាល ហើយនិងបទពិសោធន៍របស់និស្សិតក្នុងការរៀនសូត្រតាមអនឡាញ។ ដោយមានវាគ្មិនមកពី វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT), នាយកដ្ឋានគោលនយោបាយនៃក្រសួងអប់រំ, និង CDRI, ការពិភាក្សាបានផ្ដោតលើសំណួរសំខាន់ៗ មានជាអាទិ៍ តើសាលា សាកលវិទ្យាល័យ និងនិស្សិត បានត្រៀមល្អប៉ុណ្ណា ដើម្បីងាកទៅប្រើវិធីបង្រៀននិងរៀនសូត្រថ្មីនេះ? តើសាលា និងសាកលវិទ្យាល័យនានា បានឆ្លើយតបយ៉ាងណាទៅនឹងជំងឺឆ្លងរាលដាល និងការដាក់កំហិតតាមក្រោយនោះ? តើយើងរៀនសូត្របានអ្វីខ្លះពីការប្រឹងប្រែងឆ្លើយតបផ្សេងៗ និងបទពិសោធន៍របស់និស្សិតជាមួយនឹងបរិស្ថានរៀនសូត្រថ្មីនេះ?

## មជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នា (CGIS)

ក្រុមស្រាវជ្រាវ បានចូលរួមក្នុងគម្រោងស្រាវជ្រាវជាច្រើន ដែលពាក់ព័ន្ធនឹងមជ្ឈមណ្ឌលច្រើនផ្នែក។ អ្នកស្រាវជ្រាវស្ត្រីបីនាក់ បានធ្វើការប្រមូលទិន្នន័យសម្រាប់ការសិក្សាស្ដីពី *ការវិភាគយេនឌ័រ និងការអភិវឌ្ឍសម្រាប់គ្រប់គ្នា (GIDA)* ដែលដឹកនាំដោយមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ។ មជ្ឈមណ្ឌល CGIS ក៏បានធ្វើការជាមួយអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន សម្រាប់ការសិក្សាស្ដីពី *ស្ថានភាពសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។* គម្រោងស្រាវជ្រាវមានច្រើនមជ្ឈមណ្ឌលចូលរួមចុងក្រោយដឹកនាំដោយ CGIS និងមានអ្នកស្រាវជ្រាវនៅផ្នែកអប់រំ និងផ្នែកសេដ្ឋកិច្ចរួមចំណែកផង គឺការសិក្សាស្ដីពី *សហប្រតិបត្តិការអភិវឌ្ឍន៍នៃដៃគូចម្បងៗរបស់កម្ពុជា* ដែលផ្ដោតលើ ឱកាសរួមសហការដើម្បីសម្រេចបាននូវ សុខដុមនីយកម្មជំនួយ និងការដឹកនាំក្នុងស្រុក។

ដើម្បីឆ្លើយតបនឹងការអំពាវនាវ ឲ្យធ្វើការស្រាវជ្រាវពីកូវីដ១៩ មជ្ឈមណ្ឌល CGIS បានដាក់សំណើស្រាវជ្រាវពីរ គឺ សំណើទី១ ដាក់ជូនទៅ IDRC ស្ដីពី *ការប្រាស្រ័យទាក់ទងខ្វាតធំរវាងរដ្ឋាភិបាលនឹងសហគមន៍នានា ដើម្បីទប់ទល់ការផ្ដល់ព័ត៌មានខុស និងព័ត៌មានភូតភរ នៅកម្ពុជា* និង ទី២ ដាក់ជូនទៅសម្ព័ន្ធ ការស្រាវជ្រាវនិងនវានុវត្តន៍អង់គ្លេស/មូលនិធិញូតុន (UK Research and Innovation/Newton Fund) ស្ដីពី *ការគាំពារសង្គម និងផលប៉ះពាល់ផ្នែកយេនឌ័រនៃកូវីដ១៩ នៅកម្ពុជា។* សំណើទី១ បានទទួលការយល់ព្រម ហើយ CGIS បានជឿនលឿនច្រើនហើយក្នុងការរចនារៀបចំ អង្កេតពលករមួយដែលគ្រោងចាប់អនុវត្តក្នុងត្រីមាសខាងមុខ។ ការស្រាវជ្រាវនេះជាការរួមសហការមួយជាមួយ Royal Holloway នៃសាកលវិទ្យាល័យ London និងសាកលវិទ្យាល័យ Nottingham។

មជ្ឈមណ្ឌល CGIS ក៏បានទទួលស្វាគមន៍ អ្នកស្រាវជ្រាវស្ត្រីចូលថ្មី សន សុជានី ដែលមានចំណេះដឹង និងបទពិសោធន៍ច្រើនក្នុងការសិក្សាស្រាវជ្រាវពីយេនឌ័រ។

## មជ្ឈមណ្ឌលធនធានធម្មជាតិនិងបរិស្ថាន (CNRE)

មជ្ឈមណ្ឌល CNRE បានធ្វើការស្រាវជ្រាវប្រកបដោយគុណភាពដែលបានពង្រឹងកេរ្តិ៍ឈ្មោះ CDRI ជាក្រុមផ្ដល់គំនិតផ្នែកគោលនយោបាយអាចទុកចិត្តបាន និងឈានមុខ ជាពិសេសខាងផ្នែកធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ នាបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងធ្វើការសិក្សាមួយស្ដីពី *សេវានៃប្រព័ន្ធអេកូក្នុងអេកូទេសចរណ៍ ផ្អែកលើសហគមន៍៖ បញ្ហាប្រឈម និងសក្ដានុពលសម្រាប់ការកែលំអជីវភាពរស់នៅ។* CNRE ក៏បានចូលរួមក្នុងការសិក្សាផ្សេងៗទៀតស្ដីពី ការប្រែប្រួលអាកាសធាតុ មានជាអាទិ៍ *ផលប៉ះពាល់នៃកម្មវិធីពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ហើយនឹង ស្ថានភាពនៃការប្រែប្រួលអាកាសធាតុក្នុងតំបន់អាស៊ាន៖ ការសិក្សាពីប្រទេសកម្ពុជា។* ទាក់ទិននឹងការអភិវឌ្ឍកសិកម្ម ក្រុមស្រាវជ្រាវរបស់ CNRE បានធ្វើការវាយតម្លៃជាច្រើនសម្រាប់ការសិក្សាស្ដីពី *អត្ថប្រយោជន៍នៃការដាំដុះស្រូវតាមកិច្ចសន្យា ហើយនិង ការធ្វើកសិកម្មតាមកិច្ចសន្យាក្នុងតំបន់មេគង្គ-ឡានឆាង។*

មជ្ឈមណ្ឌល CNRE បានដាក់សំណើស្រាវជ្រាវពីរ៖ សំណើទី១ ដាក់ជូនទៅ សាកលវិទ្យាល័យ Chicago សម្រាប់ការសិក្សាស្ដីពី *"ការក្លាយជាអ្នកក្រុង៖ ការស្វែងយល់ពីការប្រែក្លាយជាអ្នកក្រុងនៃជនចំណាកស្រុកមកភ្នំពេញ"* និងទី២ ដាក់ជូនទៅ មូលនិធិកាណាដា សម្រាប់ការសិក្សាស្ដីពី *"ការផ្ដល់សិទ្ធិអំណាចដល់ក្រុមស្ត្រីជនជាតិភាគតិច នៅក្នុងក្រុមប្រឹក្សាឃុំសម្រាប់ស្ត្រីនិងកុមារ (CCWC) និង ក្រុមប្រឹក្សាឃុំសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ (CCDM) នៅកម្ពុជា តាមរយៈសិក្ខាសាលាបណ្ដុះបណ្ដាលកសាងសមត្ថភាព"*។

ក្រោយបានចងក្រងរបាយការណ៍ សម្រាប់គម្រោងស្រាវជ្រាវស្ដីពី *ការធ្វើកសិកម្មតាមកិច្ចសន្យាក្នុងតំបន់មេគង្គ-ឡានឆាង* មជ្ឈមណ្ឌល CNRE បានរៀបចំសន្និសីទផ្សព្វផ្សាយអនឡាញមួយ ដែលផ្ដល់លទ្ធផលដ៏មានប្រយោជន៍សម្រាប់ក្រុមអនុវត្តគម្រោង។

*តទៅទំព័រ ១៨*

# ឯកសារបោះពុម្ពផ្សាយថ្មីៗ
# របស់វិទ្យាស្ថាន CDRI












# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

ថ្ងៃទី១ កក្កដា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI បានរួមសហការរៀបចំកិច្ចសន្ទនាផ្នែកគោលនយោបាយស្ដីពី ចម្លើយតបនឹងជំងឺឆ្លងរាលដាលកូវីដ១៩ នៅកម្ពុជា។** នាយកប្រតិបត្តិ CDRI បានចូលរួមក្នុងកិច្ចសន្ទនាផ្នែកគោលនយោបាយមួយស្ដីពី បទពិសោធន៍រៀនសូត្របានពីការសម្រាលផលប៉ះពាល់ និងគ្រប់គ្រងជំងឺឆ្លងរាលដាលកូវីដ១៩ នៅកម្ពុជា។ កិច្ចសន្ទនានេះ រៀបចំឡើងដោយ វិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ ដោយរួមសហការជាដៃគូជាមួយ វិទ្យាស្ថាន CDRI និង វិទ្យាស្ថាន AVI (វិទ្យាស្ថានចក្ខុវិស័យអាស៊ី)។ ស្ត្រីបីនាក់នៅជួរមុខនៃការប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ គឺមាន វេជ្ជបណ្ឌិត ឱក "វ៉ាន់ឌីន រដ្ឋលេខាធិការក្រសួងសុខាភិបាល បណ្ឌិត Li Ailan ប្រធានការិយាល័យប្រចាំប្រទេសកម្ពុជានៃអង្គការសុខភាពពិភពលោក (WHO) និងបណ្ឌិត Laurence Baril នាយកវិទ្យាស្ថានប៉ាស្ទ័រនៅកម្ពុជា បានចែករំលែកបទពិសោធន៍ក្នុងការឆ្លើយតបជាបន្ទាន់ទៅនឹងកូវីដ១៩ និងគំនិតរបស់ខ្លួនលើ "គន្លងថ្មី" ត្រូវអនុវត្ត និងការងារត្រូវធ្វើដើម្បីរៀបចំស្ថាប័នសុខភាពសាធារណៈនានា និងសេដ្ឋកិច្ចសម្រាប់ពេលអនាគត។ បណ្ឌិតទាំងបីនាក់ បានចូលរួមតាំងពីដំបូងក្នុងសេចក្ដីរាយការណ៍សង្ខេបតាមទូរទស្សន៍ជាតិស្ដីពីកូវីដ១៩។ សាធារណជនបានភ្លឺស្វាងច្រើនដោយបានស្ដាប់គំនិតស៊ីជម្រៅ និងសន្ទនាជាមួយអ្នកទាំងបីដែលជាវីរនារីរបស់យើងទាំងអស់គ្នា។

ថ្ងៃទី៩ កក្កដា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI និង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) បានពិភាក្សាពីមធ្យោបាយ សម្រាប់ញ៉ាំងឲ្យកិច្ចសហការទៅវិញទៅមកកាន់តែស៊ីជម្រៅឡើង។** នាយកប្រតិបត្តិ CDRI និង នាយកមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍អប់រំ (CERI) បានជួបជាមួយនាយក និងអ្នកគ្រប់គ្រងជាន់ខ្ពស់មួយចំនួនរបស់ ITC ដើម្បីពិភាក្សាពីលទ្ធភាពរួមសហការខាងផ្នែក ការកសាងកម្លាំងពលកម្មមានជំនាញ បញ្ញាសិប្បនិម្មិត តម្រូវការជំនាញផ្នែកឌីជីថលនៅតាមសហគ្រាសនិងទីផ្សារពលកម្មនានា កិច្ចសហការជាដៃគូដើម្បីជំរុញការអភិវឌ្ឍនិងប្រើប្រាស់បច្ចេកវិទ្យា និង របៀបរបបអនុវត្តផ្អែកលើភស្តុតាង សម្រាប់ឧត្ដមសិក្សាក្នុងសម័យឌីជីថល។

ថ្ងៃទី១០ កក្កដា ក្រុងភ្នំពេញ

**វិទ្យាស្ថាន CDRI បានចុះអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)។** អនុស្សរណៈយោគយល់គ្នានេះ ត្រូវបានចុះហត្ថលេខាដោយ ឯ.ឧ បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ហើយនិង នាយកប្រតិបត្តិ CDRI ។ អនុស្សរណៈនេះកំណត់ កិច្ចព្រមព្រៀងសហការស្រាវជ្រាវយ៉ាងម៉ត់ចត់ និង ផ្សព្វផ្សាយលទ្ធផលមានភស្តុតាងបញ្ជាក់ សម្រាប់ការកសាងគោលនយោបាយ, ការរៀបចំកិច្ចសន្ទនាផ្នែកគោលនយោបាយ និងជំរុញឲ្យមានអ្នកពាក់ព័ន្ធចូលរួមជាបន្ត, ការផ្ដល់ជំនួយគាំទ្រការកសាងសមត្ថភាពដល់ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, និងការកសាងសម្ព័ន្ធភាពជាយុទ្ធសាស្ត្រជាមួយបណ្ដាស្ថាប័នក្នុងតំបន់និងអន្តរជាតិ ដើម្បីទទួលបាននិងចែករំលែកចំណេះដឹង។ វិស័យសហប្រតិបត្តិការ រួមមាន ផលពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និង ផលប៉ះពាល់នៃកូវីដ១៩ ទៅលើ ទំនាក់ទំនងអន្តរជាតិ កំណែទម្រង់អភិបាលកិច្ច សន្តិសុខស្បៀងនិងភាពម្ចាស់ការ ពហុភាគីនិយម និងការអភិវឌ្ឍកម្លាំងពលកម្ម។ សកម្មភាពទាំងអស់នេះ សំដៅជួយគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការជំរុញកំណើនសេដ្ឋកិច្ចមានចីរភាព និងសម្រាប់

តទៅទំព័រ ២២

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី២៤ លេខ៣ ខែកញ្ញា ឆ្នាំ២០២០

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ សម្រាប់ការពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់នូវការវាយតម្លៃឯករាជ្យពីដំណើរការសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក្ដី។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ពផ្សាយ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ពផ្សាយ ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

☒ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ +៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ 🖷 +៨៥៥២៣៨៨០៧៣៤

e-mail: cdri@cdri.org.kh

website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ

គ្រប់គ្រងកែសម្រួល: អ៊ុំ ចាន់ថា

កែសម្រួលផលិតកម្ម: ម៉េន ច័ន្ទធីតា

សហគ្រាសបោះពុម្ព Go Invent Media (GIM), រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០២០ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈវេបសាយ www.cdri.org.kh